**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**



# របាយការណ៍

# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ

## ខេត្តសៀមរាប និង ខេត្តប៉ៃលិន

*ផលិតដោយ : នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ*

*នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ*

**រាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០២៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍

# លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ

## ខេត្តសៀមរាប និង ខេត្តប៉ៃលិន

*ផលិតដោយ : នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ*

*នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ*

**រាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០២៤**

## មាតិកា


**បុព្វកថា** ...... I

**អារម្ភកថា** ...... II

**ជំពូកទី១** ...... **១**

**សេចក្តីផ្តើម** ...... **១**

**១.១- សេចក្តីផ្តើម** ...... ២

*១.១.១- និមិត្តសញ្ញាសម្គាល់ខេត្ត* ...... *៣*

*១.១.២- ផែនទីខេត្ត* ...... *៦*

*១.១.៣- ផែនទីអនុវត្តគម្រោង* ...... *៨*

**១.២- គោលបំណង** ...... ៨

**១.៣- វិធីសាស្រ្តប្រមូលទិន្នន័យ** ...... ៩

**១.៤- ការផលិតទិន្នន័យ** ...... ៩

**ជំពូកទី២** ...... **១០**

**វិភាគទិន្នន័យ** ...... **១០**

**២.១- ព័ត៌មានប្រជាសាស្រ្ត** ...... ១១

*២.១.១- ព័ត៌មានគ្រួសារ* ...... *១១*

*២.១.២- ព័ត៌មានប្រជាជន* ...... *១២*

*២.១.៣- ការផ្លាស់ប្តូរទីលំនៅ* ...... *១៤*

*២.១.៤- លំនៅឋាន* ...... *១៧*

*២.១.៥- បរិក្ខារកសិកម្ម ដឹកជញ្ជូន និងប្រើប្រាស់* ...... *២០*

**២.២- អត្រាកំណើត និង មរណភាព** ...... ២៣

*២.២.១- អត្រាកំណើត* ...... *២៣*

*២.២.២- មរណភាព* ...... *២៥*

**២.៣- ពិការភាព និង បុគ្គលគ្មានអ្នកថែទាំ** ...... ២៨

**២.៤- ការលែងលះ** ...... ២៩

**២.៥- ការប្រើប្រាស់ទឹក និង បង្គន់អនាម័យ** ...... ៣០

**២.៦- បរិស្ថាន និង ធនធានធម្មជាតិ** ...... ៣៤

**២.៧- សន្តិសុខសង្គម និង សេដ្ឋកិច្ច** ...... ៣៧

*២.៧.១- សន្តិសុខសង្គម* ...... *៣៧*

*២.៧.២- សេដ្ឋកិច្ចគ្រួសារ ........................................................................ ៣៩*
**២.៨- វិស័យអប់រំ និង សេវាសង្គម** ........................................................ ៤២
*២.៨.១- វិស័យអប់រំ ........................................................................ ៤២*
*២.៨.២- សេវាសង្គម........................................................................ ៤៤*
**២.៩- ផ្លូវគមនាគមន៍**........................................................................ ៤៥
**២.១០- សុខាភិបាល** ........................................................................ ៤៦
*២.១០.១- សេវាកម្មសុខភាព........................................................................ ៤៦*
*២.១០.២- ជំងឺសំខាន់ៗ........................................................................ ៤៨*
*២.១០.៣- ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ និង កុមារកំព្រា........................ ៥១*
**២.១១- កសិកម្ម** ........................................................................ ៥២
*២.១១.១- ការកាន់កាប់ដីកសិកម្ម........................................................................ ៥៣*
*២.១១.២- ផ្ទៃដីកសិកម្ម និង ផលិតកម្ម........................................................ ៥៤*
*២.១១.៣- ប្រព័ន្ធស្រោចស្រព ........................................................................ ៥៥*
*២.១១.៤- ការប្រើប្រាស់ជី និង ថ្នាំពុលលើផ្ទៃដីផលិតកម្ម ........................................ ៥៦*
*២.១១.៥- ការចិញ្ចឹមបសុសត្វ និង បសុបក្សី ........................................................ ៥៨*
*២.១១.៦- ទិន្នផលដំណាំ និង គោលបំណងផលិត........................................ ៦១*
**ជំពូកទី៣........................................................................ ៦៣**
**សន្និដ្ឋាន និង អនុសាសន៍ ........................................................................ ៦៣**
**៣.១- សន្និដ្ឋាន**........................................................................ ៦៤
**៣.២- អនុសាសន៍** ........................................................................ ៦៤
**ឧបសម្ព័ន្ធ១ ........................................................................ ៦៦**
**ឧបសម្ព័ន្ធ២ ........................................................................ ៩១**

# បុព្វកថា

របាយការណ៍លទ្ធផលស្តីពី "**ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ**" ជំហានទី៨ គឺជាបណ្តុំទិន្នន័យសំខាន់ៗជាច្រើន ដូចជាៈ ស្ថិតិប្រជាសាស្ត្រ, សន្តិសុខ, សង្គម, សេដ្ឋកិច្ច, អប់រំ, សុខាភិបាល និងស្ថិតិកសិកម្ម ដែលជាតម្រូវការចាំបាច់មិនអាចខ្វះបាន សម្រាប់ធ្វើជាមូលដ្ឋានគ្រឹះក្នុងការកសាងផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗ ដើម្បីអភិវឌ្ឍនៅថ្នាក់ក្រោមជាតិស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។ របាយការណ៍លទ្ធផលស្តីពី "**ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ**" ត្រូវបានរៀបចំឡើងផ្អែកលើទិន្នន័យដែលប្រមូលបានពីខេត្តចំនួន២ គឺខេត្តសៀមរាប និងខេត្តប៉ៃលិន។

ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺជាចំណុចចាប់ផ្តើមក្នុងការអភិវឌ្ឍប្រទេសជាតិ ដែលបានឆ្លុះបញ្ចាំងពីស្ថានភាពសង្គមនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន ជួយជំរុញទិសដៅក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០។ ទិន្នន័យនេះ ក៏ជាធាតុចូលដ៏សំខាន់សម្រាប់អ្នករៀបចំគោលនយោបាយ ស្ថាប័នរដ្ឋ បណ្តាអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ ក្នុងការដាក់ចេញនូវផែនការច្បាស់លាស់ សម្រាប់ការវិនិយោគលើវិស័យជាអាទិភាពនៅថ្នាក់ក្រោមជាតិ។

លើសពីនេះទៀតទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺជាមាគ៌ាដ៏សំខាន់មួយសម្រាប់ផ្សារភ្ជាប់រវាង ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានតួនាទីមិនអាចខ្វះបានសម្រាប់ការបង្កើត ការគ្រប់គ្រងគោលនយោបាយសាធារណៈ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃផលប៉ះពាល់នៃការអនុវត្តគោលនយោបាយ ការផ្តល់ជំនួយ ឬការវិនិយោគផ្សេងៗទៀតនៅថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព។ របាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺជាប្រភពទិន្នន័យមួយដែលមិនអាចខ្វះបានក្នុងការផ្តល់នូវ "**ទិន្នន័យទាន់ពេលវេលា និងច្បាស់លាស់**" ដែលឆ្លើយតបចំគោលដៅ និងឈានដល់ការអភិវឌ្ឍប្រទេសឱ្យកាន់តែមានភាពរីកចម្រើន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះប្រមុខរាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្តល់នូវការគាំទ្រ ទាំងផ្នែកស្មារតី និងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តកិច្ចការនេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងអំណរគុណ ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលបានចូលរួមអនុវត្តការងារប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ ជំហានទី៨ នេះ សម្រេចបានលទ្ធផលគួរជាទីមោទនៈ។

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រឈៃ**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានក្តីសោមនស្សរីករាយ សូមបង្ហាញជូននូវរបាយការណ៍ ស្តីពី "លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ដែលបានផលិតឡើងដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការសហការពីមន្ទីរផែនការខេត្តសៀមរាបនិងខេត្ត ប៉ៃលិន។ របាយការណ៍នេះ បានផ្តល់នូវទិន្នន័យសំខាន់ៗជាច្រើន ដូចជាស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម ដែលជាសូចនាករដ៏សំខាន់មិនអាចខ្វះបានសម្រាប់កសាង ផែនការ រៀបចំគោលនយោបាយ និងកម្មវិធីផ្សេងៗដើម្បីអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ។

របាយការណ៍នេះ ត្រូវបានផលិតឡើងដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយសហការជាមួយមន្ទីរផែនការរាជធានី ខេត្តបានចំនួន២០ខេត្ត (៧លើក) រួចមកហើយ រួមមានខេត្តបន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កែប កំពត កោះកុង ព្រះសីហនុ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ព្រះវិហារ កណ្តាល តាកែវ ស្វាយរៀង ព្រៃវែង កំពង់ធំ និងខេត្ត ឧត្តរមានជ័យ។ ដោយឡែកឆ្នាំ២០២៣នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិបានបន្តចុះស្រង់ទិន្នន័យស្ថិតិ ថ្នាក់ក្រោមជាតិបានចំនួន២ខេត្តទៀត (លើកទី៨) គឺខេត្តសៀមរាបនិងខេត្តប៉ៃលិន។ នៅក្នុងរបាយការណ៍ នេះផងដែរ គឺមានការវិភាគជាតារាងតួលេខ ជារូបភាព (ក្រាហ្វិក) រួមជាមួយនឹងការអធិប្បាយខ្លីៗ ដែលអាច ជាប្រភពទិន្នន័យដ៏សំខាន់សម្រាប់អ្នកប្រើប្រាស់គ្រប់រូបភាពដែលមានចំណាប់អារម្មណ៍ទៅលើទិន្នន័យ ស្ថិតិថ្នាក់ក្រោមជាតិ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរនិងអរគុណ ចំពោះក្រុមការងារនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ មន្ទីរផែនការខេត្តសៀមរាប និងមន្ទីរផែនការខេត្តប៉ៃលិនដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរៀបចំ ចងក្រង និងបោះពុម្ពផ្សាយនូវរបាយការណ៍ "លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ដ៏មានសារៈសំខាន់ ជាលើកទី៨នេះឡើង៕

**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ទ្រី ឫទ្ធា**

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១- សេចក្តីផ្តើម

ស្ថិតិថ្នាក់ក្រោមជាតិ គឺជាគម្រោងថ្មីមួយដែលវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានរៀបចំឡើងដើម្បីប្រមូលទិន្នន័យស្ថិតិនៅថ្នាក់មូលដ្ឋាន និងធ្វើការវិភាគលើលទ្ធផលទាំងនោះស្របតាមការធ្វើវិមជ្ឈការនិងសហវិមជ្ឈការសម្រាប់ថ្នាក់ក្រោមជាតិ។

ទិន្នន័យដែលត្រូវប្រមូលពីថ្នាក់មូលដ្ឋានដើម្បីយកមកវិភាគនិងចងក្រង រួមមានស្ថិតិប្រជាសាស្ត្រ សន្តិសុខ សង្គម សេដ្ឋកិច្ច អប់រំ សុខាភិបាល និងស្ថិតិកសិកម្ម។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកអនុវត្តគម្រោងនេះដោយផ្ទាល់ ដែលនេះគឺស្របទៅតាមភារកិច្ចរបស់នាយកដ្ឋាន និងសេចក្តីសម្រេចដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** (អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា) ស្នើឱ្យក្រសួងផែនការបង្កើតនាយកដ្ឋាននេះឡើងតាមអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤។

ប្រទេសកម្ពុជាបានបែងចែកជា៤តំបន់សំខាន់ៗ គឺតំបន់ភ្នំនិងខ្ពង់រាប តំបន់វាលទំនាប តំបន់បឹងទន្លេសាប និងតំបន់ឆ្នេរសមុទ្រ។ យ៉ាងណាមិញ នៅជំហានទី៨ឆ្នាំ២០២៣នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ បានជ្រើសរើសយកខេត្តចំនួន២ (ខេត្តសៀមរាបនិងខេត្តប៉ៃលិន) មកបន្តអនុវត្តគម្រោងរបស់ខ្លួន។

**សៀមរាប** គឺជាខេត្តមួយស្ថិតនៅតំបន់ពាយព្យនៃប្រទេសកម្ពុជា។ ខេត្តនេះមានផ្ទៃដីសរុបប្រមាណ ១០.២៩៩,៤៣គីឡូម៉ែត្រការ៉េ ដោយចែកចេញជា១២ក្រុង/ស្រុក ១០០ឃុំ/សង្កាត់ និង៩០៩ភូមិ ហើយមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ ខាងកើតជាប់ខេត្តកំពង់ធំនិងខេត្តព្រះវិហារ ខាងលិចជាប់ខេត្តបន្ទាយមានជ័យ និងខាងត្បូងជាប់ខេត្តបាត់ដំបងនិងបឹងទន្លេសាប (ព្រំប្រទល់ជាប់បឹងទន្លេសាបមានប្រវែង៨២គីឡូម៉ែត្រ ស្ថិតនៅជាប់ស្រុកជីក្រែង សូត្រនិគម ប្រាសាទបាគង សៀមរាប ពួក និងស្រុកក្រឡាញ់)។ បើគេធ្វើដំណើរតាមផ្លូវគោកពីរាជធានីភ្នំពេញទៅទីរួមនៃខេត្តនេះ (ក្រុងសៀមរាប) គេអាចចេញពីរាជធានីភ្នំពេញទៅតាម៖

- ផ្លូវជាតិលេខ៦ ៖ ឆ្លងកាត់ខេត្តកណ្តាល កំពង់ចាម និងខេត្តកំពង់ធំ មានចម្ងាយប្រមាណ ៣១៤គីឡូម៉ែត្រ
- ផ្លូវជាតិលេខ៥ ៖ ឆ្លងកាត់ខេត្តកណ្តាល កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងខេត្តបន្ទាយមានជ័យ មានចម្ងាយប្រមាណ៤៥៣គីឡូម៉ែត្រ។

**ខេត្តប៉ៃលិន** ស្ថិតនៅប៉ែកខាងលិចនៃប្រទេសកម្ពុជា និងមានផ្ទៃដីសរុបប្រមាណ១.០៦២ គីឡូម៉ែត្រការ៉េ ដោយចែកចេញជា២ក្រុង/ស្រុក ៨ឃុំ/សង្កាត់ និង៩២ភូមិ។ ខេត្តនេះមានព្រំប្រទល់ខាងជើងជាប់នឹងស្រុកកំរៀង (ខេត្តបាត់ដំបង) ខាងត្បូងជាប់នឹងស្រុកសំឡូត (ខេត្តបាត់ដំបង) ខាងកើតជាប់នឹងស្រុករតនមណ្ឌល (ខេត្តបាត់ដំបង) និងខាងលិចជាប់នឹងស្រុកពោងណាំរ៉ង (ខេត្តច័ន្ទបូរី ប្រទេសថៃ)។ បើគេធ្វើដំណើរតាមផ្លូវគោកទៅទីរួមនៃខេត្តនេះ (ក្រុងប៉ៃលិន) គឺត្រូវឆ្លងកាត់ខេត្តកណ្ដាល កំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលមានចម្ងាយប្រមាណ៣៧១គីឡូម៉ែត្រ។

### ១.១.១- និមិត្តសញ្ញាសម្គាល់ខេត្ត

#### ក- ខេត្តសៀមរាប




ការប្រើប្រាស់នូវនិមិត្តសញ្ញាសម្គាល់នេះ គឺយោងទៅតាមប្រកាសលេខ ៥៥០៨ ប្រក ចុះថ្ងៃអង្គារ ៨រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ស្ដីពី ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តសៀមរាប។

## អត្ថន័យនិមិត្តសញ្ញា៖

- **មានរាងមូល**
- **រូបប្រាសាទអង្គរវត្ត** : ជាអត្តសញ្ញាណជាតិ ដែលបានចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក នាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩២។ ប្រាសាទនេះត្រូវបានបុព្វបុរសខ្មែរកសាងនៅលើទឹកដីដ៏ពិសិដ្ឋ ដែលបានកសាងសេដ្ឋកិច្ច វប្បធម៌ ការពារទឹកដី ខឿននៃអរិយធម៌ ស្ថិតនៅចន្លោះភ្នំគូលែននិង បឹងទន្លេសាបក្នុងភូមិសាស្ត្រខេត្តសៀមរាប និងត្រូវបានទទួលស្គាល់ និងទម្លាប់ហៅតាមគ្នាថា "សៀមរាបអង្គរ"
- **រូបនាគ** : តំណាងឱ្យពិភពចក្រវាលទាំងប្រាំពីរ គឺព្រះចន្ទ ព្រះអង្គារ ព្រះពុធ ព្រះព្រហស្បតិ៍ ព្រះសុក្រ ព្រះសៅរ៍ និងព្រះអាទិត្យ និងជានិមិត្តរូបនៃភាពត្រជាក់ត្រជុំ សុខដុមរមនា ការរួបរួមកម្លាំង សាមគ្គីភាពក្រោមម្លប់នៃសុខសន្តិភាព តាមរយៈនយោបាយឈ្នះ-ឈ្នះ
- **រូបរហាត់ទឹក** : ជាឧបករណ៍ស្រោចស្រព តំណាងឱ្យប្រព័ន្ធធារាសាស្ត្រដែលមានតាំងពីសម័យ បុរាណកាលមក ហើយត្រូវបានអភិរក្ស និងអភិវឌ្ឍន៍រហូតដល់បច្ចុប្បន្នសម្រាប់ប្រើប្រាស់ក្នុង វិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាជន
- **រូបទឹកនិងត្រី** : ក្រៅពីបឹងទន្លេសាប ត្រពាំង បឹងបួ អូរ ប្រឡាយធម្មជាតិ ក្រោមនយោបាយទឹក បារាយណ៍ទឹកថ្លា កសិណ ត្រូវបានរៀបចំសម្រាប់ជាប្រព័ន្ធការពារសំណង់ស្ថាបត្យកម្ម និងគ្រឹះ នៃសេដ្ឋកិច្ចជាតិ ជាប្រភពនៃមច្ឆជាតិ និងជីវៈចម្រុះបម្រើដល់ប្រព័ន្ធស្បៀងអាហារ
- **កួរស្រូវ** : តំណាងឱ្យវិស័យកសិកម្មដ៏មានសក្តានុពលតាំងពីបុរាណកាលមក ហើយវិស័យនេះ នៅតែបន្តជ្រោងខឿនសេដ្ឋកិច្ចខេត្ត។ ក្រៅពីការផ្គត់ផ្គង់ជីវភាពប្រជាជន ភាពសម្បូររុងរឿងនៃ វិស័យកសិកម្មពេលបច្ចុប្បន្ននេះ បានជួយដោយប្រយោលលើវិស័យទេសចរណ៍ផងដែរ
- **ក្បាច់ផ្កាភ្ញីអង្គរ** : តំណាងឱ្យខឿនវប្បធម៌នៃស្ថាបត្យកម្មរស់រវើករបស់ស្ថាបត្យករដ៏ល្អឯកក្នុងសម័យ បុរាណកាល
- **ខ្សែបូ** : មានបីពណ៌យកតាមទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់លើកតម្លៃ កិត្តិយស សោភ័ណភាព និងទ្រទ្រង់អត្ថន័យនៃនិមិត្តសញ្ញារបស់រដ្ឋបាលខេត្តសៀមរាប។

## ខ- ខេត្តប៉ៃលិន



ការប្រើប្រាស់នូវនិមិត្តសញ្ញាសម្គាល់នេះ គឺយោងទៅតាមប្រកាសលេខ ១៥៨៨ ប្រក ចុះថ្ងៃអង្គារ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពី ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តប៉ៃលិន។

### អត្ថន័យនិមិត្តសញ្ញា៖

- **មានរាងមូល**
- **វ័ណ្ណមូលពីរហ៊ុំព័ទ្ធ** : តំណាងឱ្យភាពត្រជាក់ត្រជុំ សម្បូររុងរឿង និងព្រំដែននៃដែនដីរដ្ឋបាលខេត្តប៉ៃលិន ក្រោមម្លប់សន្តិភាពពេញបរិបូណ៌ និងយូរអង្វែង
- **រូបភេទ្រត្បូង** : តំណាងឱ្យប្រវត្តិនៃការកកើតនូវឈ្មោះប៉ៃលិន ដែលក្លាយមកពីពាក្យ ភេលេន ជាភាសានិយាយនៃជនជាតិដើមកូឡា ដែលបានរស់នៅក្នុងតំបន់នេះតាំងពីយូរលង់មកហើយ
- **រូបភ្នំ រួមមានភ្នំខៀវ ភ្នំយ៉ាត និងត្បូង** : តំណាងឱ្យធនធានធម្មជាតិដ៏សម្បូរបែបរួមមាន ព្រៃឈើ សត្វចតុប្បាទ បក្សាបក្សីគ្រប់ប្រភេទ និងធនធានរ៉ែត្បូង ដែលជាធនធានដ៏សំខាន់គ្រប់វិស័យរបស់ខេត្ត

- **រូបចេតិយបុរាណនិងរូបសំណាកលោកយាយយ៉ាត អមដោយសត្វក្ងោកមួយគូ** : តំណាងឱ្យការរស់នៅដោយក្ដីសប្បាយរីករាយ ការគោរពប្រពៃណី វប្បធម៌រូបិយ និងអរូបិយ អរិយធម៌ដ៏ចំណាស់របស់ខេត្ត និងជំនឿសាសនា
- **ទម្រស្ទឹកងចក្រនិងកួរស្រូវចងដោយក្បាច់ផ្ការំដួល** : តំណាងឱ្យមូលដ្ឋានអភិវឌ្ឍសេដ្ឋកិច្ចរីកចម្រើនរបស់ខេត្តក្នុងវិស័យកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងសហគ្រាស ក្រោមគោលនយោបាយកែទម្រង់ស៊ីជម្រៅ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល
- **ផ្ទៃមេឃពណ៌ខៀវខ្ចី** : តំណាងឱ្យភាពអំណោយផលនៃអាកាសធាតុបរិសុទ្ធនៃធម្មជាតិ បរិស្ថានល្អសម្រាប់ជីវិតមនុស្ស សត្វ និងភាពសុខដុមរមនារបស់ប្រជាពលរដ្ឋទូទៅនៅលើទឹកដីនៃខេត្តប៉ៃលិន។

## ១.១.២- ផែនទីខេត្ត

### ក- ខេត្តសៀមរាប



## ខ- ខេត្តប៉ៃលិន



### ១.១.៣- ផែនទីអនុវត្តគម្រោង




## ១.២- គោលបំណង

គោលបំណងសំខាន់នៃរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិនេះ គឺដើម្បីផ្តល់នូវទិន្នន័យដែលជាតម្រូវការចាំបាច់សម្រាប់តម្រូវការៈ

- ធ្វើគោលនយោបាយអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ
- ប្រើប្រាស់ក្នុងវិទ្យាស្ថានជាតិស្ថិតិ (NIS) ក្រសួងផែនការ
- អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត បណ្ដាអង្គការជាតិ-អន្តរជាតិ ស្ថាប័នរដ្ឋ និងស្ថាប័នឯកជនជាច្រើនទៀត។

នៅក្នុងជំពូកបន្ទាប់ នឹងមានបង្ហាញយ៉ាងលម្អិតនូវទិន្នន័យជាច្រើនដែលទាក់ទងទៅនឹងព័ត៌មានស្ថិតិប្រជាសាស្ត្រ សន្តិសុខសង្គម សេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ និងស្ថិតិកសិកម្ម។ ក្រៅពីការបោះពុម្ពផ្សាយចេញនូវសៀវភៅរបាយការណ៍ "លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ" ខេត្តសៀមរាបនិងខេត្តប៉ៃលិនឆ្នាំ២០២៣នេះ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិក៏មានផ្សព្វផ្សាយដោយបើកចំហនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ តាមអាសយដ្ឋាន https://www.nis.gov.kh ផងដែរ។

## ១.៣- វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ គឺត្រូវបានធ្វើឡើងដោយការសម្ភាសទល់មុខ (Face to Face) និងប្រើប្រាស់ម៉ាស៊ីនថេប្លេត តាមរយៈកម្មវិធីឌីជីថល (Kobo Toolbox)។ កម្រងបញ្ជីសំណួរស្ថិតិថ្នាក់ក្រោមជាតិនេះ ត្រូវបានចុះសម្ភាសន៍គ្រប់ភូមិដែលមាននៅក្នុងខេត្តជាមួយមេភូមិទាំងអស់រយៈពេល ១៥ថ្ងៃ គឺចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ ដោយមន្ត្រីនៃមន្ទីរផែនការខេត្តសៀមរាបនិងខេត្តប៉ៃលិន ក្រោយពីទទួលបានការបណ្តុះបណ្តាលយ៉ាងលម្អិតនិងច្បាស់លាស់រួចមក។ នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ គឺជាអ្នកសម្របសម្រួលផ្នែកបច្ចេកទេសតាំងពីចាប់ផ្តើមដំណើរការ រហូតដល់ការប្រមូលទិន្នន័យត្រូវបានបញ្ចប់ដោយជោគជ័យ១០០ភាគរយ។ ចំណែកកាលបរិច្ឆេទយោងនៃការប្រមូលទិន្នន័យ គឺយករយៈពេល១២ខែកន្លងមក ដោយគិតចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣។

## ១.៤- ការផលិតទិន្នន័យ

ការផលិតទិន្នន័យ គឺត្រូវបានធ្វើឡើងដោយការទាញយកទិន្នន័យពីកម្មវិធី Kobo Toolbox បំប្លែងទៅជា Microsoft Excel ដើម្បីវិភាគទិន្នន័យ បង្កើតជាតារាង និងសង់ជាក្រាហ្វិក មុននឹងឈានដល់ការបកស្រាយទិន្នន័យក្នុងកម្មវិធី Microsoft Word។ ដំណើរការផលិត និងវិភាគទិន្នន័យមានរយៈពេល៣ខែ គឺចាប់ពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ បន្ទាប់ពីការចុះស្រង់ទិន្នន័យតាមមូលដ្ឋានរួចមក។

# ជំពូកទី២

# វិភាគទិន្នន័យ

## ២.១- ព័ត៌មានប្រជាសាស្ត្រ

### ២.១.១- ព័ត៌មានគ្រួសារ

**គ្រួសារ** គឺជាមនុស្សមួយក្រុមដែលរស់នៅរួមគ្នា និងបរិភោគអាហារចេញពីចង្ក្រានតែមួយ វៀរលែងតែអ្នកដែលមានការងារពិសេសមិនអាចទៅហូបចុកជាមួយបាន។

**មេគ្រួសារ** គឺជាមនុស្សដែលត្រូវបានទទួលស្គាល់ពីសមាជិកក្នុងគ្រួសារ។ មេគ្រួសារអាចជាបុរស ឬស្ត្រី ដែលជាទូទៅគាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងគ្រួសារ និងធ្វើការសម្រេចចិត្តក្នុងនាម (តំណាង)ឱ្យគ្រួសារ។ មេគ្រួសារ មិនចាំបាច់ត្រូវតែជាមនុស្សចាស់ទេ ប៉ុន្តែគាត់អាចជាបុរស ស្ត្រី ក្មេងស្រី ឬក្មេងប្រុសនៃសមាជិកក្នុងគ្រួសារនោះ។

*តារាងទី១ : ចំនួនមេគ្រួសារ បែងចែកតាមភេទ*

| ភេទមេគ្រួសារ | ខេត្តសៀមរាប | ខេត្តប៉ៃលិន |
|---|---|---|
| បុរស | ២២៧.៦៧៦ | ១៨.១១៨ |
| ស្ត្រី | ៣៣.៨៥០ | ២.១៦៥ |
| សរុប | ២៦១.៥២៦ | ២០.២៨៣ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១ គឺជាចំនួនមេគ្រួសារបែងចែកតាមភេទនៅក្នុងខេត្តគោលដៅ។ យើងឃើញថា ខេត្តសៀមរាបមានចំនួន២៦១.៥២៦គ្រួសារ (ស្ត្រីជាមេគ្រួសារ៣៣.៨៥០គ្រួសារ ស្មើនឹង១៣%) ចំណែកខេត្តប៉ៃលិនមាន២០.២៨៣គ្រួសារ (ស្ត្រីជាមេគ្រួសារ២.១៦៥គ្រួសារ ស្មើនឹង១១%)។

*រូបភាពទី១ : ភាគរយស្ត្រីជាមេគ្រួសារដែលមានកុមារអាយុក្រោម៥ឆ្នាំរស់នៅជាមួយ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១ បានបង្ហាញពីភាគរយស្ត្រីជាមេគ្រួសារដែលមានកុមារអាយុក្រោម៥ឆ្នាំរស់នៅជាមួយ។ ក្នុងចំណោមស្ត្រីជាមេគ្រួសារនៅក្នុងខេត្តទាំងពីរ យើងឃើញថា ខេត្តសៀមរាបមាន៣៧% (១២.៦៦៦ គ្រួសារ) និងខេត្តប៉ៃលិនមាន១៧% (៣៥៨គ្រួសារ) មានកុមារអាយុក្រោម៥ឆ្នាំស្នាក់នៅនិងកំពុងរស់នៅជាមួយគ្នា។

## ២.១.២- ព័ត៌មានប្រជាជន

**ប្រជាជន** គឺសំដៅដល់មនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ជាតិសាសន៍ ដែលរស់នៅ ឬធ្វើការក្នុងប្រទេសណាមួយជាក់លាក់។

### ក- ចំនួនប្រជាជន

*តារាងទី២ : ចំនួនប្រជាជនបែងចែកតាមជនជាតិ*

| ជនជាតិ | សៀមរាប | | | ប៉ៃលិន | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ខ្មែរ | ១.២០៣.២០៨ | ៥៩៤.២១៦ | ៦០៨.៩៩២ | ៨៤.៦២០ | ៤២.៥៥៨ | ៤២.០៦២ |
| ចិន | ០ | ០ | ០ | ៩០៤ | ៦០១ | ៣០៣ |
| ថៃ | ២ | ២ | ០ | ១.២១២ | ៥៤៩ | ៦៦៣ |
| ឡាវ | ០ | ០ | ០ | ១ | ០ | ១ |
| វៀតណាម | ៣.១៥២ | ១.៦៦៤ | ១.៤៨៨ | ៤២ | ១៦ | ២៦ |
| ខ្មែរឥស្លាម | ៧២៦ | ៣៩២ | ៣៣៤ | ៤៨៦ | ២៣១ | ២៥៥ |
| កូរ៉េ | ០ | ០ | ០ | ៥ | ៣ | ២ |
| ជនជាតិដើមភាគតិច | ០ | ០ | ០ | ០ | ០ | ០ |
| ជនជាតិផ្សេងៗទៀត | ២ | ០ | ២ | ១ | ១ | ០ |
| សរុប | ១.២០៧.០៩០ | ៥៩៦.២៧៤ | ៦១០.៨១៦ | ៨៧.២៧១ | ៤៣.៩៥៩ | ៤៣.៣១២ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២ បានបង្ហាញពីចំនួនប្រជាជនដោយបែងចែកទៅតាមជនជាតិ។ តារាងនេះបង្ហាញថា ខេត្តសៀមរាបមានប្រជាជនសរុបប្រមាណ១.២០៧.០៩០នាក់ (ក្នុងនោះស្រី៦១០.៨១៦នាក់ ស្មើនឹង ៥០,៦០%)។ ក្រៅពីជនជាតិខ្មែរ ខេត្តសៀមរាបមាន ០,២៦%ជាជនជាតិវៀតណាម និង០,០៦% ជាខ្មែរឥស្លាម។ ខេត្តប៉ៃលិនមានប្រជាជនសរុបប្រមាណជា៨៧.២៧១នាក់ (ក្នុងនោះស្រី៤៣.៣១២នាក់ ស្មើនឹង៤៩,៦៣%)។ ក្រៅពីជនជាតិខ្មែរ ខេត្តនេះមាន ១,៣៩%ជាជនជាតិថៃ ១,០៤%ជាជនជាតិចិន ០,៥៦%ជាខ្មែរឥស្លាម ០,០៥%ជាជនជាតិវៀតណាម និង ០,០១%ជាជនជាតិកូរ៉េ។

## ខ- ស្ថានភាពអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ ត្រូវបានកំណត់និយមន័យខុសៗគ្នាទៅតាមអង្គភាព ឬដោយផ្អែកទៅលើវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី សាសនា មជ្ឈដ្ឋានជុំវិញ ឬបុគ្គលផ្ទាល់ខ្លួនជាដើម។ នៅក្នុងរបាយការណ៍នេះ និយមន័យនៃអាពាហ៍ពិពាហ៍ត្រូវបានកំណត់ថា ជាកិច្ចសន្យាសង្គមនិងច្បាប់រវាងបុគ្គលពីរនាក់ដែលបង្រួបបង្រួមជីវិតរបស់ពួកគេតាមផ្លូវច្បាប់ផ្នែកសេដ្ឋកិច្ច និងខាងអារម្មណ៍។ កិច្ចសន្យាអាពាហ៍ពិពាហ៍ ជាធម្មតាបញ្ជាក់ថា ប្ដីប្រពន្ធនោះមានកាតព្វកិច្ចផ្លូវច្បាប់ចំពោះគ្នាទៅវិញទៅមកពេញមួយជីវិត ឬរហូតដល់ពួកគេសម្រេចចិត្តលែងលះគ្នា។

*តារាងទី៣ : ភាគរយនៃស្ថានភាពអាពាហ៍ពិពាហ៍តាមគ្រួសារ*

| ស្ថានភាពអាពាហ៍ពិពាហ៍ | ខេត្តសៀមរាប | ខេត្តប៉ៃលិន |
|---|---|---|
| បានរៀបការរួច | ៨៧,៧ | ៨៩,២ |
| មេម៉ាយ/ពោះម៉ាយ | ៩,៥ | ៩,៦ |
| រស់នៅផ្សេងគ្នា | ២,០ | ០,៤ |
| រស់នៅជាមួយគ្នាមិនបានរៀបការ | ០,៧ | ០,៦ |
| មិនដែលរៀបការ/នៅលីវ | ០,២ | ០,២ |
| **សរុប** | **១០០,០** | **១០០,០** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី៣ បានបង្ហាញពីភាគរយនៃស្ថានភាពអាពាហ៍ពិពាហ៍តាមគ្រួសារ។ យើងឃើញថា ក្នុងគ្រួសារសរុបទាំង២៦១.៥២៦គ្រួសារ នៃខេត្តសៀមរាប គ្រួសារដែលបានរៀបការរួច (កំពុងរស់នៅជាមួយគ្នា) មានភាគរយខ្ពស់ជាងគេ (៨៧,៧%) បន្ទាប់មក គ្រួសារមេម៉ាយ/ពោះម៉ាយ (៩,៥%) បន្ទាប់មកទៀត

គ្រួសារដែលរស់នៅផ្សេងគ្នា (២,០%) គ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការ (០,៧%) និងគ្រួសារមិនដែលរៀបការ/នៅលីវមាន (០,២%)។ ខេត្តប៉ៃលិនមានគ្រួសារសរុបចំនួន២០.២៨៣គ្រួសារ ក្នុងនោះមានគ្រួសារដែលបានរៀបការរួចចំនួន៨៩,២% បន្ទាប់មក គឺគ្រួសារមេម៉ាយ/ពោះម៉ាយមាន៩,៦% គ្រួសារដែលរស់នៅជាមួយគ្នាដោយមិនបានរៀបការមាន០,៦% គ្រួសារដែលរស់នៅផ្សេងគ្នាមាន០,៤% និងចុងក្រោយគឺគ្រួសារមិនដែលរៀបការ/នៅលីវមានចំនួន០,២%។

## ២.១.៣- ការផ្លាស់ប្តូរទីលំនៅ

**ការផ្លាស់ប្តូរទីលំនៅ** គឺជាចលនាផ្លាស់ប្តូរទីកន្លែងរស់នៅរបស់មនុស្សពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ ជាទូទៅ គេចាត់ទុកចលនាបម្លាស់លំនៅជាបាតុភូតសកល ពីព្រោះចលនានេះតែងតែកើតមានឡើងនៅគ្រប់ប្រទេសទាំងអស់ មិនថាប្រទេសអ្នកមាន ឬប្រទេសអ្នកក្រនោះទេ។ កត្តាចម្បងដែលនាំឱ្យមានបញ្ហានេះ គឺដោយសារវិបត្តិសេដ្ឋកិច្ច ទំនិញឡើងថ្លៃ ការប្តូរកន្លែងធ្វើការ ការស្វែងរកការងារធ្វើ អសន្តិសុខ ការវិលជួបជុំគ្រួសារ កូនកំព្រា និងការបាត់បង់ដីធ្លី ឬលំនៅឋាន។ នៅកម្ពុជាបច្ចុប្បន្ន គេចែកបម្លាស់លំនៅជាបួនរូបភាព គឺបម្លាស់លំនៅពីជនបទទៅទីក្រុង បម្លាស់លំនៅពីជនបទទៅជនបទ បម្លាស់លំនៅពីទីក្រុងទៅទីក្រុង និងបម្លាស់លំនៅពីទីក្រុងទៅជនបទ។

### ក- ចំណូលស្រុក និង ចំណាកស្រុក

តាមនិយមន័យនៃទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិបានកំណត់ថា **ចំណូលស្រុក** គឺជាបម្លាស់លំនៅរបស់ប្រជាជនដែលចូលមករស់នៅតំបន់ណាមួយជាក់លាក់នៅក្នុងប្រទេស ឬមកពីប្រទេសផ្សេងចាប់ពីរយៈពេល៦ខែឡើងទៅ។ **ចំណាកស្រុក** គឺជាបម្លាស់លំនៅរបស់ប្រជាជនដែលចេញពីតំបន់មួយទៅក្នុងតំបន់ផ្សេងទៀតនៅក្នុងប្រទេស ឬក្រៅប្រទេសជាក់លាក់ណាមួយចាប់ពីរយៈពេល៦ខែឡើងទៅ។




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ចំណូលស្រុក ឬចំណាកស្រុក គឺមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងកត្តាសេដ្ឋកិច្ច សន្តិសុខ និង សង្គម។ រូបភាពទី២ បានបង្ហាញពីភាគរយនៃប្រជាជនធ្វើចំណូលស្រុក និង ចំណាកស្រុក។ ខេត្តសៀមរាប មានប្រជាជនធ្វើចំណូលស្រុក០,២% និងចំណាកស្រុក៧,០% នៃប្រជាជនសរុប១.២០៧.០៩០នាក់។ ដោយឡែកខេត្តប៉ៃលិនវិញ ប្រជាជនធ្វើចំណូលស្រុក០,៩% និងចំណាកស្រុក៧,៤% នៃប្រជាជនសរុប ៨៧.២៧១នាក់។

## ខ- ភេទនៃអ្នកចំណូលស្រុក និង ចំណាកស្រុក




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ខេត្តសៀមរាបមានប្រជាជនចំណូលស្រុកប្រមាណជា២.០៤២នាក់ (៤៣,២% ជាមនុស្សស្រី) និងប្រជាជនចំណាកស្រុកប្រមាណជា៨៤.៨១៦នាក់ (៣៩,២% ជាមនុស្សស្រី) រីឯខេត្តប៉ៃលិនមានប្រជាជនចំណូលស្រុកប្រមាណ៧៨៨នាក់ (៤៩,៧% ជាមនុស្សស្រី) និងចំណាកស្រុកប្រមាណ៦.៤៧៧ នាក់ (៤៦,៦% ជាមនុស្សស្រី) (មើលរូបភាពទី៣)។

## គ- មូលហេតុចំណាកស្រុក

*រូបភាពទី៤ : ភាគរយនៃការធ្វើចំណាកស្រុកក្នុងប្រទេស*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី៤ បង្ហាញពីមូលហេតុចម្បងនៃការធ្វើចំណាកស្រុករបស់ប្រជានជនក្នុងតំបន់ ឬពីខេត្តមួយទៅខេត្តមួយនៃប្រទេសកម្ពុជា ដោយផ្អែកលើកត្តាចំបាច់មួយចំនួនដែលជាតម្រូវការរបស់ពួកគាត់។ យើងកត់សម្គាល់ឃើញថា ក្នុងចំណោមប្រជាជនចំណាកស្រុកក្នុងប្រទេសទាំងអស់នៃខេត្តសៀមរាប អត្រាប្រជាជនធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើមានរហូតដល់ទៅ៩៥,៥% ខណៈដែលចំណាកស្រុកដើម្បីបន្តការសិក្សាមាន៤,៣% និងមូលហេតុផ្សេងទៀតមាន០,១%។ ចំណែកខេត្តប៉ៃលិន អត្រាអ្នកចំណាកស្រុកដើម្បីស្វែងរកការងារធ្វើមានទាបជាងខេត្តសៀមរាប៧,៩% ខណៈការចំណាកស្រុកដើម្បីទៅបន្តការសិក្សាមានខ្ពស់ជាងខេត្តសៀមរាប៨,១%។




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ក្រៅពីការធ្វើចំណាកស្រុកក្នុងប្រទេស ខេត្តទាំងពីរក៏មានប្រជាជនចំណាកស្រុកក្រៅផងដែរ។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកក្រៅប្រទេសរបស់ប្រជានជនខេត្តសៀមរាប គឺការស្វែងរកការងារធ្វើមានរហូតដល់ទៅ៩៩,៨% ខណៈដែលចំណាកស្រុកក្រៅប្រទេសដើម្បីបន្តការសិក្សាមាន០,២% ចំណែកឯខេត្តប៉ៃលិន អត្រាអ្នកចំណាកស្រុកក្រៅប្រទេសដើម្បីស្វែងរកការងារធ្វើមាន៩៦,១% ខណៈដែលការទៅបន្តការសិក្សាមាន៣,៩% (មើលរូបភាពទី៥)។

## ២.១.៤- លំនៅឋាន

គោលបំណងសំខាន់នៅក្នុងផ្នែកនេះ គឺដើម្បីបង្ហាញនូវទិន្នន័យស្ថិតិអំពីលំនៅឋានរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទាំងពីរ។ នៅឆ្នាំ២០២៣ ខេត្តសៀមរាបមានគ្រួសារសរុបប្រមាណជា២៦១.៥២៦ គ្រួសារ និងខេត្តប៉ៃលិនប្រមាណជា២០.២៨៣គ្រួសារ (ចំនួនខ្នងផ្ទះអាចស្មើឬតិចជាងនេះ ដោយសារតែមានគ្រួសារមួយចំនួនរៀបការរួចពុំទាន់មានលទ្ធភាពសាងសង់ផ្ទះសម្រាប់ស្នាក់នៅផ្ទាល់ខ្លួន ទើបទៅស្នាក់អាស្រ័យជាមួយផ្ទះឪពុកម្ដាយ ឬបងប្អូនជាដើម)។ សម្ភារៈប្រើប្រាស់សម្រាប់ធ្វើជាដំបូលផ្ទះ ក៏មានសារៈសំខាន់ផងដែរក្នុងការកំណត់នូវចរិតលក្ខណៈនៃគុណភាពរបស់លំនៅឋាន ដូចជាបេតុង ក្បឿង ហ្វីប្រូស៊ីម៉ងត៍ ស័ង្កសី ស្លឹក ជាដើម។

### ក- ប្រភេទដំបូលផ្ទះ

*តារាងទី៤ : ចំនួនខ្នងផ្ទះតាមប្រភេទដំបូល*

| ប្រភេទដំបូល | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បេតុង | ២៥.៦០៨ | ១០,២ | ៤៩៩ | ២,៧ |
| ក្បឿង | ៨២.០២៨ | ៣២,៥ | ១.៣៧៦ | ៧,៥ |
| ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ | ១៤០.៦១៤ | ៥៥,៧ | ១៦.៣៨៣ | ៨៩,២ |
| ស្លឹក | ៣.៧១២ | ១,៥ | ១០៨ | ០,៦ |
| ផ្សេងៗ | ២៨៨ | ០,១ | ០ | ០,០ |
| **សរុប** | **២៥២.២៥០** | **១០០,០** | **១៨.៣៦៦** | **១០០,០** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី៤ បានបង្ហាញពីចំនួនខ្នងផ្ទះរបស់ប្រជាពលរដ្ឋទៅតាមប្រភេទដំបូល។ យើងឃើញថាខេត្តសៀមរាបមានចំនួនខ្នងផ្ទះសរុប២៥២.២៥០ខ្នង ក្នុងនោះខ្នងផ្ទះភាគច្រើនមានដំបូលប្រក់ស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍ (១៤០.៦១៤ខ្នង ស្មើនឹង៥៥,៧%) បន្ទាប់មក គឺផ្ទះដំបូលប្រក់ក្បឿងមាន៨២.០២៨ខ្នង (៣២,៥%) ផ្ទះដំបូលបេតុងមាន២៥.៦០៨ខ្នង (១០,២%) ខណៈដែលផ្ទះដំបូលស្លឹកមាន៣.៧១២ខ្នង (១,៥%) ក្រៅពីនេះក៏នៅមានខ្នងផ្ទះមួយចំនួនទៀតដែលមានដំបូលប្រក់ពីសម្ភារៈផ្សេងៗ ដូចជាប្លាស្ទិកចំនួន២៨៨ខ្នង (០,១%) ផងដែរ។ ឯខេត្តប៉ៃលិនមានខ្នងផ្ទះសរុប១៨.៣៦៦ខ្នង ក្នុងនោះខ្នងផ្ទះដំបូលប្រក់ពីស័ង្កសី/ហ្វីប្រូស៊ីម៉ង់ត៍មានចំនួនច្រើនជាងគេ គឺ១៦.៣៨៣ខ្នង (៨៩,២%) បន្ទាប់មក គឺផ្ទះដំបូលប្រក់ក្បឿងមាន១.៣៧៦ខ្នង (៧,៥%) ផ្ទះដំបូលបេតុង៤៩៩ខ្នង (២,៧%) និងផ្ទះដំបូលស្លឹកមាន១០៨ខ្នង (០,៦%)។

## ខ- បរិក្ខារចម្បងក្នុងផ្ទះ

បរិក្ខារចម្បងសម្រាប់ប្រើប្រាស់ក្នុងផ្ទះ គឺសំដៅដល់បរិក្ខារចាំបាច់សម្រាប់ប្រើប្រាស់ក្នុងផ្ទះ ដូចជា ភ្លើងអគ្គិសនី ទូរសព្ទដៃ កុំព្យូទ័រ អ៊ីនធឺណិត ឬទូរទស្សន៍ជាដើម។

*រូបភាពទី៦ : ភាគរយនៃខ្នងផ្ទះដែលមានបរិក្ខារប្រើប្រាស់បែងចែកតាមខេត្ត*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី៦ បានបង្ហាញពីភាគរយនៃខ្នងផ្ទះដែលមានបរិក្ខារប្រើប្រាស់។ តាមរូបភាពនេះបាន បញ្ជាក់ថា ខេត្តសៀមរាប ក្នុងចំណោមខ្នងផ្ទះទាំងអស់ ខ្នងផ្ទះប្រមាណជា៩៦%មានទូរសព្ទដៃប្រើប្រាស់ ៩០%មានមានអ៊ីនធឺណិត ៩៣%មានអគ្គិសនី ៥៣%មានទូរទស្សន៍ និងប្រមាណជា២៣%មានកុំព្យូទ័រ ប្រើប្រាស់។ ខេត្តប៉ៃលិន ខ្នងផ្ទះប្រមាណជា៩៨%មានទូរសព្ទដៃប្រើប្រាស់ ៩៦%មានមានអ៊ីនធឺណិត ៨៦%មានអគ្គិសនី ៥៣%មានទូរទស្សន៍ និងខ្នងផ្ទះប្រមាណជា៣%មានកុំព្យូទ័រប្រើប្រាស់។

## ២.១.៥- បរិក្ខារកសិកម្ម ដឹកជញ្ជូន និងប្រើប្រាស់

### ក- បរិក្ខារកសិកម្ម និង នេសាទ

*តារាងទី៥ : ចំនួនគ្រួសារដែលមានបរិក្ខារកសិកម្មនិងនេសាទ*

| ប្រភេទ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | បរិក្ខារ | គ្រួសារ | បរិក្ខារ |
| ម៉ាស៊ីនភ្ជួររាស់ | ៦៣.៩២៦ | ៦៤.៧១៤ | ១.៦៨៣ | ១.៨០៥ |
| ម៉ាស៊ីនប្រមូលផល | ១.០២០ | ១.០៥២ | ១១ | ១១ |
| ឧបករណ៍កសិកម្ម (ក្រៅពីគ្រឿងម៉ាស៊ីន) | ១០៩.៤២៦ | ១១១.៧៥៦ | ៦ | ៦ |
| ទូកនេសាទ | ៦.៩៨៦ | ៧.០៨៤ | 0 | 0 |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី៥ បានបង្ហាញពីចំនួនបរិក្ខារកសិកម្មនិងនេសាទ ដែលបានកាន់កាប់តាមគ្រួសារ ក្នុងនោះ យើងឃើញថា ខេត្តសៀមរាបមានម៉ាស៊ីនភ្ជួររាស់ចំនួន៦៣.៩២៦គ្រឿង ស្មើនឹង២៤,៤% (កាន់កាប់ដោយ ៦៤.៧១៤គ្រួសារ) ម៉ាស៊ីនប្រមូលផលមាន១.០៥២គ្រឿង ស្មើនឹង0,៤% (កាន់កាប់ដោយ១.០២០គ្រួសារ) ឧបករណ៍កសិកម្មក្រៅពីគ្រឿងម៉ាស៊ីនមាន១១១.៧៥៦គ្រឿង ស្មើនឹង៤១,៨% (កាន់កាប់ដោយ ១០៩.៤២៦គ្រួសារ) និងទូកនេសាទមាន៧.០៨៤គ្រឿង ស្មើនឹង២,៧% (កាន់កាប់ដោយ៦.៩៨៦គ្រួសារ)។ ខេត្តប៉ៃលិនមានម៉ាស៊ីនភ្ជួររាស់ចំនួន១.៨០៥គ្រឿង ស្មើនឹង៨,៣% (កាន់កាប់ដោយ១.៦៨៣គ្រួសារ) ម៉ាស៊ីនប្រមូលផលចំនួន១១គ្រឿង ស្មើនឹង0,១% (កាន់កាប់ដោយ១១គ្រួសារ) និងឧបករណ៍កសិកម្មក្រៅពីគ្រឿងម៉ាស៊ីនចំនួន៦គ្រឿង (កាន់កាប់ដោយ៦គ្រួសារ)។ *ភាគរយទាំងនេះ គឺជាផលធៀបរវាងគ្រួសារដែលមានបរិក្ខារកសិកម្មនិងនេសាទ ធៀបទៅនឹងចំនួនគ្រួសារសរុបដែលមាននៅក្នុងខេត្តទាំងពីរ។*

## ខ- បរិក្ខារដឹកជញ្ជូន

*តារាងទី៦ : ចំនួនគ្រួសារដែលមានបរិក្ខារសម្រាប់ដឹកជញ្ជូន*

| ប្រភេទ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | បរិក្ខារ | គ្រួសារ | បរិក្ខារ |
| រថយន្តដឹកអ្នកដំណើរ | ២.៦៨៦ | ២.៧២៤ | ៩៧ | ១០៥ |
| រថយន្តដឹកទំនិញ | ២.២៩៤ | ២.៣៣៦ | ៤០៧ | ៤៦៧ |
| រថយន្តក្រុង | ២៨២ | ៤០៨ | ៤៨ | ៥១ |
| ម៉ូតូកង់បី | ២.៧៨២ | ២.៨១២ | ១៣០ | ១៣៨ |
| រទេះអូសដោយដៃ | ៣.៨៧០ | ៤.៥១២ | ២២៩ | ២៦៩ |
| រទេះគោ/រទេះសេះ | ២៨៨ | ២៩០ | ៥ | ៨ |
| ទូកដឹកអ្នកដំណើរ | ៨៩៤ | ១.០៤០ | ០ | ០ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី៦ បានបង្ហាញពីចំនួនបរិក្ខារសម្រាប់ដឹកជញ្ជូនដែលបានកាន់កាប់តាមគ្រួសារ ក្នុងនោះយើងឃើញថា ខេត្តសៀមរាបមានរទេះអូសដោយដៃចំនួន៤.៥១២គ្រឿង ស្មើនឹង១,៥% ដែលជាភាគរយខ្ពស់ជាងគេ (កាន់កាប់ដោយ៣.៨៧០គ្រួសារ) បន្ទាប់មក គឺម៉ូតូកង់បីមានចំនួន២.៨១២គ្រឿង ស្មើនឹង១,១% (កាន់កាប់ដោយ២.៧៨២គ្រួសារ) បន្ទាប់មកទៀត គឺរថយន្តដឹកអ្នកដំណើរមានចំនួន២.៧២៤គ្រឿង ស្មើនឹង១,០% (កាន់កាប់ដោយ២.៦៨៦គ្រួសារ) រថយន្តដឹកទំនិញមានចំនួន២.៣៣៦គ្រឿង ស្មើនឹង០,៩% (កាន់កាប់ដោយ២.២៩៤គ្រួសារ) ទូកដឹកអ្នកដំណើរមានចំនួន១.០៤០គ្រឿង ស្មើនឹង០,៣% (កាន់កាប់ដោយ៨៩៤គ្រួសារ) រថយន្តក្រុងមានចំនួន៤០៨គ្រឿង ស្មើនឹង០,១% (កាន់កាប់ដោយ២៨២គ្រួសារ) និងចុងក្រោយ គឺរទេះគោ/រទេះសេះមានចំនួន២៩០គ្រឿង ស្មើនឹង០,១% (កាន់កាប់ដោយ២៨៨គ្រួសារ)។ ភាគរយបរិក្ខារសម្រាប់ដឹកជញ្ជូនខ្ពស់ជាងគេនៅក្នុងខេត្តប៉ៃលិន គឺរថយន្តដឹកទំនិញមានចំនួន៤៦៧គ្រឿង ស្មើនឹង២,០% (កាន់កាប់ដោយ៤០៧គ្រួសារ) បន្ទាប់មក គឺរទេះអូសដោយដៃមានចំនួន២៦៩គ្រឿង ស្មើនឹង១,១% (កាន់កាប់ដោយ២២៩គ្រួសារ) និងម៉ូតូកង់បីមានចំនួន១៣៨គ្រឿង ស្មើនឹង០,៦% (កាន់កាប់ដោយ១៣០គ្រួសារ) ខណៈដែលរទេះគោ/រទេះសេះមានត្រឹមតែ៨គ្រឿង (កាន់កាប់ដោយ៨គ្រួសារ)។ *ភាគរយទាំងនេះ គឺជាផលធៀបរវាងគ្រួសារដែលមានបរិក្ខារសម្រាប់ដឹកជញ្ជូនធៀបទៅនឹងចំនួនគ្រួសារសរុបដែលមាននៅទូទាំងខេត្តទាំងពីរ។*

## គ- បរិក្ខារប្រើប្រាស់ផ្ទាល់ខ្លួន

*តារាងទី៧ : ចំនួនគ្រួសារដែលមានបរិក្ខារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន*

| ប្រភេទ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | បរិក្ខារ | គ្រួសារ | បរិក្ខារ |
| រថយន្តលក្ខណៈគ្រួសារ | ១៥.៣៣២ | ១៥.៦៤៤ | ២.៣៤៩ | ២.៤៧២ |
| ម៉ូតូ | ២០០.៣៤៦ | ២៣១.៤០៤ | ១៦.៩២៤ | ១៩.៨៦៨ |
| ទូក | ២.៥២២ | ២.៩៨០ | ៨ | ៨ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ផ្អែកតាមតារាងទី៧យើងឃើញថា ម៉ូតូមានចំនួនច្រើនលើសលប់បើធៀបទៅនឹងបរិក្ខារប្រើប្រាស់ផ្ទាល់ខ្លួនផ្សេងទៀត។ ខេត្តសៀមរាប ចំនួនម៉ូតូមានរហូតដល់៧៦,៦% (២៣១.៤០៤គ្រឿង ដែលកាន់កាប់ដោយ២០០.៣៤៦គ្រួសារ) និងខេត្តប៉ៃលិនមានចំនួន៨៣,៤% (១៩.៨៦៨គ្រឿង ដែលកាន់កាប់ដោយ១៦.៩២៤គ្រួសារ)។ ចំណែករថយន្តលក្ខណៈគ្រួសារ គឺមានចំនួន៥,៩% (១៥.៦៤៤គ្រឿង ដែលកាន់កាប់ដោយ១៥.៣៣២គ្រួសារ) ទូកមានចំនួន១,0% (២.៩៨០គ្រឿង ដែលកាន់កាប់ដោយ២.៥២២គ្រួសារ) សម្រាប់ខេត្តសៀមរាប រីឯខេត្តប៉ៃលិនវិញ រថយន្តលក្ខណៈគ្រួសារមានចំនួន១១,៦% (២.៤៧២គ្រឿង ដែលកាន់កាប់ដោយ២.៣៤៩គ្រួសារ) និងទូកមានប្រមាណជា៨គ្រឿង (កាន់កាប់ដោយ៨គ្រួសារ)។ *ភាគរយទាំងនេះ គឺជាផលធៀបរវាងគ្រួសារដែលមានបរិក្ខារសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ធៀបទៅនឹងចំនួនគ្រួសារសរុបដែលមាននៅទូទាំងខេត្តទាំងពីរ។*

## ២.២- អត្រាកំណើត និង មរណភាព

### ២.២.១- អត្រាកំណើត

*តារាងទី៨ : ចំនួននិងកន្លែងកើតរបស់ទារក*

| ទីកន្លែងកើត | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី |
| មន្ទីរពេទ្យរដ្ឋ/មណ្ឌលសុខភាព | ៧.៧៩៦ | ៨.២៤៨ | ៤០៦ | ៤៨៦ |
| មន្ទីរពេទ្យ/គ្លីនិកឯកជន | ៦២ | ៩០ | ១៣ | ១១ |
| ផ្សេងៗ | ១៨ | ៣០ | ០ | ០ |
| **សរុប** | **៧.៨៧៦** | **៨.៣៦៨** | **៤១៩** | **៤៩៧** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី៨ បានបង្ហាញនូវចំនួនទារក ដោយបែងចែកទៅតាមទីកន្លែងដែលបានកើត។ តាមតារាងនេះបានបង្ហាញឱ្យឃើញថា ខេត្តទាំងពីរ ទារកភាគច្រើនគឺកើតនៅទីតាំងផ្តល់សេវាសុខាភិបាលរបស់រដ្ឋ ដូចជាមន្ទីរពេទ្យខេត្ត មន្ទីពេទ្យបង្អែកក្រុងស្រុក មណ្ឌលសុខភាពជាដើម។ ខេត្តសៀមរាបមានទារកកើតនៅមន្ទីរពេទ្យរដ្ឋ/មណ្ឌលសុខភាពចំនួន១៦.០៤៤នាក់ (ស្រី៨.២៤៨នាក់) ដែលស្មើនឹង៩៨,៨% ចំណែកមន្ទីរពេទ្យឯកជន (មន្ទីរពេទ្យ មន្ទីរសម្រាកព្យាបាល គ្លីនិក សម្ភព ...) មានចំនួន១៥២នាក់ (ស្រី៩០នាក់) ស្មើនឹង០,៩% និងនៅកន្លែងផ្សេងទៀតមានចំនួន៤៨នាក់ (ស្រី៣០នាក់) ស្មើនឹង០,៣%។ ចំណែកឯខេត្តប៉ៃលិនវិញឃើញថា ទារកកើតនៅពេទ្យរដ្ឋ/មណ្ឌលសុខភាពមានចំនួន៨៩២នាក់ (ស្រី៤៨៦នាក់) ស្មើនឹង៩៧,៤% ខណៈដែលមន្ទីរពេទ្យ/គ្លីនិកឯកជនមានតែ២៤នាក់ (ស្រី១១នាក់) ស្មើនឹង២,៦% ប៉ុណ្ណោះ។

*រូបភាពទី៧ : ភាគរយនៃកំណើតទារក បែងចែកតាមភេទ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

បើនិយាយពីកំណើតរបស់ទារកដោយបែងចែកតាមភេទវិញឃើញថា ភាគរយនៃភេទទាំងពីរមិនសូវជាខុសគ្នាប៉ុន្មានឡើយ។ តាមរូបភាពទី៧បានបង្ហាញថា ប្រមាណជា ៤៩% គឺជាទារកភេទប្រុស និង ៥១% ជាទារកភេទស្រី ដែលបានកើតនៅក្នុងខេត្តសៀមរាប។ រីឯខេត្តប៉ៃលិនមាន៤៦% ជាទារកភេទប្រុស និង៥៤% ជាទារកភេទស្រី។

## ២.២.២- មរណភាព

ផ្នែកនេះបង្ហាញនូវទិន្នន័យមួយចំនួនទាក់ទងទៅនឹងមូលហេតុចម្បងនៃការស្លាប់ ដូចជាស្លាប់ដោយជំងឺ គ្រោះថ្នាក់ចរាចរណ៍ លង់ទឹក ពស់ចឹក ឃាតកម្មជាដើម។ ទន្ទឹមនោះ ទិន្នន័យនៃការស្លាប់តាមក្រុមអាយុ និងភេទក៏ត្រូវបានបង្ហាញផងដែរ។

### ក- មូលហេតុនៃការស្លាប់

*តារាងទី៩ : ចំនួននិងមូលហេតុនៃការស្លាប់*

| មូលហេតុស្លាប់ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ជំងឺ | ១៧៧៨ | ៨៦,៣៩ | ២៧២ | ៩១,៥៨ |
| គ្រោះថ្នាក់ចរាចរណ៍ | ១៩៦ | ៩,៥២ | ២១ | ៧,០៧ |
| លង់ទឹក | ៥៤ | ២,៦២ | ៤ | ១,៣៥ |
| អត្តឃាត | ២ | ០,១០ | ០ | ០ |
| ឃាតកម្ម | ៤ | ០,១៩ | ០ | ០ |
| ពស់ចឹក | ១៤ | ០,៦៨ | ០ | ០ |
| គ្រាប់មិនទាន់ផ្ទុះ | ១០ | ០,៤៩ | ០ | ០ |
| សរុប | ២.០៥៨ | ១០០,០០ | ២៩៧ | ១០០,០០ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី៩ គឺជាចំនួននិងមូលហេតុនៃការស្លាប់ក្នុងរយៈពេល១២ខែចុងក្រោយ។ នៅក្នុងឆ្នាំ២០២៣នេះ ខេត្តសៀមរាបមានអ្នកស្លាប់សរុបចំនួន២.០៥៨នាក់ ក្នុងនោះអ្នកស្លាប់ដោយសារជំងឺមានចំនួនច្រើនជាងគេ គឺ១.៧៧៨នាក់ (៨៦,៣៩%) បន្ទាប់មក គឺអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ក៏មានចំនួនគួរឱ្យកត់សម្គាល់ផងដែរ ដែលមានចំនួន១៩៦នាក់ (៩,៥២%) អ្នកស្លាប់ដោយលង់ទឹកមានចំនួន៥៤នាក់ (២,៦២%) អ្នកស្លាប់ដោយសារពស់ចឹកមាន១៤នាក់ (០,៦៨%) អ្នកស្លាប់ដោយសារគ្រាប់មិនទាន់ផ្ទុះមាន១០នាក់ (០,៤៩%) ចំណែកឯអ្នកស្លាប់ដោយសារឃាតកម្មមាន៤នាក់ (០,១៩%) និងអ្នកស្លាប់ដោយសារអត្តឃាតមានចំនួនតិចជាង គឺ២នាក់ (០,១០%)។ ខេត្តប៉ៃលិន មានអ្នកស្លាប់សរុប២៩៧នាក់ ក្នុងនោះអ្នកស្លាប់ដោយសារជំងឺមានចំនួន២៧២នាក់ (៩១,៥៨%) ខណៈដែលអ្នកស្លាប់

ដោយសារគ្រោះថ្នាក់ចរាចរណ៍មានចំនួន២១នាក់ (៧,០៧%) និងអ្នកស្លាប់ដោយសារលង់ទឹកមានចំនួន៤នាក់ (១,៣៥%)។

### ខ- អាយុនៃអ្នកស្លាប់




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី៨ គឺជាចំនួនអ្នកស្លាប់ដោយបែងចែកទៅតាមក្រុមអាយុ។ រូបភាពខាងលើនេះបានបញ្ជាក់យ៉ាងច្បាស់ថា ចំនួនអ្នកស្លាប់ភាគច្រើនគឺស្ថិតនៅអាយុចន្លោះពី១៨-៦៤ឆ្នាំ សម្រាប់ខេត្តសៀមរាប និងអាយុ៦៥ឆ្នាំឡើងសម្រាប់ខេត្តប៉ៃលិន។ ជាទូទៅ នៅក្នុងខេត្តសៀមរាបមានមនុស្សប្រុសស្លាប់ច្រើនជាងមនុស្សស្រី។ មនុស្សដែលស្ថិតក្នុងអាយុចន្លោះពី១៨-៦៤ឆ្នាំ មានចំនួនច្រើនជាងគេ គឺ១.១៤២នាក់ (ស្រី៤៨៤នាក់) បន្ទាប់មក គឺមនុស្សវ័យចាស់ដែលមានអាយុចាប់ពី៦៥ឆ្នាំឡើង មានចំនួន៧២៨នាក់ (ស្រី៣៥៤នាក់) និងអាយុចន្លោះពី៥-១៧ឆ្នាំ មានចំនួន១៤៦នាក់ (ស្រី៥៦នាក់) ខណៈដែលក្រុមអាយុកុមារតិចជាង៥ឆ្នាំ មានចំនួន៤២នាក់ (ស្រី៨នាក់)។ ខេត្តប៉ៃលិនក៏មិនខុសគ្នាពីខេត្តសៀមរាបដែរ អ្នកស្លាប់ភេទប្រុសគឺមានចំនួនច្រើនជាងអ្នកស្លាប់ភេទស្រី (លើកលែងតែកុមារអាយុក្រោម៥ឆ្នាំ ដែលអ្នកស្លាប់ភេទប្រុសតិចជាងអ្នកស្លាប់ភេទស្រី)។ ខេត្តនេះ អ្នកស្លាប់ច្រើនជាងគេគឺនៅអាយុ៦៥ឆ្នាំ (១៩០នាក់ ស្រី៦៥នាក់) បន្ទាប់មក គឺអាយុចន្លោះពី១៨-៦៤ឆ្នាំ (៨៧នាក់ ស្រី៤១នាក់) អាយុពី៥-១៧ឆ្នាំ (១៥នាក់ ស្រី៥នាក់) និងតិចជាងគេគឺនៅអាយុក្រោម៥ឆ្នាំ (៦នាក់ ស្រី៥នាក់)។




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី៩ គឺជាភាគរយនៃអ្នកស្លាប់ដោយបែងចែកតាមក្រុមអាយុ។ តាមរូបនេះបង្ហាញថា ខេត្តសៀមរាប មនុស្សដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី១៨-៦៤ មានអត្រាស្លាប់ច្រើនជាងគេ (៥៥%) បន្ទាប់មកគឺក្រុមអាយុ៦៥ឆ្នាំឡើង (៣៥%) ក្រុមអាយុ៥-១៧ឆ្នាំ (៧%) និងចុងក្រោយគឺក្រុមអាយុក្រោម៥ឆ្នាំ (២%)។ ខេត្តប៉ៃលិន មនុស្សដែលស្ថិតនៅក្នុងក្រុមអាយុចាប់ពី៦៥ឆ្នាំឡើង មានអត្រាស្លាប់ច្រើនជាងគេ (៦៤%) បន្ទាប់មកគឺក្រុមអាយុ ១៨-៦៤ឆ្នាំ (២៩%) ក្រុមអាយុ ៥-១៧ឆ្នាំ (៥%) និងក្រុមអាយុតិចជាង ៥ឆ្នាំមាន ២% ដែលជាចំនួនតិចជាងគេបើធៀបទៅនឹងភាគរយនៃអ្នកស្លាប់ក្នុងក្រុមអាយុទាំងបួន។

## ២.៣- ពិការភាព និង បុគ្គលគ្មានអ្នកថែទាំ

ជនមានពិការភាព ត្រូវបានឱ្យនិយមន័យថា គឺជាឧបសគ្គ ឬជាកង្វះផ្នែកសមត្ថភាពណាមួយ ក្នុងការអនុវត្តសកម្មភាព ឬនៅក្នុងកម្រិតមួយដែលមនុស្សធម្មតាអាចធ្វើបាន។

*តារាងទី១០ : ចំនួនបុគ្គលមានពិការភាពនិងមនុស្សគ្មានអ្នកថែទាំ*

| បរិយាយ | សៀមរាប | | | ប៉ៃលិន | | |
|---|---|---|---|---|---|---|
| | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| ពិការភាព (ក្រោម១៨ឆ្នាំ) | ១.៣១២ | ៧៦២ | ៥៥០ | ៩៦ | ៤៧ | ៤៩ |
| ពិការភាព (អាចរកប្រាក់ចំណូលបាន) | ៣.០៥២ | ២.១៩២ | ៨៦០ | ១.០៤០ | ៨២៤ | ២១៦ |
| ពិការភាព (មិនអាចរកប្រាក់ចំណូលបាន) | ២.៣១៨ | ១.៤៤០ | ៨៧៨ | ៤២២ | ២៧៥ | ១៤៧ |
| ពិការភាព (ដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ) | ៨៧៦ | ៧៤០ | ១៣៦ | ១៥ | ១០ | ៥ |
| មនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ | ៤៤៨ | ១៣៨ | ៣១០ | ៦២ | ២៦ | ៣៦ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១០ បានបង្ហាញពីចំនួនបុគ្គលមានពិការភាពនិងមនុស្សគ្មានអ្នកថែទាំ។ នៅក្នុងខេត្តសៀមរាបមានបុគ្គលពិការភាពអាយុក្រោម១៨ឆ្នាំ ចំនួន១.៣១២នាក់ (ស្រី៨៥០នាក់ ស្មើនឹង៤២%) ពិការភាពអាចរកប្រាក់ចំណូលបាន ដូចជាជាងជួសជុលកង់ម៉ូតូ ជាងកាត់សក់ អ៊ុតសក់ ... មានចំនួន៣.០៥២នាក់ (ស្រី៩៦០នាក់ ស្មើនឹង២៨%) ពិការភាពមិនអាចរកប្រាក់ចំណូលបានមានចំនួន២.៣១៨នាក់ (ស្រី៨៧៨នាក់ ស្មើនឹង៣៨%) ពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះមានចំនួន៨៧៦នាក់ (ស្រី១៣៦នាក់ ស្មើនឹង១៦%) និងមនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ចំនួន៤៤៨នាក់ (ស្រី១៣៦នាក់ ស្មើនឹង៦៩%)។ ចំណែកខេត្តប៉ៃលិន មានបុគ្គលពិការភាពអាយុក្រោម១៨ឆ្នាំ ចំនួន៩៦នាក់ (ស្រី៤៩នាក់ ស្មើនឹង៥១%) ពិការភាពអាចរកប្រាក់ចំណូលបានមានចំនួន១.០៤០នាក់ (ស្រី១១៦នាក់ ស្មើនឹង២១%) ពិការភាពមិនអាចរកប្រាក់ចំណូលបានមានចំនួន៤២២នាក់ (ស្រី១៤៧នាក់ ស្មើនឹង៣៥%) ពិការភាពដោយសារគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះមានចំនួន១៥នាក់ (ស្រី៥នាក់ ស្មើនឹង៣៣%) និងមនុស្សចាស់គ្មានអ្នកថែទាំ/ផ្គត់ផ្គង់ចំនួន៦២នាក់ (ស្រី៣៦នាក់ ស្មើនឹង៥៨%)។

## ២.៤- ការលែងលះ

**ការលែងលះ** គឺជាការរំលាយចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ក្នុងពេលរស់នៅទាំងពីរនាក់។ អានុភាពនៃការលែងលះ គឺនាំឱ្យផ្តាច់ទំនាក់ទំនងទាំងស្រុងតាមផ្លូវច្បាប់នៃភាពជាប្តីប្រពន្ធ លែងមានទ្រព្យរួមប្តីប្រពន្ធ និងការបែងចែកកំណត់អ្នកដែលមានសិទ្ធិអំណាចមេបាចំពោះកូនក្នុងបន្ទុក (កូនជាអនីតិជនអាយុក្រោម១៨ឆ្នាំ)។ ការលែងលះ មានពីរវិធី គឺការលែងលះដោយការព្រមព្រៀង ហើយមានដីកាសម្រេចលែងលះចេញពីតុលាការ និងការលែងលះតាមរយៈការធ្វើបណ្តឹងទាមទារការលែងលះ ដោយមានសាលក្រម ឬសាលដីការបស់តុលាការ។

*តារាងទី១១ : ចំនួនអ្នកលែងលះ បែងចែកតាមមុខរបរនៃមេគ្រួសារ*

| មុខរបរមេគ្រួសារ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ពលករ/កម្មករ | ១.៧០៤ | ៣២,៥៨ | ៣៦ | ៤៣,៣៧ |
| កសិកម្ម | ១.៤៧៤ | ២៨,១៨ | ៤៤ | ៥៣,០១ |
| អ្នកជំនួញ | ៨៣៦ | ១៥,៩៨ | ១ | ១,២០ |
| អ្នកមានវិជ្ជាជីវៈ | ៣៩៤ | ៧,៥៣ | ០ | ០,០០ |
| មន្ត្រីរាជការ | ២២២ | ៤,២៤ | ២ | ២,៤១ |
| អ្នកនយោបាយ | ១៩៦ | ៣,៧៥ | ០ | ០,០០ |
| ផ្សេងៗ | ៤០៤ | ៧,៧២ | ០ | ០,០០ |
| **សរុប** | **៥.២៣០** | **១០០,០០** | **៨៣** | **១០០,០០** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងខាងលើ (តារាងទី១១) បានបង្ហាញពីចំនួនអ្នកលែងលះគ្នាដោយបែងចែកតាមមុខរបរនៃមេគ្រួសារ (មុខរបរមេគ្រួសារនូវមុនពេលលែងលះគ្នា)។ យើងឃើញថា ក្នុងឆ្នាំ២០២៣ ខេត្តសៀមរាបមានអ្នកលែងលះគ្នាសរុបប្រមាណ៣.៥៣០គ្រួសារ ក្នុងនោះពលករ/កម្មករមានចំនួនខ្ពស់ជាងគេ គឺ ១.៧០៤គ្រួសារ (៣២,៥៨%) បន្ទាប់មក គឺអ្នកធ្វើកសិកម្ម ចំនួន១.៤៧៤គ្រួសារ (២៨,១៨%) អ្នកជំនួញ៨៣៦គ្រួសារ (១៥,៩៨%) និងតិចជាងគេ គឺអ្នកនយោបាយ មានចំនួន១៩៦គ្រួសារ (៣,៧៥%)។ ខេត្តប៉ៃលិនមានចំនួនអ្នកលែងលះគ្នាប្រមាណជា៨៣គ្រួសារ ក្នុងនោះភាគច្រើនជាអ្នកធ្វើកសិកម្ម ដែលមានប្រមាណជា៤៤គ្រួសារ (ស្មើនឹង៥៣,០១%) បើធៀបទៅនឹងចំនួនអ្នកលែងលះគ្នាសរុបទាំងអស់។

## ២.៥- ការប្រើប្រាស់ទឹក និង បង្គន់អនាម័យ

ទឹក គឺជាវត្ថុធាតុធម្មជាតិមួយប្រភេទនៅលើផែនដី។ វាមាន ៧១,៤% នៃផ្ទៃផែនដីគ្របដណ្តប់ទៅដោយទឹក។ ទឹកស្អាតដែលសព្វថ្ងៃគេនិយមហៅថា ទឹកបរិសុទ្ធ ពុំមានក្លិន រសជាតិ និងពណ៌ទេ។ ឈ្មោះនៃទឹក ត្រូវបានគេហៅតាមទីកន្លែងរបស់វា ដូចជាទឹកបឹង ទឹកទន្លេ ទឹកសមុទ្រ ឬទឹកភ្លៀងជាដើម។

### ក- ប្រភពទឹកប្រើប្រាស់

*តារាងទី១២ : ប្រភពទឹកចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ*

| ប្រភពទឹក | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ទឹកភ្លៀង | ៥.៩៦៨ | ២,២៨ | ២.៧៦៥ | ១៣,៦៣ |
| ទឹកបរិសុទ្ធ | ៦.១០៨ | ២,៣៤ | ៣.៣៩៨ | ១៦,៧៥ |
| ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ | ២១.៦៦៨ | ៨,២៩ | ៣.៨៤០ | ១៨,៩៣ |
| ទឹកស្អាត (ទុយោ) | ៣៧.២៧៨ | ១៤,២៥ | ៤.០០៤ | ១៩,៧៤ |
| ទឹកអណ្តូង | ១៩០.៥០៤ | ៧២,៨៤ | ៦.២៧៦ | ៣០,៩៤ |
| **សរុប** | **២៦១.៥២៦** | **១០០,០០** | **២០.២៨៣** | **១០០,០០** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១២ បង្ហាញពីប្រភពទឹកចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ខេត្តសៀមរាប ប្រមាណ ៧២,៨៤% (១៩០.៥០៤គ្រួសារ) នៃគ្រួសារសរុបបានប្រើប្រាស់ទឹកអណ្តូង បន្ទាប់មក គឺទឹកស្អាត(ទឹកទុយោ) មាន១៤,២៥% (៣៧.២៧៨គ្រួសារ) ទឹកទឹកស្រះ/បឹង/ស្ទឹង/ទន្លេមាន៨,២៩% (២១.៦៦៨គ្រួសារ) ទឹកបរិសុទ្ធមាន២,៣៤% (៦.១០៨គ្រួសារ) ខណៈដែលចំនួនអ្នកប្រើប្រាស់ទឹកភ្លៀងមាន ២,២៨% (៥.៩៦៨គ្រួសារ) ដែលជាចំនួនតិចជាងគេ បើធៀបទៅនឹងប្រភពចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារទាំងអស់។ ចំណែកខេត្តប៉ៃលិនវិញ គ្រួសារភាគច្រើនគឺប្រើប្រាស់ទឹកអណ្តូង ដែលមានប្រមាណ៣០,៩៤% (៦.២៧៦គ្រួសារ) ខណៈដែលគ្រួសារប្រើប្រាស់ទឹកស្អាត/ទុយោមានចំនួន១៩,៧៤% (៤.០០៤គ្រួសារ) ប្រើប្រាស់ទឹកស្រះ/បឹង/ស្ទឹង/ទន្លេមាន១៨.៩៣% (៣.៨៤០គ្រួសារ) ទឹកបរិសុទ្ធមានចំនួន១៦,៧៥% (៣.៣៩៨គ្រួសារ) ហើយក៏មានគ្រួសារមួយចំនួនតូច (២.៧៦៥គ្រួសារ ស្មើនឹង១៣,៦៣%) បានយកទឹកភ្លៀងមកប្រើប្រាស់ជាប្រចាំថ្ងៃផងដែរ។

### ខ- ប្រភពទឹកទទួលទាន

*តារាងទី១៣ : ប្រភពទឹកចម្បងសម្រាប់ទទួលទានក្នុងគ្រួសារ*

| ប្រភពទឹក | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ទឹកភ្លៀង | ២.៥១០ | ០,៩៦ | ២.៣៧២ | ១១,៦៩ |
| ទឹកបរិសុទ្ធ | ១០៤.៨៣២ | ៤០,០៨ | ៩.៥៥៦ | ៤៧,១១ |
| ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ | ៨.២១៨ | ៣,១៤ | ១.៤៨៩ | ៧,៣៤ |
| ទឹកស្អាត (ទុយោ) | ១២.៩៩៤ | ៤,៩៧ | ៣.១៧៤ | ១៥,៦៥ |
| ទឹកអណ្ដូង | ១៣២.៩៧២ | ៥០,៨៤ | ៣.៦៩២ | ១៨,២០ |
| **សរុប** | **២៦១.៥២៦** | **១០០,០០** | **២០.២៨៣** | **១០០,០០** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១៣ បង្ហាញពីប្រភពទឹកចម្បងសម្រាប់ទទួលទានក្នុងគ្រួសារ។ ខេត្តសៀមរាប ប្រមាណ ៥០,៨៤% (១៣២.៩៧២គ្រួសារ) នៃគ្រួសារសរុបបានទទួលទានទឹកអណ្ដូង បន្ទាប់មកគឺ ទឹកបរិសុទ្ធ មាន៤០,០៨% (១០៤,៨៣២គ្រួសារ) ខណៈដែល ៩,៧% (២៣.៧២២គ្រួសារ) ទៀតបានទទួលទានទឹកស្រះ/បឹង/ស្ទឹង/ទន្លេ ទឹកភ្លៀង និងទឹកស្អាត(ទឹកទុយោ)។ ខេត្តប៉ៃលិន គ្រួសារប្រមាណ៤៧,១១% (៩.៥៥៦គគ្រួសារ) បានយកទឹកបរិសុទ្ធមកទទួលទាន ១៨,២០% (៣.៦៩២គ្រួសារ) ទទួលទានទឹកអណ្ដូងមាន ខណៈដែល៦.៧៣៥គ្រួសារ (៣៧,២៣%) ទៀតបានយកទឹកស្រះ/បឹង/ស្ទឹង/ទន្លេ ទឹកភ្លៀង និងទឹកស្អាត (ទឹកទុយោ) មកទទួលទានជាប្រចាំថ្ងៃ។

### គ- បង្គន់អនាម័យ

អនាម័យ គឺជាកត្តាសំខាន់សម្រាប់សុខភាព។ ការប្រើប្រាស់នូវបង្គន់អនាម័យបានត្រឹមត្រូវ វាគឺជាផ្នែកមួយក្នុងការជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ សហគមន៍ និងសង្គមជាតិ តាមរយៈការកាត់បន្ថយជំងឺនានា ជាពិសេសគឺជំងឺរាគរូស។ តាមលទ្ធផលជំរឿនឆ្នាំ២០១៩ ការប្រើប្រាស់បង្គន់អនាម័យនៅកម្ពុជាមាន ៨២,៨% គឺមានការរីកចម្រើនជាខ្លាំងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។

*តារាងទី១៤ : ការប្រើប្រាស់បង្គន់អនាម័យសម្រាប់បន្ទោបង់តាមគ្រួសារ*

| ការបន្ទោបង់ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| បង្គន់អនាម័យផ្ទាល់ខ្លួន | ២៣៥.៩០៦ | ៩០,២០ | ១៩.៤០៩ | ៩៥,៦៩ |
| បង្គន់អនាម័យអ្នកជិតខាង | ២១.២៩៤ | ៨,១៤ | ៦៣១ | ៣,១១ |
| បន្ទោបង់ពាសវាល | ៤.៣២៦ | ១,៦៥ | ២៤៣ | ១,២០ |
| **សរុប** | **២៦១.៥២៦** | **១០០,០០** | **២០.២៨៣** | **១០០,០០** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១៤ គឺជាចំនួននៃការប្រើប្រាស់បង្គន់អនាម័យសម្រាប់បន្ទោបង់តាមគ្រួសារ។ យើងឃើញថា ខេត្តសៀមរាប គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួនមានចំនួន២៣៥.៩០៦គ្រួសារ (៩០,២០%) គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យអ្នកជិតខាង (បង្គន់ ឪពុកម្ដាយ បងប្អូន អ្នកជិតខាង វត្តអារាម សាលារៀន ... ) មានចំនួន២១.២៩៤គ្រួសារ (៨,១៤%) ខណៈដែលប្រជាពលរដ្ឋ៤.៣២៦ គ្រួសារ (១,៦៥%) ទៀតនៅមិនទាន់មានបង្គន់អនាម័យសម្រាប់បន្ទោបង់នៅឡើយ (បន្ទោបង់ពាសវាល ពាសកាល)។ ខេត្តប៉ៃលិន គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួនមានចំនួន១៩.៤០៩គ្រួសារ (៩៥,៦៩%) គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យអ្នកជិតខាងមានចំនួន៦៣១គ្រួសារ (៣,១១%) ខណៈដែលប្រជាពលរដ្ឋ២៤៣គ្រួសារ (១,២០%) ទៀត គឺនៅបន្ទោបង់ពាសវាលពាសកាលនៅឡើយ។ ដូច្នោះអជ្ញាធរដែលពាក់ព័ន្ធ និងអជ្ញាធរមូលដ្ឋានគួរតែខិតខំជំរុញបន្ថែមទៀតទៅគ្រួសារដែលមិនទាន់មានបង្គន់អនាម័យប្រើប្រាស់ផ្ទាល់ខ្លួន ជាពិសេសគ្រួសារដែលបន្ទោបង់ពាសវាលពាសកាល។

## ឃ- គ្រួសារគ្មានផ្ទះសំបែង

*រូបភាពទី១០ : ចំនួនគ្រួសារគ្មានផ្ទះសំបែងនិងរស់នៅលើដីសាធារណៈ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ប្រជាជនគ្មានផ្ទះសំបែង និងគ្មានដីធ្លី ក៏ជាបញ្ហាប្រឈមមួយក្នុងការអភិវឌ្ឍប្រទេសជាតិផងដែរ។ រូបភាពទី១០បានបង្ហាញថា នៅក្នុងខេត្តសៀមរាបមានប្រជាជនរស់នៅលើដីសាធារណៈចំនួន៤.៤០២គ្រួសារ (៨៩,១១%) ខណៈដែល៥៣៨គ្រួសារ (១០,៨៩%) ទៀតកំពុងគ្មានផ្ទះសំបែងសម្រាប់ស្នាក់នៅនៅ (ស្នាក់នៅក្រោមស្ពាន វត្តអារាម ឬទីសាធារណៈនានា)។ រីឯខេត្តប៉ៃលិន មានប្រជាជនរស់នៅលើដីសាធារណៈចំនួន៤៦៧គ្រួសារ (៩៦,០៩%) ខណៈដែល១៩គ្រួសារ (៣,៩១%) ទៀតបានស្នាក់នៅក្រោមស្ពាន វត្តអារាម ឬទីសាធារណៈនានាជាដើម។

## ២.៦- បរិស្ថាន និង ធនធានធម្មជាតិ

### ក- គ្រោះធម្មជាតិ

នៅប្រទេសកម្ពុជា ខ្យល់ព្យុះ ទឹកជំនន់ និងរន្ទះបាញ់ គឺជាគ្រោះមហន្តរាយធម្មជាតិចម្បងដែលធ្វើឱ្យបាត់បង់ជីវិតមនុស្សសត្វ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ខណៈដែលគ្រោះរាំងស្ងួត ការបាក់ដី/ស្រុតដីចូលទន្លេ ព្រៃក ឬស្ទឹង បានបង្កឱ្យមានទុក្ខវេទនាយ៉ាងខ្លាំងដល់ប្រជាជន ជាពិសេសចំពោះប្រជាកសិករ។ ការផ្លាស់ប្តូរអាកាសធាតុនឹងធ្វើឱ្យស្ថានភាពនេះកាន់តែលំបាក ដោយរដូវប្រាំងមានអាកាសធាតុកាន់តែក្តៅហួតហែង ឯរដូវវស្សាមានភ្លៀងធ្លាក់ជោគជាំ និងខ្យល់ព្យុះកាន់តែខ្លាំង។

*តារាងទី១៥ : គ្រួសារនិងផ្ទៃដីរងផលប៉ះពាល់ដោយសារគ្រោះធម្មជាតិ*

| គ្រោះធម្មជាតិ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | ផ្ទៃដី (ហិកតា) | គ្រួសារ | ផ្ទៃដី (ហិកតា) |
| ទឹកជំនន់ | ៦.៩៥២ | ១៣.៣៨៤ | ៣២៧ | ៩៨៨ |
| បាក់/ស្រុតដី | ៤០ | ៤ | ០ | ០ |
| គ្រោះរាំងស្ងួត | ២.២៥៤ | ១៥.១០៦ | ២៦ | ៤៨ |
| ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ | ៥១២ | ១១៣ | ៤១ | ៥៨ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១៥ គឺជាផលប៉ះពាល់ដែលបណ្តាលមកពីគ្រោះធម្មជាតិ។ តារាងនេះបានបង្ហាញថា ខេត្តសៀមរាប គ្រោះទឹកជំនន់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន១៣.៣៨៤ហិកតា (៦.៩៥២គ្រួសារ) គ្រោះរាំងស្ងួតប៉ះពាល់ដល់ផ្ទៃដីដាំដុះចំនួន១៥.១០៦ហិកតា (២.២៥៤គ្រួសារ) ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ ប៉ះពាល់ដល់ផ្ទៃដីចំនួន១១៣ហិកតា (៥១២គ្រួសារ) ចំណែកការបាក់ដី/ស្រុតដីក៏បានរងផលប៉ះពាល់ផ្ទៃដីចំនួន៤ហិកតា (៤០គ្រួសារ) ផងដែរ។ ខេត្តប៉ៃលិន គ្រោះទឹកជំនន់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន៩៨៨ហិកតា (៣២៧គ្រួសារ) គ្រោះរាំងស្ងួតប៉ះពាល់ដល់ផ្ទៃដីដាំដុះចំនួន៤៨ហិកតា (២៦គ្រួសារ) និងខ្យល់ព្យុះ/ខ្យល់កន្ត្រាក់បានបង្កឱ្យមានផលប៉ះពាល់ដល់ផ្ទៃដីចំនួន៥៨ហិកតា (៤១គ្រួសារ) ផងដែរ។

## ខ- ការគ្រប់គ្រងកាកសំណល់

ការគ្រប់គ្រងកាកសំណល់នៅប្រទេសកម្ពុជា គឺជាបញ្ហាសំខាន់មួយដែលត្រូវការការយកចិត្តទុកដាក់ដើម្បីការពារបរិស្ថាន និងសុខភាពសាធារណៈ។ កំណើនប្រជាជន សកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច បាន និងកំពុងបង្កផលវិបាកដល់បរិស្ថាន មនុស្ស និងសត្វផងដែរ។

*តារាងទី១៦ : ការគ្រប់គ្រងកាកសំណល់តាមគ្រួសារ*

| ទីតាំង | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រើប្រាស់សេវាប្រមូលសំរាម | ៣៥.៥៩៦ | ១៣,៦ | ២.៣៣៦ | ១១,៥ |
| គ្រប់គ្រងសំរាមដោយខ្លួនឯង (ដុត/កប់ចោល) | ១៩៤.២៦០ | ៧៤,៣ | ១៧.៨២៤ | ៨៧,៩ |
| មិនបានគ្រប់គ្រងសំរាម (មិនបានទុកដាក់ត្រឹមត្រូវ) | ៣១.៦៧០ | ១២,១ | ១២៣ | ០,៦ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

នៅខេត្តសៀមរាប មានប្រមាណជា១៩៤.២៦០គ្រួសារ (៧៤,៣%) បានគ្រប់គ្រងសំរាមដោយខ្លួនឯង (ដុត/កប់ចោល) ខណៈដែល៣៥.៥៩៦គ្រួសារ (១៣,៦%) បានប្រើប្រាស់សេវាប្រមូលសំរាម និង៣១.៦៧០គ្រួសារ (១២,១%) នៅមិនទាន់បានទុកដាក់សំរាមឱ្យបានត្រឹមត្រូវនៅឡើយ (ចោលពាសវាស)។ ខេត្តប៉ៃលិន មាន១៧.៨២៤គ្រួសារ (៨៧,៩%) បានគ្រប់គ្រងសំរាមដោយខ្លួនឯង (ដុត/កប់ចោល) ខណៈដែល២.៣៣៦គ្រួសារ (១១,៥%) បានប្រើប្រាស់សេវាប្រមូលសំរាម និងមានតែ១២៣គ្រួសារ (០,៦%) ប៉ុណ្ណោះដែលមិនបានទុកដាក់សំរាមឱ្យបានត្រឹមត្រូវ (ចោលពាសវាស)។ (មើលតារាងទី១៦)។

## គ- ថាមពលចម្អិនអាហារ

*រូបភាពទី១១ : ភាគរយនៃប្រភពថាមពលចម្បងសម្រាប់ចម្អិនអាហារតាមគ្រួសារ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ការចម្អិនអាហារ គឺជាតម្រូវការចាំបាច់និងមិនអាចខ្វះបានសម្រាប់ជីវិតរស់នៅរបស់មនុស្ស។ តាមរូបភាពទី១១បានបង្ហាញថា នៅក្នុងខេត្តសៀមរាបប្រជាជនប្រមាណជា៧១,៩៥% បានប្រើប្រាស់អុស/ធ្យូងសម្រាប់ចម្អិនម្ហូបអាហារ ខណៈដែលការប្រើហ្គាសមាន២៧,៩៩% និងឡជីវឧស្ម័នមាន ០,៦១%។ ខេត្តប៉ៃលិន ប្រជាជនប្រើប្រាស់អុស/ធ្យូងមាន៣៣,៩៧% ហ្គាសមាន ៦៥,៩៨% និងឡជីវឧស្ម័នមាន០,០៥%។

## ឃ- ព្រៃឈើ

*រូបភាពទី១២ : ចំនួនផ្ទៃដីព្រៃឈើ ដាំកូនឈើ និងការកាប់ឆ្ការព្រៃ (គិតជាហិកតា)*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១២បានបង្ហាញថា ខេត្តសៀមរាបមានផ្ទៃដីព្រៃឈើគ្របដណ្តប់ចំនួន១២.២៨៦ហិកតា និងផ្ទៃដីដាំកូនឈើមានចំនួន២៨ហិកតា។ ខេត្តប៉ៃលិនមានផ្ទៃដីព្រៃឈើគ្របដណ្តប់ចំនួន១០.០៩៦ ហិកតា និងផ្ទៃដីដាំកូនឈើចំនួន១.៥៨២ហិកតា។ ទន្ទឹមនោះ ក៏មាននូវការកាប់ឆ្ការទន្រ្ទានព្រៃឈើយកដីធ្វើកសិកម្ម និងជាកម្មសិទ្ធិផ្ទាល់ខ្លួនផងដែរ (ខេត្តសៀមរាបមានចំនួន២.៨៦៦ហិកតា និងខេត្តប៉ៃលិនមានចំនួន១៨៦ហិកតា)។

# ២.៧- សន្តិសុខសង្គម និង សេដ្ឋកិច្ច

## ២.៧.១- សន្តិសុខសង្គម

**អសន្តិសុខសង្គម** សំដៅដល់ការលួច឴ឆក់ ប្លន់ ចាប់ជម្រិត ឃាតកម្ម ឧក្រិដ្ឋកម្ម ការប្រើប្រាស់គ្រឿងញៀន និងជម្លោះដីធ្លីនៅក្នុងមូលដ្ឋានជាដើម។ ចំពោះករណីទាំងអស់នេះ ទោះបីជាមានចំនួនកើតឡើងច្រើនយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាលនិងអាជ្ញាធរខេត្តខេត្តសៀមរាបនិងខេត្តប៉ៃលិន បានខិតខំដោះស្រាយបានមួយចំនួនធំផងដែរ។

### ក- អសន្តិសុខសង្គម




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៣ បានបង្ហាញពីបញ្ហាអសន្តិសុខនិងដំណោះស្រាយ។ រូបភាពនេះបានបង្ហាញថា ក្នុងចំណោមករណីអសន្តិសុខដែលកើតមាននៅក្នុងខេត្តសៀមរាប ជម្លោះដីធ្លីមាន៩៤៦ករណី ដោះស្រាយបាន៥៩៤ករណី បញ្ហាប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នា៧៥៤ករណី ដោះស្រាយបាន៦១០ករណី ចោរលួច

មាន២៤២ករណី ដោះស្រាយបាន១២៦ករណី ឃាតកម្ម/ឧក្រិដ្ឋកម្មមានចំនួន៥៨ករណី ដោះស្រាយបានតែ៤៨ករណី ខណៈដែលបញ្ហាប្លន់/ចាប់ជម្រិតមាន១៨ករណី ដោះស្រាយបាន១២ករណី។ រីឯខេត្តប៉ៃលិនវិញ បញ្ហាប្រជាពលរដ្ឋឈ្លោះទាស់ទែងគ្នាមាន១៧៥ករណី ដោះស្រាយបាន១៧៤ករណី ចំពោះបញ្ហាជម្លោះដីធ្លីបានកើតឡើង៥៧ករណី ដោះស្រាយបានចំនួន៥៤ករណី ករណីលួចមាន១៣៦ករណី ដោះស្រាយបាន១៣៤ករណី បញ្ហាប្លន់/ចាប់ជម្រិតមានចំនួន១១ករណី ដោះស្រាយបាន២ករណី និងករណីឃាតកម្ម/ឧក្រិដ្ឋកម្មមាន៦ករណី ដោះស្រាយបានទាំងអស់។

## ខ- អំពើហិង្សាក្នុងគ្រួសារនិងគ្រឿងញៀន

*រូបភាពទី១៤ : ករណីអំពើហិង្សាក្នុងគ្រួសារនិងការប្រើប្រាស់គ្រឿងញៀន*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៤បានបង្ហាញថា ក្នុងចំណោមគ្រួសារសរុប (២៦១.៥២៦គ្រួសារ) ដែលរស់នៅខេត្តសៀមរាប គឺមាន១.០២៤គ្រួសារ (0,៤%) បានទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ និង ៨៣២គ្រួសារ (0,៣%) មានសមាជិកកំពុងប្រើប្រាស់គ្រឿងញៀន។ ខេត្តប៉ៃលិន ក្នុងចំណោមគ្រួសារសរុប (២០.២៨៣គ្រួសារ) គឺមាន៧១គ្រួសារ (0,៤%) បានទទួលរងនូវអំពើហិង្សាក្នុងគ្រួសារ និង ២៥៦គ្រួសារ (១,៣%) មានសមាជិកកំពុងប្រើប្រាស់គ្រឿងញៀន។

### គ- ស្ត្រីរងគ្រោះដោយការចាប់រំលោភ




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៥បានបង្ហាញថា ខេត្តសៀមរាបមានស្ត្រីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទចំនួន៣០ករណី ក្នុងនោះភាគច្រើនគឺជាស្ត្រីដែលមានអាយុតិចជាង១៨ឆ្នាំ (២៤ករណី) ដោយឡែក ខេត្តប៉ៃលិនមានស្ត្រីរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទចំនួន២ករណី (អាយុតិចជាង១៨ឆ្នាំ មាន១ករណី និង ១៨ឆ្នាំឡើង មាន១ករណី)។

## ២.៧.២- សេដ្ឋកិច្ចគ្រួសារ

នៅក្នុងប្រទេសកម្ពុជា មានសកម្មភាពអាជីវកម្មជាច្រើនដែលប្រជាជនធ្វើសកម្មភាពដើម្បីរកស៊ីចិញ្ចឹមជីវិត និងផ្គត់ផ្គង់គ្រួសារ (ដោយមិនរាប់ចូលសកម្មភាពកសិកម្មនិងមុខរបរអាជីព ដូចជាគ្រូពេទ្យ គ្រូបង្រៀន ប៉ូលីស ទាហានជាដើម)។ ក្នុងចំណោមសកម្មភាពអាជីវកម្មទាំងអស់នោះ យើងបានជ្រើសរើសយកសកម្មភាពអាជីវកម្មសំខាន់ៗមួយចំនួនដើម្បីយកមកបង្ហាញសម្រាប់ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិ។

## ក- សកម្មភាពអាជីវកម្ម

*តារាងទី១៧ : សកម្មភាពអាជីវកម្មចម្បងតាមគ្រួសារ*

| ប្រភេទអាជីវកម្ម | ចំនួនគ្រួសារ | |
|---|---|---|
| | សៀមរាប | ប៉ៃលិន |
| ម៉ាស៊ីនកិនស្រូវ | ១.៥១២ | ៣២ |
| លក់/ជួសជុលម៉ូតូ/កង់ | ១.៧៦២ | ១៤៦ |
| លក់/ជួសជុលរថយន្ត | ១៧៦ | ៤ |
| លក់/ជួសជុលឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្ម | ៤៤៦ | ៥២ |
| លក់/ជួសជុលគ្រឿងអេឡិចត្រូនិក | ៦០៦ | ៥៧ |
| លក់/ផលិតគ្រឿងសង្ហារិមពីឈើ | ៣១០ | ៥៩ |
| លក់/ផលិតគ្រឿងសង្ហារិមពីស៊ីម៉ង់ត៍ | ៣៤ | ១២ |
| លក់/ផលិតគ្រឿងសង្ហារិមពីដែក/អ៊ីណុក | ៥៨ | ៦ |
| បិតស្រា | ៤១២ | ០ |
| កាត់សក់/អ៊ុតសក់/កែសម្ផស្ស | ១.៣១០ | ៩១ |
| លក់គ្រឿងទេស/ភេសជ្ជៈ | ៦.៤៩៤ | ៧៨៣ |
| លក់ថ្នាំពេទ្យ/គ្លីនិក | ៦០៤ | ៧៩ |
| សណ្ឋាគារ/ផ្ទះសំណាក់ | ៧៥០ | ៤១៤ |
| ភោជនីយដ្ឋាន | ៣៩៦ | ៣១ |
| ស្ថានីយ៍ប្រេងឥន្ធនៈ | ១៩៨ | ១២ |
| តូបលក់សាំង | ១.៣៧២ | ១៣៤ |
| លក់គ្រឿងសំណង់ | ៥៥៤ | ៣៨ |
| កាត់កញ្ចក់/ជាងដែក | ៦២ | ០ |
| អាជីវកម្មផ្សេងៗទៀត | ៦២ | ៥៧ |
| **សរុប** | **១៧.១១៨** | **២.០០៧** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ក្រៅពីការប្រកបរបរកសិកម្មនិងមុខរបរអាជីព ការធ្វើអាជីវកម្មបានដើរតួបន្ថែមយ៉ាងសំខាន់ក្នុងការលើកស្ទួយជីវភាពគ្រួសារ។ តាមតារាងទី១៧ឃើញថា នៅក្នុងខេត្តសៀមរាបមានរបរអាជីវកម្មចំនួន១៧.១១៨គ្រួសារ (ស្មើនឹង៦,៥% នៃគ្រួសារសរុប) ដែលភាគច្រើនគ្រួសារទាំងនោះធ្វើទៅលើការលក់ចាប់ហួយ/គ្រឿងទេស/ភេសជ្ជៈ (៦.៤៩៤គ្រួសារ) បន្ទាប់មក គឺលក់/ជួសជុលម៉ូតូ/កង់ (១.៧៦២គ្រួសារ)

ខណៈដែលលក់/ផលិតគ្រឿងសង្ហារិមពីស៊ីម៉ងត៍មានតិចតួចបំផុត (៣៤គ្រួសារ)។ ខេត្តប៉ៃលិន មានប្រកបរបរអាជីវកម្មចំនួន២.០០៧គ្រួសារ (ស្មើនឹង៩,៩% នៃគ្រួសារសរុប) ដែលភាគច្រើនគ្រួសារទាំងនោះធ្វើទៅលើការលក់ចាប់ហួយ/គ្រឿងទេស/ភេសជ្ជៈ (៧៨៣គ្រួសារ) បន្ទាប់មក គឺសណ្ឋាគារ/ផ្ទះសំណាក់ (៤១៤គ្រួសារ) ខណៈដែលលក់/ជួសជុលរថយន្តមានតិចតួចបំផុត (៤គ្រួសារ)។

## ខ- អ្នកធ្វើការក្នុងអាជីវកម្ម

*រូបភាពទី១៦ : ចំនួនអ្នកធ្វើការក្នុងអាជីវកម្ម បែងចែកតាមភេទ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៦ បង្ហាញពីចំនួនអ្នកធ្វើការក្នុងអាជីវកម្ម។ យើងឃើញថា ខេត្តសៀមរាបមានចំនួនអ្នកធ្វើការក្នុងអាជីវកម្មសរុប៤០.៤៩០នាក់ (ស្រី២០.៤៧៨នាក់ ស្មើនឹង៥០,៦%) ខណៈដែលខេត្តប៉ៃលិនមានចំនួនអ្នកធ្វើការក្នុងអាជីវកម្មសរុប៤.២៩៩នាក់ (ស្រី២.៣៤៣នាក់ ស្មើនឹង៥៤,៥%)។ ជាមធ្យមខេត្តទាំងពីរមានមនុស្សប្រមាណជា២នាក់ ធ្វើការក្នុងមួយអាជីវកម្ម ឬមួយកន្លែង។

## ២.៨- វិស័យអប់រំ និង សេវាសង្គម

### ២.៨.១- វិស័យអប់រំ

វិស័យអប់រំនៅក្នុងសៀវភៅនេះ គឺគ្រាន់តែសំដៅលើចំនួនគ្រឹះស្ថានសិក្សា និងចម្ងាយពីទីតាំងភូមិទៅកន្លែងផ្តល់សេវាអប់រំទាំងនោះតែប៉ុណ្ណោះ។ គ្រឹះស្ថានសិក្សាមានតាមកម្រិតដូចជា មត្តេយ្យសិក្សា បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យ (ទាំងរដ្ឋ និងឯកជន)។

#### ក- គ្រឹះស្ថានសិក្សា

*តារាងទី១៨ : ចំនួនគ្រឹះស្ថានសិក្សាបែងចែកតាមវិស័យ*

| កម្រិតអប់រំ | សៀមរាប | | | ប៉ៃលិន | | |
|---|---|---|---|---|---|---|
| | រដ្ឋ | ឯកជន | សហគមន៍ | រដ្ឋ | ឯកជន | សហគមន៍ |
| មត្តេយ្យសិក្សា | ៤៣០ | ៤៤ | ២០៥ | ២៥ | ២ | ១១ |
| បឋមសិក្សា | ៥៥០ | ៨ | ០ | ៥៣ | ៣ | ០ |
| អនុវិទ្យាល័យ | ៩៥ | ៦ | ០ | ៦ | ០ | ០ |
| វិទ្យាល័យ | ៤៥ | ២ | ០ | ៣ | ០ | ០ |
| សាកលវិទ្យាល័យ | ០ | ៧ | ០ | ០ | ០ | ០ |
| **សរុប** | **១.១២០** | **៦៧** | **២០៥** | **៨៧** | **៥** | **១១** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី១៨ បានបង្ហាញពីចំនួនគ្រឹះស្ថានសិក្សាតាមកម្រិត ដោយបានបែងចែកទៅតាមវិស័យ។ ចាប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា នៅខេត្តសៀមរាប មានគ្រឹះស្ថានសិក្សាចំនួន១.៣៩២កន្លែង ក្នុងនោះមានមត្តេយ្យសិក្សាចំនួន៦៧៩កន្លែង (សាលារដ្ឋមាន៤៣០កន្លែង ឯកជនមាន៤៤កន្លែង និងសាលាសហគមន៍មាន២០៥កន្លែង) បឋមសិក្សាមានចំនួន៥៥៨កន្លែង (សាលារដ្ឋមាន៥៥០កន្លែង និងឯកជនមាន៨កន្លែង) អនុវិទ្យាល័យមានចំនួន១០១កន្លែង (សាលារដ្ឋមានចំនួន៩៥កន្លែង និងឯកជនមាន៦កន្លែង) វិទ្យាល័យមានចំនួន៤៧កន្លែង (សាលារដ្ឋមាន៤៥កន្លែង និងឯកជនមាន២កន្លែង) និងសាកលវិទ្យាល័យមានចំនួន៧កន្លែង (សាលាឯកជន)[9] ផងដែរ។ ខេត្តប៉ៃលិន មានគ្រឹះស្ថានសិក្សាចំនួន

[9] ឯកសារព័ត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចខេត្តសៀមរាប ឆ្នាំ២០២៤

១០៣កន្លែង ក្នុងនោះមត្តេយ្យសិក្សាមានចំនួន៣៨កន្លែង (សាលារដ្ឋមាន២៥កន្លែង ឯកជនមាន២កន្លែង និងសាលាសហគមន៍មាន១១កន្លែង) បឋមសិក្សាមានចំនួន៥៦កន្លែង (សាលារដ្ឋមាន៥៣កន្លែង និងឯកជនមាន៣កន្លែង) អនុវិទ្យាល័យមានចំនួន៦កន្លែង (សាលារដ្ឋ) និងវិទ្យាល័យមានចំនួន៣កន្លែង (សាលារដ្ឋ)។

### ខ- ចម្ងាយពីភូមិទៅគ្រឹះស្ថានសិក្សា

ចម្ងាយជាមធ្យមពីភូមិទៅគ្រឹះស្ថានសិក្សា គឺជាចម្ងាយដែលគិតពីចំណុចកណ្តាលភូមិមួយ (ភូមិគ្មានគ្រឹះស្ថានសិក្សា) ទៅភូមិណាមួយផ្សេងទៀតដែលមានគ្រឹស្ថានសិក្សានិងនៅជិតបំផុត។ ចំពោះភូមិណាដែលមានទីតាំងគ្រឹះស្ថានសិក្សានៅក្នុងនោះជាក់ស្តែង ភូមិនោះមិនបានរាប់បញ្ចូលថាមានចម្ងាយឡើយ។

*តារាងទី១៩ : ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងគ្រឹះស្ថានសិក្សាដែលជិតបំផុត (គិតជាគីឡូម៉ែត្រ)*

| កម្រិតអប់រំ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | បច្ចុប្បន្ន | ៥ឆ្នាំមុន | បច្ចុប្បន្ន | ៥ឆ្នាំមុន |
| មត្តេយ្យសិក្សា | ១,៥ | ១,៥ | ១,៣ | ១,៤ |
| បឋមសិក្សា | ០,៩ | ១,០ | ០,៨ | ០,៨ |
| អនុវិទ្យាល័យ | ៤,១ | ៤,៨ | ៥,០ | ៥,៦ |
| វិទ្យាល័យ | ៨,៦ | ៨,៩ | ៩,៦ | ១០,៦ |
| សាកលវិទ្យាល័យ | ៤៨,៤ | ៤៨,៨ | ៩៩,១ | ៩៩,១ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

កាលពី៥ឆ្នាំមុនរហូតមកដល់បច្ចុប្បន្ន ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងគ្រឹះស្ថានសិក្សាដែលនៅជិតបំផុតគឺមានការប្រែប្រួលបន្តិចបន្តួច។ បច្ចុប្បន្ន នៅខេត្តសៀមរាប ពីចំណុចកណ្តាលភូមិទៅមត្តេយ្យសិក្សាមានចម្ងាយ១,៥គ.ម. ទៅបឋមសិក្សាមានចម្ងាយ០,៩គ.ម. ទៅអនុវិទ្យាល័យមានចម្ងាយ៤,១គ.ម. ទៅវិទ្យាល័យមានចម្ងាយ៨,៦គ.ម. និងពីភូមិទៅសាកលវិទ្យាល័យមានចម្ងាយ៤៨,៤គ.ម.។ ខេត្តប៉ៃលិន បើគិតពីចំណុចកណ្តាលភូមិទៅមត្តេយ្យសិក្សាមានចម្ងាយ១,៣គ.ម. ទៅបឋមសិក្សាមានចម្ងាយ០,៨គ.ម. ទៅអនុវិទ្យាល័យមានចម្ងាយ៥គ.ម. ទៅវិទ្យាល័យមានចម្ងាយ៩,៦គ.ម. និងពីភូមិទៅសាកលវិទ្យាល័យមានចម្ងាយ៩៩,១គ.ម. (មើលតារាងទី១៩)។

### ២.៨.២- សេវាសង្គម

ចម្ងាយមធ្យមពីភូមិទៅទីតាំងផ្តល់សេវាសង្គម ក៏មានន័យមិនខុសគ្នាពីចម្ងាយមធ្យមពីភូមិទៅកាន់គ្រឹះស្ថានសិក្សាដែរ ពោលគឺគិតពីចំណុចកណ្តាលនៃភូមិមួយ ទៅភូមិណាមួយផ្សេងទៀតដែលមានទីតាំងផ្តល់សេវាទាំងនោះ ដោយមិនបានរាប់បញ្ចូលទីតាំងផ្តល់សេវាណាដែលមានជាក់ស្តែងនៅក្នុងភូមិនោះឡើយ។

*តារាងទី២០ : ចម្ងាយប៉ាន់ស្មានជាមធ្យមពីភូមិទៅទីតាំងផ្តល់សេវាសង្គមដែលជិតបំផុត (គិតជាគីឡូម៉ែត្រ)*

| សេវាសង្គម | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | បច្ចុប្បន្ន | ៥ឆ្នាំមុន | បច្ចុប្បន្ន | ៥ឆ្នាំមុន |
| មន្ទីរពេទ្យរដ្ឋ | ១៩,៧ | ២០,១ | ១២,៩ | ១៣,៩ |
| មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព | ៥,២ | ៥,៣ | ៤,៤ | ៦,២ |
| គ្លីនិកឯកជន | ១០,៦ | ១០,៩ | ៨,៣ | ៨,៥ |
| ឱសថស្ថាន | ៦,០ | ៦,២ | ៦,០ | ៦,១ |
| មណ្ឌលពាណិជ្ជកម្ម/ផ្សារ | ៨,៧ | ៨,៩ | ៦,៧ | ៦,៧ |
| ប៉ុស្តិ៍នគរបាល | ៤,៧ | ៤,៨ | ៨,២ | ៨,២ |
| សាលាឃុំ | ៤,៧ | ៤,៧ | ៨,១ | ៨,១ |
| ប្រៃសណីយ៍/អ៊ីនធឺណិតកាហ្វេ | ៨,៣ | ៨,៤ | ៨,៥ | ៨,៧ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២០បានបង្ហាញថា កាលពី៥ឆ្នាំមុនរហូតមកដល់បច្ចុប្បន្ន ចម្ងាយប៉ាន់ស្មានជាមធ្យមពីចំណុចកណ្តាលភូមិទៅកាន់កន្លែងផ្តល់សេវាសង្គមមានការប្រែប្រួលបន្តិចបន្តួច។ ខេត្តសៀមរាប បើគិតពីចំណុចកណ្តាលភូមិទៅដល់មន្ទីរពេទ្យរដ្ឋមានចម្ងាយ១៩,៧គ.ម. ទៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមានចម្ងាយ៥,២គ.ម. ទៅគ្លីនិកឯកជនមានចម្ងាយ១០,៦គ.ម. ទៅឱសថស្ថានមានចម្ងាយ៦,០គ.ម. ទៅមណ្ឌលពាណិជ្ជកម្ម/ផ្សារមានចម្ងាយ៨,៧គ.ម. ទៅប៉ុស្តិ៍នគរបាល/សាលាឃុំមានចម្ងាយ៤,៧គ.ម. និងពីចំណុចកណ្តាលភូមិទៅដល់ប្រៃសណីយ៍/អ៊ីនធឺណិតកាហ្វេមានចម្ងាយ៨,៣គ.ម.។ ខេត្តប៉ៃលិន បើគិតពីចំណុចកណ្តាលភូមិទៅដល់មន្ទីរពេទ្យគឺមានចម្ងាយ១២,៩គ.ម. ទៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមានចម្ងាយ៤,៤គ.ម. ទៅគ្លីនិកឯកជនមានចម្ងាយ៨.៣គ.ម. ទៅឱសថស្ថានមានចម្ងាយ៦,០គ.ម. ទៅមណ្ឌលពាណិជ្ជកម្ម/ផ្សារមានចម្ងាយ៦,៧គ.ម. ទៅប៉ុស្តិ៍នគរបាលមានចម្ងាយ៨,២គ.ម. ទៅសាលាឃុំមានចម្ងាយ៨.១គ.ម. និងពីចំណុចកណ្តាលភូមិទៅដល់ប្រៃសណីយ៍/អ៊ីនធឺណិតកាហ្វេមានចម្ងាយ៨,៥គ.ម.។

## ២.៩- ផ្លូវគមនាគមន៍

ផ្លូវគមនាគមន៍ គឺសំដៅលើផ្លូវថ្នល់សម្រាប់ធ្វើចរាចរទៅមក (មិនរាប់បញ្ចូលផ្លូវទឹកនិងផ្លូវអាកាសទេ)។ រូបភាពខាងក្រោមនឹងបង្ហាញពីប្រវែងផ្លូវថ្នល់ ដូចជាផ្លូវដី ផ្លូវគ្រួស ផ្លូវបេតុង និងផ្លូវកៅស៊ូដែលបានស្ថាបនាក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

*រូបភាពទី១៧ : ការស្ថាបនាផ្លូវថ្នល់ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (គិតជាគីឡូម៉ែត្រ)*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៧ បង្ហាញពីការស្ថាបនាផ្លូវថ្នល់នៅទូទាំងខេត្តទាំងពីរ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ (២០១៩-២០២៣)។ រដ្ឋបាលខេត្តសៀមរាបស្ថាបនាផ្លូវថ្នល់ (ធ្វើថ្មីនិងជួសជុល) សរុបបានប្រវែង ៤៣.៧១គ.ម. ដែលភាគច្រើនជាផ្លូវគ្រួស (២.២៤៦គ.ម.) ខណៈដែលផ្លូវដីស្ថាបនាបាន១,៣០៦គ.ម. ផ្លូវកៅស៊ូបានប្រវែង៥៦២គ.ម. និងផ្លូវបេតុងបានប្រវែង២៥៧គ.ម.។ រដ្ឋបាលខេត្តប៉ៃលិនស្ថាបនាផ្លូវថ្នល់ (ធ្វើថ្មីនិងជួសជុល) សរុបបានប្រវែង១២៧,៤គ.ម. ដែលភាគច្រើនជាផ្លូវគ្រួស (៩៥,២គ.ម.) បន្ទាប់មកគឺផ្លូវកៅស៊ូ (២៥,៥គ.ម.) ផ្លូវបេតុង (៣,៩គ.ម.) និងផ្លូវដីស្ថាបនាបានប្រវែង២,៨គ.ម.។

## ២.១០- សុខាភិបាល

### ២.១០.១- សេវាកម្មសុខភាព

**សេវាកម្មសុខភាព** គឺសំដៅលើទីតាំងនិងភ្នាក់ងារសុខាភិបាល ដែលមានតួនាទីផ្តល់សេវាកម្មសុខភាពជូនប្រជាពលរដ្ឋទូទៅ។

#### ក- ទីតាំងផ្តល់សេវាកម្មសុខភាព




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៨ បានបង្ហាញពីចំនួនទីតាំងផ្តល់សេវាកម្មសុខភាពជូនសាធារណជនទូទៅ។ យើងឃើញថា ខេត្តសៀមរាបមានឱសថស្ថានចំនួន៦៣៣កន្លែង មន្ទីរពេទ្យ/គ្លីនិកឯកជនចំនួន៩៣កន្លែង មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពចំនួន៩៣កន្លែង និងមន្ទីរពេទ្យរដ្ឋ/មន្ទីរពេទ្យបង្អែកចំនួន៥កន្លែង [២]។ ខេត្តប៉ៃលិន មានឱសថស្ថានចំនួន៥៧កន្លែង មន្ទីរពេទ្យ/គ្លីនិកឯកជនចំនួន១៥កន្លែង មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពមាន៧កន្លែង និងមន្ទីរពេទ្យរដ្ឋ/មន្ទីរពេទ្យបង្អែកចំនួន១កន្លែង[៣]។

[២] ឯកសារព័ត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចខេត្តសៀមរាប ឆ្នាំ២០២៤

[៣] របាយការណ៍សមិទ្ធផលសុខាភិបាល ឆ្នាំ២០២៣ និងទិសដៅការងារឆ្នាំ២០២៤ និងឆ្នាំបន្ត

## ខ- ភ្នាក់ងារផ្តល់សេវាកម្មសុខភាព

*រូបភាពទី១៩ : ចំនួនភ្នាក់ងារផ្តល់សេវាកម្មសុខភាព*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី១៩បានបង្ហាញថា ភ្នាក់ងារផ្តល់សេវាកម្មសុខភាពនៅខេត្តសៀមរាបភាគច្រើនគឺកម្រិតពេទ្យមធ្យម (៣២២នាក់) បន្ទាប់មក គឺវេជ្ជបណ្ឌិត (១៦៤នាក់) គិលានុបដ្ឋាយិកា/ឆ្មប (១២៨នាក់) និងឆ្មបបុរាណមានចំនួនតិចជាងគេ (១៦នាក់) ខណៈដែលខេត្តប៉ៃលិន មានកម្រិតគិលានុបដ្ឋាយិកា/ឆ្មបច្រើនជាងគេ (៥៤នាក់) បន្ទាប់មក គឺពេទ្យមធ្យម (២៥នាក់) វេជ្ជបណ្ឌិត (១៧នាក់) និងឆ្មបបុរាណមានចំនួនតិចជាងគេ (១នាក់)។

## ២.១០.២- ជំងឺសំខាន់ៗ

### ក- ជំងឺគ្រុនចាញ់

*រូបភាពទី២០ : ចំនួនអ្នកកើតនិងស្លាប់ដោយសារជំងឺគ្រុនចាញ់*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី២០ បានបង្ហាញពីចំនួនអ្នកកើតនិងស្លាប់ដោយសារជំងឺគ្រុនចាញ់។ យើងឃើញថា ខេត្តសៀមរាបមានជនរងគ្រោះសរុបចំនួន១០៦នាក់ (ស្រី៤៤នាក់) ក្នុងនោះមានអ្នករងគ្រោះរហូតដល់ស្លាប់ចំនួន១៦នាក់ (ស្រី៨នាក់)។ ខេត្តប៉ៃលិនមានជនរងគ្រោះសរុបចំនួន៦២នាក់ (ស្រី១៩នាក់) ក្នុងនោះមិនមានអ្នករងគ្រោះរហូតដល់ស្លាប់ទេ។

## ខ- ជំងឺរបេង




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី២១ បានបង្ហាញពីចំនួនអ្នកកើតនិងស្លាប់ដោយសារជំងឺរបេង។ យើងឃើញថា ខេត្តសៀមរាបមានជនរងគ្រោះសរុបចំនួន៣២២នាក់ (ស្រី១៣៨នាក់) ក្នុងនោះមានអ្នករងគ្រោះរហូតដល់ស្លាប់ចំនួន៧៦នាក់ (ស្រី៣៦នាក់)។ ខេត្តប៉ៃលិនមានជនរងគ្រោះសរុបចំនួន៤២នាក់ (ស្រី១៨នាក់) ក្នុងនោះមានអ្នករងគ្រោះរហូតដល់ស្លាប់ចំនួន៣នាក់ (ស្រី១នាក់)។

## គ- ជំងឺអេដស៍

*រូបភាពទី២២ : ចំនួនអ្នកកើតនិងស្លាប់ដោយសារជំងឺអេដស៍តាមក្រុមអាយុ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី២២ បានបង្ហាញពីចំនួនអ្នកកើតនិងស្លាប់ដោយសារជំងឺអេដស៍ ដោយបែងចែកទៅតាមក្រុមអាយុ។ យើងឃើញថា ខេត្តសៀមរាបមានអ្នកកើតជំងឺនេះសរុប៥៣២នាក់ (៥៤%ជាមនុស្សស្រី)និងស្លាប់១០៦នាក់ (៥៨%ជាមនុស្សស្រី)។ អ្នកកើតជំងឺអេដស៍ភាគច្រើន គឺជាមនុស្សដែលស្ថិតនៅក្នុងវ័យពី២៦-៥៩ឆ្នាំ ខណៈដែលអ្នកស្លាប់ភាគច្រើនស្ថិតនៅក្នុងវ័យពី១៨-២៥ឆ្នាំ។ ខេត្តប៉ៃលិនមានអ្នកកើតជំងឺនេះសរុប១១៨នាក់ (៦៧%ជាមនុស្សស្រី) និងស្លាប់៧នាក់ (៥៧%ជាមនុស្សស្រី)។ អ្នកកើតនិងអ្នកស្លាប់ភាគច្រើន គឺជាមនុស្សដែលស្ថិតនៅក្នុងវ័យពី២៦-៥៩ឆ្នាំ។

## ២.១០.៣- ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ និង កុមារកំព្រា

### ក- ផលប៉ះពាល់ពីជំងឺអេដស៍ទៅគ្រួសារ

*រូបភាពទី២៣ : ចំនួនអ្នករងផលប៉ះពាល់ក្នុងគ្រួសារនិងកុមារកំព្រា (ឪពុកម្ដាយស្លាប់ដោយសារជំងឺអេដស៍*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី២៣ គឺជាចំនួនអ្នករងផលប៉ះពាល់ក្នុងគ្រួសារនិងកុមារកំព្រាដែលមានឪពុកម្ដាយស្លាប់ដោយសារជំងឺអេដស៍។ យើងឃើញថា ខេត្តទាំងពីរមានអ្នកកំពុងផ្ទុក/កើតជំងឺអេដស៍៦៥០នាក់ (សៀមរាប៥៣២នាក់ និងប៉ៃលិន១១៨នាក់) ដែលអ្នកខ្លះរស់នៅម្នាក់ឯង និងអ្នកខ្លះទៀតរស់នៅជាមួយក្រុមគ្រួសារ។ យ៉ាងណាមិញ តាមរូបភាពខាងលើបានបញ្ជាក់ថា ខេត្តសៀមរាបមានមនុស្សចំនួន៥៩០នាក់ ជាសមាជិកគ្រួសារដែលបានរងផលប៉ះពាល់និងកំពុងរស់នៅជាមួយអ្នកជំងឺអេដស៍ និង ៤៤នាក់ ជាកុមារកំព្រាដោយឪពុកម្ដាយរបស់ខ្លួនស្លាប់ដោយសារជំងឺអេដស៍។ រូបភាពនេះក៏បានបង្ហាញផងដែរថា ខេត្តប៉ៃលិនមានមនុស្សចំនួន៣០០នាក់ ជាសមាជិកគ្រួសារដែលបានរងផលប៉ះពាល់និងកំពុងរស់នៅជាមួយអ្នកជំងឺអេដស៍ និង ១៧នាក់ ជាកុមារកំព្រាដោយឪពុកម្ដាយរបស់ខ្លួនស្លាប់ដោយសារជំងឺអេដស៍ ។

### ខ- កុមារកំព្រា

*រូបភាពទី២៤ : ចំនួនកុមារកំព្រាដែលមានអាយុក្រោម១៨ឆ្នាំ*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

រូបភាពទី២៤ គឺជាចំនួនកុមារកំព្រាដែលមានអាយុក្រោម១៨ឆ្នាំ។ តាមរូបភាពនេះបានបង្ហាញថា នៅក្នុងខេត្តសៀមរាបមានកុមារកំព្រាសរុបប្រមាណជា៨០៨នាក់ ដែលក្នុងនោះមាន៣៤៤នាក់ ជាកុមារកំព្រាដែលមានអ្នកមើលថែត្រឹមត្រូវ និង ៤៦៤នាក់ ជាកុមារកំព្រាគ្មានអ្នកមើលថែត្រឹមត្រូវ។ រីឯខេត្តប៉ៃលិន គឺមានកុមារកំព្រាប្រមាណជា១៤៩នាក់ ដែលក្នុងនោះមាន១១៩នាក់ ជាកុមារកំព្រាដែលមានអ្នកមើលថែត្រឹមត្រូវ និង ៣០នាក់ ជាកុមារកំព្រាគ្មានអ្នកមើលថែត្រឹមត្រូវ។

## ២.១១- កសិកម្ម

កសិកម្ម គឺមិនសំដៅទៅលើការដាំដុះតែម៉្យាងនោះទេ វាសំដៅលើការចិញ្ចឹមសត្វ វារីវប្បកម្ម និង ការនេសាទផងដែរ។ តាមរបាយការណ៍ជំរឿនប្រជាជនឆ្នាំ២០១៩ បានបញ្ជាក់ថា សេដ្ឋកិច្ចប្រទេសកម្ពុជាបច្ចុប្បន្នបានពឹងលើវិស័យសំខាន់បី រួមមានវិស័យកសិកម្ម៥៣,៤% វិស័យផលិតកម្មឬឧស្សាហកម្ម ១៦,៦% និងវិស័យសេវាកម្ម១២,៦%។ នៅឆ្នាំ២០២៣ ខេត្តសៀមរាបមានផ្ទៃដីសម្រាប់ធ្វើកសិកម្មប្រមាណជា៤០៤.៧២២ហិកតា រីឯខេត្តប៉ៃលិនមានប្រមាណជា៥៧.៤២០ហិកតា។

### ២.១១.១- ការកាន់កាប់ដីកសិកម្ម

ដីកសិកម្ម គឺសំដៅទៅលើដីដែលគ្រួសារបានកាន់កាប់ធ្វើជាម្ចាស់កម្មសិទ្ធិផ្ទាល់ខ្លួន ឬបានពីការជួលពីគេ ដីជួលឱ្យគេ ដីប្រើប្រាស់មិនគិតថ្លៃ ... ដើម្បីប្រើប្រាស់សម្រាប់ដាំដំណាំ ឬក៏ប្រើប្រាស់សម្រាប់ការងារកសិកម្មផ្សេងៗទៀត។

*តារាងទី២១ : ការកាន់កាប់ផ្ទៃដីកសិកម្មតាមគ្រួសារ*

| ផ្ទៃដីកសិកម្ម | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | ភាគរយ | គ្រួសារ | ភាគរយ |
| គ្មានដី | ៧៥.៥៥២ | ២៩ | ៥.៣០៧ | ២៦ |
| ក្រោម១ហិកតា | ៧១.៩២២ | ២៨ | ២.០៧៥ | ១០ |
| ១-១.៩៩ហិកតា | ៥៦.៣៤២ | ២២ | ៣.៩៨៧ | ២០ |
| ២-២.៩៩ហិកតា | ២៩.៦៩០ | ១១ | ២.៨២០ | ១៤ |
| ៣-៣.៩៩ហិកតា | ១៤.៧៦០ | ៦ | ២.៥៨៨ | ១៣ |
| ៤-៤.៩៩ហិកតា | ៧.៦៧០ | ៣ | ១.៧៩៧ | ៩ |
| ៥ហិកតាឡើង | ៥.៥៩០ | ២ | ១.៧០៩ | ៨ |
| សរុប | ២៦១.៥២៦ | ១០០ | ២០.២៨៣ | ១០០ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២១បានបង្ហាញថា ខេត្តសៀមរាប គ្រួសារភាគច្រើនមានក្បាលដីកាន់កាប់សម្រាប់ធ្វើកសិកម្ម (៧១%) ហើយក៏មានគ្រួសារមួយចំនួនតូច (២៩%) គ្មានដីប្រើប្រាស់សម្រាប់ធ្វើកសិកម្មផងដែរ។ ពួកគាត់អាចជាគ្រួសាររស់នៅទីប្រជុំជន មានមុខរបរជាអ្នកលក់ដូរតាមផ្ទះ លក់ដូរនៅផ្សារ ឬធ្វើការងារផ្សេងៗទៀត។ ក្នុងចំណោមគ្រួសារសរុបទូទាំងខេត្ត ភាគច្រើននៃគ្រួសារទាំងនោះ (៧៥.៥៥២គ្រួសារ ស្មើនឹង២៩%) គឺគ្មានដីកាន់កាប់សម្រាប់ធ្វើកសិកម្ម ខណៈដែលគ្រួសារមានដីកសិកម្មចាប់ពី៥ហិកតាឡើងទៅមានចំនួនតិចជាងគេ គឺត្រឹមតែ២% (៥.៥៩០គ្រួសារ) ប៉ុណ្ណោះ។ ខេត្តប៉ៃលិន គ្រួសារមានក្បាលដីកាន់កាប់សម្រាប់ធ្វើកសិកម្ម៧៤% និង ២៦% ទៀត គ្មានដីសម្រាប់ធ្វើកសិកម្មទេ។ ភាគច្រើននៃគ្រួសារទាំងនោះ (៥.៣០៧គ្រួសារ ស្មើនឹង២៦%) គ្មានដីកាន់កាប់សម្រាប់ធ្វើកសិកម្ម ខណៈដែលគ្រួសារមានដីសម្រាប់ធ្វើកសិកម្មចាប់ពី៥ហិកតាឡើងមានចំនួនតិចជាងគេ គឺមានត្រឹម ៨% (១.៧០៩ គ្រួសារ) តែប៉ុណ្ណោះ។

### ២.១១.២- ផ្ទៃដីកសិកម្ម និង ផលិតកម្ម

ផ្ទៃដីកសិកម្មនៅប្រទេសកម្ពុជាត្រូវបានចែកដីជាពីរប្រភេទគឺ ប្រភេទដីស្ងួត និងប្រភេទដីសើម។ ចំណែកឯរដូវវិញក៏មានពីរដែរ គឺរដូវប្រាំង និងរដូវវស្សា។ តារាងខាងក្រោមនឹងបង្ហាញពីចំនួនផ្ទៃដីកសិកម្ម និងចំនួនផ្ទៃដីដែលបានបង្កបង្កើនផលដោយបែងចែងទៅតាមប្រភេទរដូវនីមួយៗ។

*តារាងទី២២ : ចំនួនផ្ទៃដីកសិកម្ម និង ផ្ទៃដីបានដាំដុះតាមប្រភេទរដូវ (គិតជាហិកតា)*

| បរិយាយ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | ផ្ទៃដីកសិកម្ម | ផ្ទៃដីបានដាំដុះ | ផ្ទៃដីកសិកម្ម | ផ្ទៃដីបានដាំដុះ |
| រដូវប្រាំង | ២១.៥២៨ | ២១.៤០៤ | 0 | 0 |
| រដូវវស្សា | ៣៧២.៥៣០ | ៣៦៦.០០៨ | ៣.១០៦ | ៣.១០៦ |
| ទាំងពីររដូវ | ១០.៦៦៤ | ១០.៦១៨ | ៥៤.៣១៤ | ៤៩.៧៦៦ |
| **សរុប** | **៤០៤.៧២២** | **៣៩៨.០៣០** | **៥៧.៤២០** | **៥២.៨៧២** |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២២ គឺជាចំនួនផ្ទៃដីកសិកម្មនិងផ្ទៃដីដែលបានដាំដុះទៅតាមប្រភេទរដូវនីមួយៗ។ ផ្ទៃដីប្រមាណជា៩៨% នៅខេត្តសៀមរាប និង៩២% នៃផ្ទៃដីកសិកម្មសរុបនៅខេត្តប៉ៃលិនត្រូវបានយកទៅបង្កបង្កើនផលនៅក្នុងឆ្នាំ២០២៣នេះ។ ខេត្តសៀមរាប មានផ្ទៃដីកសិកម្មសរុបប្រមាណ៤០៤.៧២២ហិកតា ក្នុងនោះផ្ទៃដីដែលអាចធ្វើកសិកម្មបានតែនៅរដូវប្រាំងមានចំនួន២១.៥២៨ហិកតា ស្មើនឹង៥% (ដាំដុះបាន២១.៤០៤ហិកតា) សម្រាប់តែរដូវវស្សាមាន៣៧២.៥៣០ហិកតា ស្មើនឹង៩២% (ដាំដុះបាន៣៦៦.០០៨ហិកតា) និងផ្ទៃដីដែលអាចបង្កបង្កើនផលបានទាំងពីររដូវមាន១០.៦៦៤ហិកតា ស្មើនឹង៣% (ដាំដុះបាន១០.៦១៨ហិកតា)។ ខេត្តប៉ៃលិន មានផ្ទៃដីកសិកម្មសរុប៥៧.៤២០ហិកតា ក្នុងនោះផ្ទៃដីដែលអាចធ្វើកសិកម្មបានតែនៅរដូវវស្សាមាន៣.១០៦ហិកតា ស្មើនឹង៦% (ដាំដុះបាន៣.១០៦ហិកតា) និងផ្ទៃដីដែលអាចបង្កបង្កើនផលបានទាំងពីររដូវមានចំនួន៥៤.៣១៤ហិកតា ស្មើនឹង៩៤% (ដាំដុះបាន៤៩.៧៦៦ហិកតា)។

## ២.១១.៣- ប្រព័ន្ធស្រោចស្រព

*រូបភាពទី២៥ : ភាគរយនៃផ្ទៃដីដាំដុះដែលមាននិងគ្មានប្រព័ន្ធស្រោចស្រព នៅខេត្តសៀមរាប*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

នៅខេត្តសៀមរាប មានប្រមាណតែ៤១% នៃផ្ទៃដីកសិកម្មដែលបានបង្កបង្កើនផលប៉ុណ្ណោះដែលមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាប់។ ផ្ទៃដីកសិកម្មប្រមាណ៣៩៨.០៣០ហិកតា ត្រូវបានដាំដុះ ដែលក្នុងនោះ ៨៤%ត្រូវបានដាំដំណាំស្រូវ និង ១៦% ទៀត ត្រូវបានដំដំណាំផ្សេងៗក្រៅពីនេះ។ ដំណាំស្រូវប្រមាណ៣២% ខណៈដែល៨៥% នៃដំណាំផ្សេងៗទៀតក្រៅពីនេះមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ (មើលរូបភាពទី២៥)។

## ២.១១.៤- ការប្រើប្រាស់ជី និង ថ្នាំពុលលើផ្ទៃដីផលិតកម្ម

### ក- ការប្រើប្រាស់ជីលើផ្ទៃដីផលិតកម្ម

*រូបភាពទី២៦ : ភាគរយនៃការប្រើប្រាស់ជីលើផ្ទៃដីផលិតកម្មនៅខេត្តសៀមរាប*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ខេត្តសៀមរាប ប្រជាពលរដ្ឋបានប្រើប្រាស់ជីគីមីលើផ្ទៃដីផលិតកម្មរហូតដល់៨៨% ខណៈដែលការប្រើប្រាស់ជីសរីរាង្គមានតែ១២%ប៉ុណ្ណោះ។ ជីគីមីត្រូវបានប្រើប្រាស់ភាគច្រើនទៅលើដំណាំផ្សេងក្រៅពីស្រូវ (៩៩%) ខុសពីជីសរីរាង្គដែលត្រូវបានប្រើប្រាស់ទៅលើដំណាំស្រូវ ១៤% ដែលនេះជាតួលេខខ្ពស់ជាងដំណាំផ្សេងក្រៅពីស្រូវ ដែលមានត្រឹមតែ១% ប៉ុណ្ណោះ (មើលរូបភាពទី២៦)។

## ខ- ការប្រើប្រាស់ថ្នាំពុលលើផ្ទៃដីផលិតកម្ម

*រូបភាពទី២៧ : ភាគរយនៃការប្រើប្រាស់ថ្នាំពុលលើផ្ទៃដីផលិតកម្មនៅខេត្តសៀមរាប*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

ក្រៅពីការប្រើប្រាស់ជីទាំងពីរប្រភេទខាងលើ ថ្នាំពុលក៏ត្រូវបានប្រើប្រាស់ទៅលើដំណាំកសិកម្មផងដែរ។ បើប្រៀបធៀបទៅនឹងផ្ទៃដីផលិតកម្មទាំងអស់នៅក្នុងខេត្តសៀមរាប យើងឃើញថា មាន៨៣% (៣២៨.៥៦៦ហិកតា) ប្រើប្រាស់ថ្នាំសម្លាប់ស្មៅ បន្ទាប់មកគឺការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃមាន៣១% (១២២.២៤០ហិកតា) ប្រើប្រាស់ថ្នាំសម្លាប់ផ្សិតមាន៣% (១៣.៩២៨ហិកតា) និងប្រើប្រាស់ថ្នាំពុលផ្សេងទៀតមាន១% (៤.១៣៦ហិកតា)។ ការប្រើប្រាស់ថ្នាំពុលទាំងនោះ ស្ទើរតែទាំងអស់គឺប្រើប្រាស់ទៅលើដំណាំស្រូវ ដូចជាថ្នាំសម្លាប់ស្មៅ ថ្នាំសម្លាប់សត្វចង្រៃ ថ្នាំសម្លាប់ផ្សិត ជាដើម (មើលរូបភាពទី២៧)។

### ២.១១.៥- ការចិញ្ចឹមបសុសត្វ និង បសុបក្សី

#### ក- បសុសត្វ

*តារាងទី២៣ : ចំនួនគ្រួសារនិងការចិញ្ចឹមបសុសត្វ (គិតជាក្បាល)*

| បសុសត្វ | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | ចំនួន | គ្រួសារ | ចំនួន |
| គោ | ៧១.១៧០ | ២០៩.៣៨៨ | ១.៧១៩ | ១២.៤១៨ |
| ក្របី | ៦.៨៨៦ | ៣៥.៤៧២ | ១ | ៧ |
| សេះ | ៦៤ | ២៦០ | ០ | ០ |
| ជ្រូក | ២១.៤២៨ | ៨៨.៤៨២ | ៣៤៨ | ៣.៤៣២ |
| ពពែ/ចៀម | ២៩៦ | ១.៧០៨ | ២៣៤ | ១.២០២ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២៣ បង្ហាញពីចំនួនបសុសត្វដែលបានចិញ្ចឹមតាមគ្រួសារ។ តាមតារាងនេះយើងឃើញថា នៅក្នុងខេត្តសៀមរាប ការចិញ្ចឹមគោគឺឈរនៅលំដាប់ខ្ពស់ទី១ ដែលមានចំនួន២០៩.៣៨៨ក្បាល ត្រូវបានចិញ្ចឹមក្នុង៧១.១៧០គ្រួសារ ស្មើនឹង២៧,២% នៃគ្រួសារសរុប (ជាមធ្យម៣ក្បាល/គ្រួសារដែលចិញ្ចឹម) ជ្រូកស្ថិតនៅលំដាប់ទី២ ដែលមានចំនួន៨៨.៤៨២ក្បាល ត្រូវបានចិញ្ចឹមក្នុង២១.៤២៨គ្រួសារ ស្មើនឹង៨,២% នៃគ្រួសារសរុប (ជាមធ្យម៤ក្បាល/គ្រួសារដែលចិញ្ចឹម) ខណៈដែលការចិញ្ចឹមសេះមានចំនួនតិចតួចបំផុត (មាន២៦០ក្បាល ត្រូវបានចិញ្ចឹមក្នុង៦៤គ្រួសារ)។ ខេត្តប៉ៃលិនក៏មិនខុសគ្នាពីខេត្តសៀមរាបដែរ ការចិញ្ចឹមគោគឺឈរនៅលំដាប់ខ្ពស់ទី១ ដែលមានចំនួន១២.៤១៨ក្បាល ត្រូវបានចិញ្ចឹមក្នុង១.៧១៩គ្រួសារ ស្មើនឹង៨,៥% នៃគ្រួសារសរុប (ជាមធ្យម៧ក្បាល/គ្រួសារដែលចិញ្ចឹម) និងជ្រូកគឺស្ថិតនៅលំដាប់ទី២ មានចំនួន៣.៤៣២ក្បាល ត្រូវបានចិញ្ចឹមក្នុង៣៤៨គ្រួសារ ស្មើនឹង១,៧% នៃគ្រួសារសរុប (ជាមធ្យម១០ក្បាល/គ្រួសារដែលចិញ្ចឹម) ខណៈដែលសេះគ្មានគ្រួសារណាមួយចិញ្ចឹមទេ។

## ខ- បសុបក្សី

*តារាងទី២៤ : ចំនួនគ្រួសារនិងការចិញ្ចឹមបសុបក្សី (គិតជាក្បាល)*

| បសុបក្សី | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | ចំនួន | គ្រួសារ | ចំនួន |
| មាន់ | ១៤៥.៨៥៨ | ១.៩១០.២៨២ | ៦.៩០៣ | ១២៥.១១០ |
| ទា | ២០.៥១៤ | ៦៤៣.១៦០ | ៧៧៤ | ១០.៤៤៩ |
| គ្រួច | ៥១៦ | ១.៦៤៤ | ១០ | ១២០ |
| ត្រចៀកកាំ | ២០០ | - | 0 | - |
| សត្វល្អិត | ៦៣៨ | - | 0 | - |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២៤ បង្ហាញពីចំនួនបសុបក្សីដែលបានចិញ្ចឹមតាមគ្រួសារ។ ក្នុងតារាងនេះយើងឃើញថា នៅក្នុងខេត្តសៀមរាប មាន់មានចំនួន១.៩១០.២៨២ក្បាល ត្រូវបានចិញ្ចឹមក្នុង១៤៥.៨៥៨គ្រួសារ ស្មើនឹង៥៥,៨% នៃគ្រួសារសរុប (ជាមធ្យម១៣ក្បាល/គ្រួសារដែលចិញ្ចឹម) ទាមាន៦៤៣.១៦០ក្បាល ត្រូវបានចិញ្ចឹមក្នុង២០.៥១៤គ្រួសារ ស្មើនឹង៧,៨% នៃគ្រួសារសរុប (ជាមធ្យម៣១ក្បាល/គ្រួសារដែលចិញ្ចឹម) គ្រួចមាន១.៦៤៤ក្បាល ត្រូវបានចិញ្ចឹមក្នុង៥១៦គ្រួសារ ស្មើនឹង0,២0% នៃគ្រួសារសរុប (ជាមធ្យម៣ក្បាល/គ្រួសារដែលចិញ្ចឹម) ការចិញ្ចឹមត្រចៀកកាំមានចំនួន២០០គ្រួសារ និងការចិញ្ចឹមសត្វល្អិតមានចំនួន៦៣៨គ្រួសារ។ ឯខេត្តប៉ៃលិន មាន់មានចំនួន១២៥.១១០ក្បាល ត្រូវបានចិញ្ចឹមក្នុង៦.៩០៣គ្រួសារ ស្មើនឹង៣៤% នៃគ្រួសារសរុប (ជាមធ្យម១៨ក្បាល/គ្រួសារដែលចិញ្ចឹម) ទាមាន ១០.៤៤៩ក្បាល ត្រូវបានចិញ្ចឹមក្នុង៧៧៤គ្រួសារ ស្មើនឹង៣,៨% នៃគ្រួសារសរុប (ជាមធ្យម១៤ក្បាល/គ្រួសារដែលចិញ្ចឹម) និងគ្រួចមាន១២០ក្បាល ត្រូវបានចិញ្ចឹមក្នុង១០គ្រួសារ ស្មើនឹង0,0៥% នៃគ្រួសារសរុប (ជាមធ្យម១២ក្បាល/គ្រួសារដែលចិញ្ចឹម) ចំណែកត្រចៀកកាំ និងសត្វល្អិត គឺគ្មានគ្រួសារណាចិញ្ចឹមនោះទេ។

## គ- វារីវប្បកម្ម

*តារាងទី២៥ : ចំនួនគ្រួសារនិងការចិញ្ចឹមវារីវប្បកម្ម (គិតជាតោន)*

| វារីវប្បកម្ម | សៀមរាប | | ប៉ៃលិន | |
|---|---|---|---|---|
| | គ្រួសារ | បរិមាណផល | គ្រួសារ | បរិមាណផល |
| ត្រី | ៨១០ | ១៨៧.៧៧៦ | ១០ | ៣៧០ |
| បង្កង | ៨ | ២ | ១ | ២០ |
| ក្រពើ | ២០៨ | ២.៣៤២ | ០ | ០ |
| កង្កែប | ៦០ | ៩ | ៤ | ០,៨ |
| អន្ទង់ | ៦ | ៤ | ១៦ | ១០ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តារាងទី២៥ គឺជាចំនួនវារីវប្បកម្មដែលចិញ្ចឹមនៅតាមគ្រួសារ។ តារាងនេះបានបង្ហាញថា ការធ្វើវារីវប្បកម្មនៅខេត្តសៀមរាប ភាគច្រើនគឺចិញ្ចឹមត្រី ដែលមាន៨១០គ្រួសារ ស្មើនឹង០,៣១% នៃគ្រួសារសរុប (បរិមាណផល១៨៧.៧៧៦តោន/ឆ្នាំ ដែលជាមធ្យមប្រមាណ២៣២តោន/គ្រួសារដែលចិញ្ចឹម) បន្ទាប់មកគឺក្រពើ មានប្រមាណ២០៨គ្រួសារ ស្មើនឹង០,០៨% នៃគ្រួសារសរុប (បរិមាណផល២.៣៤២តោន/ឆ្នាំ ដែលជាមធ្យមប្រមាណ១១តោន/គ្រួសារដែលចិញ្ចឹម) ខណៈដែលវារីវប្បកម្មផ្សេងទៀតដូចជា បង្កង កង្កែប អន្ទង់ ... មានចំនួនតិចតួចបំផុត។ រីឯខេត្តប៉ៃលិន មិនសូវមានគ្រួសារធ្វើវារីវប្បកម្មទេ ផ្អែកតាមតារាងខាងលើ មានតែចិញ្ចឹមត្រីចំនួន១០គ្រួសារ ស្មើនឹង០,០៥% នៃគ្រួសារសរុប (បរិមាណផល៣៧០តោន/ឆ្នាំ) ចិញ្ចឹមអន្ទង់១៦គ្រួសារ ស្មើនឹង០,០៨% នៃគ្រួសារសរុប (បរិមាណផល១០តោន/ឆ្នាំ) និងចិញ្ចឹមកង្កែប៤គ្រួសារ ស្មើនឹង០,០២% នៃគ្រួសារសរុប (បរិមាណផល០,៨តោន/ឆ្នាំ) ប៉ុណ្ណោះ។

## ២.១១.៦- ទិន្នផលដំណាំ និង គោលបំណងផលិត

### ក- ទិន្នផលដំណាំ

*តារាងទី២៦ : ទិន្នផលនៃដំណាំសំខាន់ៗនៅក្នុងខេត្តសៀមរាប (គិតជាតោន)*

| ដំណាំ | ទិន្នផល (តោន/ហិកតា) | បរិមាណផល/១ឆ្នាំ |
|---|---|---|
| ដំឡូងមី | ១២ | ១.២៨០.៥៣៥ |
| ស្រូវ | ២ | ៧៥៧.៩៣១ |
| ស្វាយចន្ទី | ២ | ១៩.៧១១ |
| ស្វាយ | ១០ | ១៦.០០០ |
| ពោត | ៤ | ២.៨៨៦ |
| សណ្តែកបាយ | ២ | ២.៧៦៤ |
| អំពៅ | ១៥ | ៦៦០ |
| ទុរេន | ១០ | ៤១៤ |
| ចេក | ៣ | ២៤៨ |
| សណ្តែកដី | ១០ | ១០០ |

*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

តាមតារាងទី២៦ខាងលើបានបង្ហាញថា ក្នុងចំណោមដំណាំជាច្រើនមុខដែលមានវត្តមាននៅក្នុងខេត្តសៀមរាប ដំឡូងមី គឺជាដំណាំតែមួយគត់ដែលមានបរិមាណផលខ្ពស់ជាងគេ វាមាន១.២៨០.៥៣៥តោន (ជាមធ្យម១២តោន/ហិកតា) បន្ទាប់មក គឺដំណាំស្រូវ មាន៧៥៧.៩៣១,២តោន (ជាមធ្យម២តោន/ហិកតា) បន្ទាប់មកទៀត គឺដំណាំស្វាយចន្ទី មាន១៩.៧១១តោន (ជាមធ្យម២តោន/ហិកតា) ស្វាយមាន១៦.០០០តោន (ជាមធ្យម១០តោន/ហិកតា) ពោត២.៨៨៦តោន (ជាមធ្យម៤តោន/ហិកតា) សណ្តែកបាយ២.៧៦៤តោន (ជាមធ្យម២តោន/ហិកតា) ខណៈដែលដំណាំសណ្តែកដី ចេក ទុរេន និង អំពៅមានចំនួនតិចតួចប៉ុណ្ណោះ បើធៀបទៅនឹងដំណាំទាំងអស់នៅទូទាំងខេត្ត។

## ខ- គោលបំណងផលិត

*រូបភាពទី២៨ : ភាគរយគោលបំណងចម្បងនៃការដាំដំណាំក្នុងខេត្តសៀមរាប*




*ប្រភព : ទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិឆ្នាំ២០២៣*

គោលបំណងចម្បងនៃការដាំដំណាំនៅក្នុងខេត្តសៀមរាប ៩១% គឺដាំដើម្បីប្រមូលផលលក់ និង ៥% គឺសម្រាប់បរិភោគឬប្រើប្រាស់ក្នុងគ្រួសារ (មើលរូបភាពទី២៨)។

# ជំពូកទី៣

# សន្និដ្ឋាន និង អនុសាសន៍

## ៣.១- សន្និដ្ឋាន

តាមលទ្ធផលនៃការវិភាគខាងលើអាចសន្និដ្ឋានបានថា ក្រៅពីកត្តាប្រជាជន គឺមានកត្តាផ្សេងទៀតដែលជះឥទ្ធិពលដល់ការរួមចំណែកក្នុងការអភិវឌ្ឍរបស់ខេត្តទាំងពីរ ដូចជាការប្រើប្រាស់ទឹកស្អាត ការប៉ះពាល់បរិស្ថាននិងអនាម័យ បញ្ហាទំនាស់ដីធ្លី អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ អសន្តិសុខសង្គម បញ្ហាគ្រឿងញៀន សេវាសុខាភិបាល សេវាអប់រំជាដើម។ បញ្ហាទាំងអស់នេះ គឺជាធាតុចូលយ៉ាងសំខាន់ ដែលត្រូវគិតគូរវែងឆ្ងាយទៅអនាគត ដើម្បីឱ្យខេត្តទាំងពីរមានការអភិវឌ្ឍបន្ថែមទៀត ពិសេសគឺកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យប្រជាជនទទួលបាននូវសុវត្ថិភាព និងសុខុមាលភាពពិតប្រាកដ។

## ៣.២- អនុសាសន៍

ខាងក្រោមនេះជាអនុសាសន៍មួយចំនួន ដើម្បីឱ្យខេត្តទាំងពីរមានការអភិវឌ្ឍល្អប្រសើរៈ

១. គ្រប់គ្រងនូវចំនួនប្រជាជនទាំងការចំណាក និងចំណូលស្រុកឱ្យមានភាពសមស្រប ព្រោះថាប្រជាជនជាកត្តាចម្បងនៃការរៀបចំផែនការអភិវឌ្ឍផ្សេងៗនៅក្នុងមូលដ្ឋានដែលមិនអាចខ្វះបាន។

២. ជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យ តាមរយៈអាជ្ញាធរភូមិ ឃុំ/សង្កាត់ និងអង្គការក្រៅរាជរដ្ឋាភិបាល រួមទាំងការចូលរួមពីមន្ទីរអភិវឌ្ឍន៍ជនបទផងដែរ។

៣. ការដោះស្រាយទំនាស់ដីធ្លី គួរធ្វើទៅតាមបច្ចេកទេស និតិវិធីនៃច្បាប់ និងតម្លាភាព ដោយមានការសហការពីអាជ្ញាធរដែនដី និងអាជ្ញាធរដោះស្រាយទំនាស់ដីធ្លី ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានយុត្តិធម៌ពិតប្រាកដ។

៤. អាជ្ញាធរក្នុងតំបន់ត្រូវអប់រំ និងណែនាំប្រជាជនឱ្យបានយល់ដឹងពីផលវិបាកនៃអំពើហិង្សាក្នុងគ្រួសារ ដែលនាំឱ្យមានការបែកបាក់គ្រួសារ បាត់បង់ឬប៉ះពាល់ដល់ការសិក្សារបស់កូន ខាតបង់ប្រាក់កាស ខាតបង់ពេលវេលាសម្រាប់ប្រកបរបររកស៊ីប្រចាំថ្ងៃ និងបាត់បង់អាយុជីវិត ម្យ៉ាងទៀតវានាំឱ្យរំខានដល់អ្នកជិតខាង និងអាជ្ញាធរដើម្បីជួយដោះស្រាយទៀតផង។

៥. រៀបចំផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងរនាំងខណ្ឌទ្រូងផ្លូវបន្ថែម រួមទាំងដាក់ចេញនូវកម្មវិធីបណ្ដុះបណ្ដាលឬផ្សព្វផ្សាយនៅតាមសាលារៀន/តាមភូមិ ដើម្បីឱ្យសិស្ស និស្សិត ក៏ដូចជាប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានមានការយល់ដឹងពីច្បាប់ចរាចរណ៍ និងផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍។

៦. សមត្ថកិច្ចគួរតែមានវិធានការទប់ស្កាត់ឱ្យខានតែបាន នូវបញ្ហាអសន្តិសុខដែលកើតមាននៅក្នុងមូលដ្ឋានរបស់ខ្លួន ដូចជាការលួច ឆក់ ប្លន់ ឃាតកម្ម គ្រឿងញៀនជាដើម។

៧. ពង្រឹងនិងពង្រីកបន្ថែមទៀតនូវការផ្ដល់សេវាសុខាភិបាល សេវាអប់រំ និងសេវាសាធារណៈផ្សេងៗទៀតឱ្យបានល្អប្រសើរជូនដល់ប្រជាពលរដ្ឋដែលដែលមានតម្រូវការ។

៨. អាជ្ញាធរមូលដ្ឋានគួរមានការយកចិត្តទុកដាក់លើបរិស្ថាន ជាពិសេសគឺការទុកដាក់សំរាម កាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វចង្រៃផ្សេងៗបានត្រឹមត្រូវ។

# ឧបសម្ព័ន្ធ១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្របខណ្ឌសំណួរស្ថិតិថ្នាក់ក្រោមជាតិ

## (បណ្ដុះបណ្ដាល និងស្រង់ទិន្នន័យ)

រៀបចំដោយ៖


នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ
វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ


ឆ្នាំ២០២៣

**ក្រសួងផែនការ**

**វិទ្យាស្ថានជាតិស្ថិតិ**

**កម្រងសំណួរស្ថិតិថ្នាក់ក្រោមជាតិ**

Sub-national Statistics Questionnaire

**លេខកម្រងបញ្ជីសំណួរ** / ID QUESTIONNAIRE ៖.....................................

| ព័ត៌មានភូមិសាស្ត្រ<br>Geographical Information | លេខកូដ<br>Code |
|---|---|
| រាជធានី/ខេត្ត៖<br>Municipal / Provincial: | |
| ស្រុក/ខណ្ឌ/ក្រុង៖<br>District / City: | |
| ឃុំ/សង្កាត់៖<br>Commune: | |
| ភូមិ/មណ្ឌល៖<br>Village: | |
| តំបន់ ( ទំនាបកណ្ដាល=១, បឹងទន្លេសាប=២, ឆ្នេរសមុទ្រ=៣, ភ្នំ និងខ្ពង់រាប=៤ )៖<br>Zone ( Plain Zone=1, Tonle Sap Lake Zone=2, Coastal Zone=3, Plateau and Mountainous Zone=4 ): | |
| ផ្នែក ( ទីប្រជុំជន=១, ជនបទ=២ )៖<br>Sector ( Urban=1 Rural = 2 ): | |

| ព័ត៌មានមន្ត្រីត្រួតពិនិត្យការសម្ភាស មន្ត្រីសម្ភាសន៍ និងអ្នកឆ្លើយតបការសម្ភាស<br>Supervisor, Enumerator and Respondent Information | | | | |
|---|---|---|---|---|
| ព័ត៌មាន<br>Information | ឈ្មោះ<br>Name | មុខងារ<br>Position | លេខទូរសព្ទ<br>Phone Number | ហត្ថលេខា<br>Signature |
| មន្ត្រីត្រួតពិនិត្យការសម្ភាស<br>Supervisor | | | | |
| មន្ត្រីសម្ភាសន៍<br>Enumerator | | | | |
| អ្នកឆ្លើយតបការសម្ភាស<br>Respondent | | | | |

# ផ្នែកទី១ ៖ ប្រជាសាស្ត្រ Demography

### សំណួរទី១.១ ៖ ចំនួនសហគមន៍/សមាគមនៅក្នុងភូមិ Number of Communities/Associations in the village

| ឈ្មោះ<br>Name | សកម្មភាពចម្បង<br>Main Activities | ចំនួនគ្រួសារដែលចូលរួម<br>No. of Households | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|---|
| 1- | | | | |
| 2- | | | | |
| 3- | | | | |
| 4- | | | | |
| *សរុប*<br>*Total* | | | | |

### សំណួរទី១.២ ៖ ចំនួនអង្គការនៅក្នុងភូមិ Number of Organization in the village

| ឈ្មោះ<br>Name | សកម្មភាពចម្បង<br>Main Activities |
|---|---|
| 1- | |
| 2- | |
| 3- | |
| 4- | |

### សំណួរទី១.៣ ៖ ចំនួនមីក្រូហិរញ្ញវត្ថុ/ធនាគារនៅក្នុងភូមិ Number of Microfinances/Banks in the village

| ឈ្មោះ<br>Name | សកម្មភាពចម្បង<br>Main Activities |
|---|---|
| 1- | |
| 2- | |
| 3- | |
| 4- | |

**សំណួរទី១.៤ ៖ ចំនួនគ្រួសារ និងចំនួនប្រជាជន** Number of Households and Population

| ប្រភេទគ្រួសារ<br>Household type | ចំនួនគ្រួសារ<br>No. of household | ចំនួនមនុស្សនៅក្នុងគ្រួសារ<br>No. of persons in the household | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|---|
| 1- បុរស ជាមេគ្រួសារ Male headed households | | | | |
| 2- ស្ត្រី ជាមេគ្រួសារ Female headed households | | | | |
| 3- ស្ត្រីជាមេគ្រួសារដែលមានកុមារអាយុក្រោម៥ឆ្នាំ<br>Female headed households having less 5 years old children | | | | |
| *សរុប*<br>*Total (1+2)* | | | | |

**សំណួរទី១.៥ ៖ ចំនួនជនជាតិដែលរស់នៅក្នុងភូមិ** Number of Nationalities are living in the village

| ជនជាតិ<br>Nationality | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|
| 1- ខ្មែរ Khmer | | | |
| 2- ចិន Chinese | | | |
| 3- ថៃ Thailand | | | |
| 4- ឡាវ Laos | | | |
| 5- វៀតណាម Vietnamese | | | |
| 6- ខ្មែរឥស្លាម Khmer Islam | | | |
| 7- កូរ៉េ Korean | | | |
| 8- ជនជាតិដើមភាគតិច Group of Ethnic minority | | | |
| 9- ជនជាតិបរទេសផ្សេងៗទៀត Other Nationality | | | |
| *សរុប*<br>*Total* | | | |

**សំណួរទី១.៦ ៖ ស្ថានភាពអាពាហ៍ពិពាហ៍របស់មេគ្រួសារ** Marital status of household headed

| ស្ថានភាពអាពាហ៍ពិពាហ៍<br>Marital status | ចំនួនគ្រួសារ<br>No. of household |
|---|---|
| 1- រៀបការរួច Married | |
| 2- រស់នៅផ្សេងគ្នា/បែកគ្នា ) Separated | |
| 3- មេម៉ាយ/ពោះម៉ាយ Widowed | |
| 4- លះលែងគ្នា Divorced | |
| 5- រស់នៅជាមួយគ្នាមិនបានរៀបការ Living together without married | |
| 6- មិនដែលរៀបការ ( នៅលីវ ) Never married | |
| *សរុប*<br>*Total* | |

** សំណួរទី១.៦៖ សរុបស្ថានភាពអាពាហ៍ពិពាហ៍ គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបដែលមានក្នុងភូមិ Total of marital status is must be equal to the number of households in the village.*

**សំណួរទី១.៧ ៖ ចំនួនមនុស្សធ្វើចំណាកស្រុកចូល និងចេញ** Number of person In and out-migrations

| ការពិពណ៌នា<br>Descriptions | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|
| 1- ចំណូលស្រុក In-migration | | | |
| 2- ចំណាកស្រុក Out-migration | | | |
| *2.1- ចំណាកស្រុកក្នុងប្រទេស Local migration* | | | |
| 2.1.1- ដើម្បីស្វែងរកការងារធ្វើ To seeking employment | | | |
| 2.1.2- ដើម្បីបន្តការសិក្សា To studying | | | |
| 2.1.3- ផ្សេងៗ Other | | | |
| *2.2- ចំណាកស្រុកក្រៅប្រទេស Overseas migration* | | | |
| 2.2.1- ដើម្បីស្វែងរកការងារធ្វើ To seeking employment | | | |
| 2.2.2- ដើម្បីបន្តការសិក្សា To studying | | | |
| 2.2.3- ផ្សេងៗ Other | | | |

**សំណួរទី១.៨ ៖ ចំនួនខ្នងផ្ទះ និងមូលដ្ឋានបរិក្ខារ** Number of Houses and Access to basic facilities

| ប្រភេទខ្នងផ្ទះ Type of house | ចំនួនខ្នងផ្ទះ និងមូលដ្ឋានបរិក្ខារ No. of houses and access to basic facilities | | | | | |
|---|---|---|---|---|---|---|
| | ចំនួនខ្នងផ្ទះ No. of houses | អគ្គិសនី Electricity | ទូរទស្សន៍ TV | កុំព្យូទ័រ Computer | ទូរសព្ទដៃ Mobile phones | អ៊ីនធឺណិត Internet |
| 1- ផ្ទះដំបូលបេតុង Concrete roof houses | | | | | | |
| 2- ផ្ទះដំបូលក្បឿង Tiles roof houses | | | | | | |
| 3- ផ្ទះដំបូលស័ង្កសី / ហ្វីប្រូ Zinc roof houses | | | | | | |
| 4- ផ្ទះប្រក់ស្លឹក Thatched huts | | | | | | |
| 5- ផ្សេងៗ Other | | | | | | |
| ***សរុប Total*** | | | | | | |

** សំណួរទី១.៨៖ ចំនួនខ្នងផ្ទះសរុប គឺត្រូវតែស្មើ ឬតិចជាងចំនួនគ្រួសារសរុបនៅក្នុងភូមិ The total number of houses is equal to or less than the total number of households in the village.*

**សំណួរទី១.៩ ៖ បរិក្ខារដែលទាក់ទងការនឹងការដឹកជញ្ជូន គ្រឿងម៉ាស៊ីន និងយានយន្ត** Transportation, Machineries and Vehicles Related Equipment

| ប្រភេទបរិក្ខារ<br>Type of equipment | ចំនួនបរិក្ខារ<br>No. of equipment | ចំនួនគ្រួសារដែលមានបរិក្ខារ<br>No. of households having equipment | ភាគរយគ្រួសារមានបរិក្ខារ<br>Percentage of households having equipment |
|---|---|---|---|
| 1- ម៉ាស៊ីនភ្ជួររាស់ Ploughing machines | | | |
| 2- ម៉ាស៊ីនដាំដំណាំ Planting machine | | | |
| 3- ម៉ាស៊ីនប្រមូលផល Harvesting machines | | | |
| 4- គ្រឿងម៉ាស៊ីនកសិកម្មផ្សេងទៀត Other agricultural machines | | | |
| 5- ឧបករណ៍កសិកម្មផ្សេងទៀត (ក្រៅពីគ្រឿងម៉ាស៊ីន)<br>Other agricultural tools (Not mechanical) | | | |
| 6- រថយន្តដឹកអ្នកដំណើរ (តាក់ស៊ី និង១៥កៅអីចុះក្រោម)<br>Taxi and Vans | | | |
| 7- រថយន្តដឹកទំនិញ Loading trucks | | | |
| 8- រថយន្តក្រុង (ចាប់ពី២៥កៅអី) Buses | | | |
| 9- រថយន្តលក្ខណៈគ្រួសារ Cars | | | |
| 10- ម៉ូតូ Motorbikes | | | |
| 11- ម៉ូតូកង់បី Tri tier motorbike | | | |
| 12- រទេះអូសដោយដៃ Carts | | | |
| 13- រទេះគោ និងសេះ Ox and horse carts | | | |
| 14- ទូក Boats | | | |
| 15- ទូកដឹកអ្នកដំណើរ Passenger boats | | | |
| 16- ទូកនេសាទ Fishing boats | | | |
| 17- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify…) | | | |

**សំណួរទី១.១០ ៖ ទីកន្លែង និងចំនួនទារកកើត** The place and Number of Infant born

| ទីកន្លែងកើត<br>Place of birth | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|
| 1- មន្ទីរពេទ្យរដ្ឋ (បង្អែកខេត្ត ស្រុក ...) Government Hospital | | | |
| 2- មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព Health centers/Health Post | | | |
| 3- មន្ទីរពេទ្យ/គ្លីនិកឯកជន Private Clinic | | | |
| 4- ផ្ទះខ្លួនឯងដោយពេទ្យឆ្មប/ឆ្មបបុរាណ Private house by Nurse/Midwife | | | |
| 5- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | | | |
| *សរុប*<br>*Total* | | | |

**សំណួរទី១.១១ ៖ ចំនួនអ្នកស្លាប់នៅក្នុងភូមិតាមក្រុមអាយុ** Number of death in the village

| មូលហេតុចម្បងនៃការស្លាប់<br>Cause of Dead | សរុប<br>Total | ប្រុស<br>Male | | | | ស្រី<br>Female | | | |
|---|---|---|---|---|---|---|---|---|---|
| | | តិចជាង ៥ឆ្នាំ<br>Lest then 5years | ៥-១៧<br>5-17 | ១៨-៦៤<br>18-64 | ៦៥ ឆ្នាំ ឡើង<br>Over 65 years | តិចជាង ៥ឆ្នាំ<br>Lest then 5years | ៥–១៧<br>5-17 | ១៨–៦៤<br>18-64 | ៦៥ ឆ្នាំ ឡើង<br>Over 65 years |
| 1- ជំងឺ Disease | | | | | | | | | |
| 1.1- ជំងឺឆ្លង Cable Diseases | | | | | | | | | |
| 1.2- ជំងឺមិនឆ្លង Non-Cable Diseases | | | | | | | | | |
| 2- គ្រោះថ្នាក់ចរាចរណ៍ Traffic accident | | | | | | | | | |
| 3- លង់ទឹក Drowning | | | | | | | | | |
| 4- ពស់ចឹក Snakebites | | | | | | | | | |
| 5- ឃាតកម្ម Criminal | | | | | | | | | |
| 6- អត្តឃាត Suicide | | | | | | | | | |
| 7- គ្រាប់មិនទាន់ផ្ទុះ Unexploded ordnance | | | | | | | | | |
| 8- ផ្សេងៗ Other | | | | | | | | | |
| *សរុប*<br>*Total* | | | | | | | | | |

**សំណួរទី១.១២ ៖ ពិការភាពនៃបុគ្គល (ពីអតីតកាល រហូតដល់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣)** Disability of Persons

| ការពិពណ៌នា<br>Descriptions | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
|---|---|---|---|
| 1- បុគ្គលដែលរងគ្រោះដោយសារគ្រាប់មិនទាន់ផ្ទុះ<br>Persons victimized from Unexploded ordnance | | | |
| 2- ផ្ទៃដីដែលបានសំអាតគ្រាប់មិនទាន់ផ្ទុះ (ហិកតា)<br>Area cleared of Unexploded ordnance (ha) | | | |
| 3- មនុស្សចាស់ដែលគ្មានអ្នកមើលថៃ ឬគ្រួសារផ្គត់ផ្គង់<br>Old people without any protectors/family support | | | |
| 4- អនីតិជនដែលពិការ (អាយុក្រោម១៨ឆ្នាំ)<br>Disabled minors (less than 18 years old) | | | |
| 5- បុគ្គលពិការដែលមានប្រភពចំណូល (ដូចជាជាងកាត់សក់។ល។)<br>Disabled persons with sources of earnings (barbers, etc.) | | | |
| 6- បុគ្គលពិការដែលគ្មានចំណូល (នៅក្នុងបន្ទុក អង្គការចិញ្ចឹម។ល។)<br>Disabled persons without any income | | | |

**សំណួរទី១.១៣ ៖ ចំនួនគ្រួសារដែលលះលែងគ្នាតាមមុខរបរ (មេគ្រួសារ)** Number of Divorces by Occupational Groups (Head of households)

| ជំនាញ<br>Professions | ចំនួនគ្រួសារដែលលះលែងគ្នា<br>No. of divorces household |
|---|---|
| 1- អ្នកមានជំនាញវិជ្ជាជីវៈ Professionals | |
| 2- មន្ត្រីរាជការ Civil servants | |
| 3- អ្នកជំនួញ Business people | |
| 4- អ្នកនយោបាយ Politicians | |
| 5- ពលករ/កម្មករ Laborers | |
| 6- កសិកម្ម Agriculture | |
| 7- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | |
| *សរុប*<br>*Total* | |

**សំណួរទី១.១៤ ៖ ប្រភពទឹកជាចម្បងសម្រាប់ប្រើប្រាស់ និងទទួលទាន (ផឹក)** Main Sources of Using and Drinking Water

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារប្រើប្រាស់ទឹក<br>No. of households using water | ចំនួនគ្រួសារទទួលទានទឹក<br>No. of households drinking water |
|---|---|---|
| 1- ទឹកស្អាត ( ទុយោ ) Clean water ( piped ) | | |
| 2- ទឹកបរិសុទ្ធ Pure water | | |
| 3- ទឹកអណ្តូង Well water | | |
| 4- ទឹកភ្លៀង Rain water | | |
| 5- ទឹកស្រះ/បឹង/ស្ទឹង/ទន្លេ Ponds / lakes / rivers / streams water | | |
| 6- ផ្សេងៗ ( សូមបញ្ជាក់.... ) Other water ( Please specify… ) | | |
| ***សរុប<br>Total*** | | |

** សំណួរទី១.១៤៖ ប្រភពទឹកប្រើប្រាស់ ឬទឹកទទួលទាន គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបនៅក្នុងភូមិ Sources of using or drinking water is equal to the total number of households in the village.*

**សំណួរទី១.១៥ ៖ ប្រភពថាមពលជាចម្បងសម្រាប់ចម្អិនអាហារ** Main Energy consumption for cooking

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារ<br>No. of households |
|---|---|
| 1- អុស/ធ្យូង Fuel wood | |
| 2- ហ្គាស Gas | |
| 3- ឡជីវឧស្ម័ន Biogas plant | |
| 4- ភ្លើងអគ្គិសនី Electricity | |
| 5- ផ្សេងៗ Others | |
| ***សរុប<br>Total*** | |

** សំណួរទី១.១៥៖ សរុបការប្រើប្រាស់ថាមពលសម្រាប់ចម្អិនអាហារ គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបនៅក្នុងភូមិ Total of energy consumption for cooking is equal to the total number of households in the village.*

**សំណួរទី១.១៦ ៖ ការប្រើប្រាស់បង្គន់អនាម័យ** Using the toilets

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារ<br>No. of households |
|---|---|
| 1- គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យផ្ទាល់ខ្លួន Households with personal toilet for using | |
| 2- គ្រួសារដែលប្រើប្រាស់បង្គន់អនាម័យអ្នកជិតខាង Households with neighbors' toilet for using | |
| 3- គ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់ ( បន្ទោបង់ពាសវាល )<br>Households without toilet for using ( Outdoor defecation ) | |
| ***សរុប<br>Total*** | |

** សំណួរទី១.១៦៖ សរុបចំនួនគ្រួសារប្រើប្រាស់បង្គន់អនាម័យ គឺត្រូវតែស្មើនឹងចំនួនគ្រួសារសរុបនៅក្នុងភូមិ Total number of households using toilets is equal to the total number of households in the village.*

**សំណួរទី១.១៧ ៖ ប្រជាជនគ្មានផ្ទះសំបែង** Homeless people

| ការពិពណ៌នា<br>Descriptions | ចំនួន<br>Number |
|---|---|
| 1- គ្រួសារដែលរស់នៅលើដីសាធារណៈ Households living on public land | |
| 2- ប្រជាជនគ្មានផ្ទះសំបែង ( គិតជានាក់ ) Homeless people | |

**សំណួរទី១.១៨ ៖ គ្រោះធម្មជាតិ** Natural disasters

| គ្រោះធម្មជាតិ<br>Natural disasters | ចំនួនគ្រួសាររងផលប៉ះពាល់<br>No. of households affected | ផ្ទៃដីរងផលប៉ះពាល់ ( ហិកតា )<br>Areas affected ( ha ) |
|---|---|---|
| 1- ទឹកជំនន់ Flooding | | |
| 2- ដីបាក់ ឬស្រុត Land slides | | |
| 3- គ្រោះរាំងស្ងួត Drought | | |
| 4- ខ្យល់ព្យុះ/ខ្យល់កន្ត្រាក់ Storm / Twitch | | |
| 5- ផ្សេងៗ ( សូមបញ្ជាក់.... ) Other ( Please specify... ) | | |

**សំណួរទី១.១៩ ៖ ការគ្រប់គ្រងកាកសំណល់** Waste management

| ការពិពណ៌នា<br>Descriptions | ចំនួន<br>Number | ចំនួនផ្ទៃដី (ហិកតា)<br>Areas (ha) |
|---|---|---|
| 1- ទីតាំងចោលកាកសំណល់ទូទៅ General waste disposal site | | |
| 2- ទីតាំងចោលកាកសំណល់ឧស្សាហកម្ម Industrial waste disposal site | | |
| 3- ទីតាំងចោលកាកសំណល់សិប្បកម្ម Handicraft waste disposal site | | |
| 4- ទីតាំងចោលកាកសំណល់វេជ្ជសាស្ត្រ Medical waste disposal site | | |
| 5- គ្រួសារដែលប្រើប្រាស់សេវាប្រមូលសំរាម Households using garbage collection service | | |
| 6- គ្រួសារដែលគ្រប់គ្រងសំរាមដោយខ្លួនឯង (ដុត/កប់ចោល) Self-managed household waste (Burn / Bury) | | |
| 7- គ្រួសារដែលមិនបានគ្រប់គ្រងសំរាម (មិនបានទុកដាក់ត្រឹមត្រូវ) Households that do not manage garbage (not properly maintained) | | |
| 8- ធុងសំរាមតាមទីសាធារណៈ Bin in public site | | |

** ចំណាំ៖ សំណួរទី១.១៩ នៅចំណុច 2, 3, និង 4 គឺមិនរាប់បញ្ចូលទីតាំងដែលមានផ្លាល់នៅកន្លែងទាំងនោះឡើយ Points 2, 3, and 4 do not include locations that are directly located in those locations.*

**សំណួរ១.២០ ៖ ប្រភេទផ្ទៃដីនៅក្នុងភូមិ** Type of areas in the village

| ការពិពណ៌នា<br>Descriptions | ចំនួនផ្ទៃដី (ហិកតា)<br>Total area (ha) |
|---|---|
| 1- ផ្ទៃដីលំនៅឋាន Residential area | |
| 2- ផ្ទៃដីកសិកម្ម Agricultural area | |
| 3- ផ្ទៃដីព្រៃឈើ Forest area | |
| 4- ផ្ទៃដីដាំកូនឈើ Afforestation | |
| 5- ផ្ទៃដីកាប់ឆ្ការព្រៃឈើ Deforestation | |
| 6- ផ្ទៃដីបឹង/ទន្លេ Lake / River area | |
| 7- ផ្ទៃដីផ្សេងទៀត Other area | |
| *សរុប*<br>*Total* | |

# ផ្នែកទី២ ៖ សន្តិសុខសង្គម និង សេដ្ឋកិច្ច Social Security and Economics

**សំណួរទី២.១ ៖ សន្តិសុខសង្គម** Social Security

| ការពិពណ៌នា<br>Descriptions | ចំនួនករណីកើតឡើង<br>No. of occurrences | ចំនួនករណីដែលបានដោះស្រាយ No. of cases solved |
|---|---|---|
| 1- ប្លន់/ចាប់ជម្រិត Robbery / Kidnapping | | |
| 2- លួច Stealing | | |
| 3- ជម្លោះដីធ្លី Land Conflicts | | |
| 4- ប្រជាពលរដ្ឋទាស់ទែងគ្នា Civil conflicts | | |
| 5- ឃាតកម្ម/ឧក្រិដ្ឋកម្ម Murdering / Criminal Conflicts | | |

**សំណួរទី២.២ ៖ អំពើហិង្សាក្នុងគ្រួសារ និងការប្រើប្រាស់គ្រឿងញៀន** The domestic violence and using illegal drugs

| ការពិពណ៌នា<br>Descriptions | ចំនួនគ្រួសារ<br>No. of Household |
|---|---|
| 1- គ្រួសារដែលជួបអំពើហិង្សា<br>Households facing domestic violence | |
| 2- គ្រួសារដែលមានសមាជិកប្រើប្រាស់គ្រឿងញៀន<br>Households that have members using illegal drugs | |

**សំណួរទី២.៣ ៖ ស្ត្រីរងគ្រោះ** Victimization of Women

| ការពិពណ៌នា<br>Descriptions | ចំនួន (គិតជានាក់)<br>No. of victims | អាយុតិចជាង១៨ឆ្នាំ<br>Less than 18 years old | អាយុ ១៨ឆ្នាំឡើង<br>18 years old and above |
|---|---|---|---|
| 1- ចំនួនស្ត្រីដែលត្រូវបានគេចាប់រំលោភ<br>Number of raped women | | | |
| 2- ចំនួនស្ត្រីដែលត្រូវគេបានជួញដូរ<br>Number of trafficked women | | | |

**សំណួរទី២.៤៖ សកម្មភាពអាជីវកម្មចម្បងនៃគ្រួសារ** Households of major business activities

| សកម្មភាពអាជីវកម្ម<br>Business Activities | ចំនួនគ្រួសារ<br>No. of households | | | ចំនួនអ្នកធ្វើការ<br>No. of Worker | | |
|---|---|---|---|---|---|---|
| | សរុប<br>Total | ក្នុងភូមិ<br>In the village | ក្រៅភូមិ<br>Out the village | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| 1- ម៉ាស៊ីនកិនស្រូវ Milling | | | | | | |
| 2- លក់ និងជួសជុលម៉ូតូ/កង់<br>Selling and Motorbike / Bike repairing | | | | | | |
| 3- លក់ និងជួសជុលរថយន្ត<br>Selling and Vehicle repairing | | | | | | |
| 4- លក់ និងជួសជុលឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្ម<br>Selling and Agricultural tools / machinery repairing | | | | | | |
| 5- លក់ និងជួសជុលគ្រឿងអេឡិចត្រូនិច<br>Selling and Electronics repairing | | | | | | |
| 6- លក់ និងផលិតគ្រឿងសង្ហារិមពីឈើ<br>Selling and Woods furniture making | | | | | | |
| 7- លក់ និងផលិតគ្រឿងសង្ហារិមពីស៊ីម៉ងត៍<br>Selling and Cements furniture making | | | | | | |
| 8- លក់ និងផលិតគ្រឿងសង្ហារិមពីដែក/អ៊ីណុក<br>Selling and Steel / Stainless furniture making | | | | | | |
| 9- បិតស្រា Distillery | | | | | | |
| 10- ហាងកាត់សក់/អ៊ុតសក់/កែសម្ផស្ស Barbers / Salon | | | | | | |
| 11- ហាងលក់គ្រឿងទេស/កេសជ្ជៈ<br>Groceries / Beverage stores | | | | | | |
| 12- ហាងលក់ថ្នាំពេទ្យ និងគ្លីនិក<br>Pharmacies and Clinics | | | | | | |
| 13- សណ្ឋាគារ/ផ្ទះសំណាក់ Hotels / Guest Houses | | | | | | |
| 14- ភោជនីយដ្ឋាន Restaurants | | | | | | |
| 15- ស្ថានីយ៍ប្រេងឥន្ធនៈ Gasoline/Gas station | | | | | | |
| 16- តូបលក់សាំង Gasoline seller | | | | | | |
| 17- លក់គ្រឿងសំណង់ Construction equipment | | | | | | |
| 18- កាត់កញ្ចក់/ជាងដែក<br>Glass cutting machine / Blacksmith | | | | | | |
| 19- អាជីវកម្មផ្សេងៗទៀត (សូមបញ្ជាក់....)<br>Other businesses (Please specify...) | | | | | | |
| 20- មិនមានសកម្មភាពអាជីវកម្ម No business activities | | | | | | |

**សំណួរទី២.៥ ៖ ផលិតកម្ម សិប្បកម្ម/ឧស្សាហកម្ម និងការងារ** Industrial / Production and Employment

| ប្រភេទនៃសិប្បកម្ម/ឧស្សាហកម្ម<br>Type of Industries | ចំនួនសិប្បកម្ម/ឧស្សាហកម្ម<br>No. of Industries | ចំនួននិយោជិត<br>No. of Employee | | |
|---|---|---|---|---|
| | | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| 1- | | | | |
| 2- | | | | |
| 3- | | | | |
| 4- | | | | |
| 5- | | | | |
| 6- | | | | |
| 7- | | | | |
| 8- | | | | |
| 9- | | | | |
| 10- | | | | |

## ផ្នែកទី៣ ៖ វិស័យអប់រំ និង សេវាសង្គម Education and Social Services

**សំណួរទី៣.១ ៖ ចម្ងាយប៉ាន់ស្មានពីភូមិទៅកន្លែងផ្តល់សេវាកម្មជិតបំផុត** Proximity of Service Provider from Village Center

| ប្រភេទសេវាកម្ម<br>Service Providers | ចម្ងាយពីភូមិទៅកន្លែងផ្តល់សេវា (គីឡូម៉ែត្រ)<br>Distance from village center to service point ( Km ) | ចម្ងាយពីភូមិទៅកន្លែងផ្តល់សេវា កាលពី៥ឆ្នាំមុន (គីឡូម៉ែត្រ)<br>Distance from village center to service point, 5 years ago ( Km ) |
|---|---|---|
| *1- សាលារៀន School* | | |
| 1.1- មត្តេយ្យសិក្សា Pre-primary | | |
| 1.2- បឋមសិក្សា Primary | | |
| 1.3- អនុវិទ្យាល័យ Secondary | | |
| 1.4- វិទ្យាល័យ College | | |
| 1.5- សាកលវិទ្យាល័យ Universities | | |
| *2- ប្រភេទសុខាភិបាល Health facilities* | | |
| 2.1- មន្ទីរពេទ្យរដ្ឋ ( បង្អែកខេត្ត ស្រុក ...)<br>Government Hospital | | |
| 2.2- មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព<br>Health centers/Health Post | | |
| 2.3- គ្លីនិកឯកជន Clinic Private | | |
| 2.4-ឱសថស្ថាន Pharmacy | | |
| *3- ប្រភេទផ្សេងទៀត Other providers* | | |
| 3.1- មណ្ឌលពាណិជ្ជកម្ម/ផ្សារ<br>Market / Commercial center | | |
| 3.2- ប៉ុស្តិ៍នគរបាល Police station | | |
| 3.3- សាលាឃុំ Commune office | | |
| 3.4- ប្រៃសណីយ៍ (រដ្ឋ និងឯកជន) Post office | | |
| 3.5- អ៊ីនធឺណិតកាហ្វេ Cyber Cafe | | |

** សំណួរទី៣.១៖ ប្រសិនបើកន្លែងផ្តល់សេវាមាននៅក្នុងភូមិ នោះចម្ងាយប៉ាន់ស្មានគឺត្រូវដាក់លេខសូន្យ "0" If the service provider in the village, the estimated distance is "0".*

**សំណួរទី៣.២ ៖ សេខាអប់រំ** Education Levels

| ប្រភេទសាលារៀន<br>Type of Schools | ចំនួនសាលារៀន<br>No. of Schools | ចំនួនសិស្ស<br>No. of Students | | | ចំនួនគ្រូ<br>No. of Teachers | | |
|---|---|---|---|---|---|---|---|
| | | សរុប<br>Total | ប្រុស<br>Boy | ស្រី<br>Girl | សរុប<br>Total | បុរស<br>Male | ស្ត្រី<br>Female |
| *1- មត្តេយ្យសិក្សា Pre-primary* | | | | | | | |
| 1.1- រដ្ឋ Government | | | | | | | |
| 1.2- ឯកជន Private | | | | | | | |
| 1.3- សហគមន៍ Association | | | | | | | |
| *2- បឋមសិក្សា Primary* | | | | | | | |
| 2.1- រដ្ឋ Government | | | | | | | |
| 2.2- ឯកជន Private | | | | | | | |
| *3- អនុវិទ្យាល័យ Secondary* | | | | | | | |
| 3.1- រដ្ឋ Government | | | | | | | |
| 3.2- ឯកជន Private | | | | | | | |
| *4- វិទ្យាល័យ Colleges* | | | | | | | |
| 4.1- រដ្ឋ Government | | | | | | | |
| 4.2- ឯកជន Private | | | | | | | |
| *5- សាកលវិទ្យាល័យ Universities* | | | | | | | |
| 5.1- រដ្ឋ Government | | | | | | | |
| 5.2- ឯកជន Private | | | | | | | |
| ***សរុប<br>Total*** | | | | | | | |

**សំណួរទី៣.៣ ៖ សកម្មភាពបណ្តុះបណ្តាល និងអភិវឌ្ឍន៍** Training and development activities

| សកម្មភាព<br>Activities | ចំនួន (ដង)<br>Number (Times) |
|---|---|
| 1- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ Infra-structural development | |
| 2- ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ Irrigation development | |
| 3- ការអភិវឌ្ឍផ្នែកកសិកម្ម Agriculture development | |
| 4- ការអភិវឌ្ឍផ្នែកឧស្សាហកម្ម Industrial development | |
| 5- ការអភិវឌ្ឍផ្នែកសិប្បកម្ម Crafts development | |
| 6- ការបណ្តុះបណ្តាលពីការដាំដំណាំ Crop training | |
| 7- ការបណ្តុះបណ្តាលពីការចិញ្ចឹមបសុសត្វ/បសុបក្សី Livestock / Poultry training | |
| 8- ការបណ្តុះបណ្តាលពីការនេសាទ Fishing training | |
| 9- ការបណ្តុះបណ្តាលពីការធ្វើវារីវប្បកម្ម Aquaculture training | |
| 10- ការបណ្តុះបណ្តាល/ផ្សព្វផ្សាយពីការដាំកូនឈើ និងការពារព្រៃឈើ Training / dissemination of tree planting and forest protection | |
| 11- ការបណ្តុះបណ្តាល/ផ្សព្វផ្សាយពីការថែទាំសុខភាព Health Care Training / Outreach | |
| 12- ការបណ្តុះបណ្តាល/ផ្សព្វផ្សាយពីច្បាប់ចរាចរណ៍ Traffic Law Training / Dissemination | |
| 13- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | |

**សំណួរទី៣.៣ ៖ ការស្ថាបនាផ្លូវថ្នល់ក្នុងរយៈពេល ៥ ឆ្នាំកន្លងមក** Road construction in the last 5 years

| ប្រភេទផ្លូវថ្នល់<br>Type of Roads | ប្រវែងផ្លូវថ្នល់បានស្ថាបនា (គីឡូម៉ែត្រ)<br>Length of Roads (Km) |
|---|---|
| 1- ថ្នល់កៅស៊ូ Metaled Road | |
| 2- ថ្នល់បេតុង Concrete Road | |
| 3- ថ្នល់គ្រួស Graveled Road | |
| 4- ថ្នល់ដី Non-graveled Road | |
| *សរុប*<br>*Total* | |

# ផ្នែកទី៤ ៖ សុខាភិបាល Health

**សំណួរទី៤.១ ៖ សេវាកម្មសុខភាព** Health services

| ប្រភេទសុខាភិបាល / សេវាកម្ម<br>Type of Health / Services | ចំនួន<br>Numbers |
|---|---|
| 1- មន្ទីរពេទ្យរដ្ឋ ( បង្អែកខេត្ត ស្រុក ...) Government Hospital | |
| 2- មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព Health centers/Health Post | |
| 3- មន្ទីរពេទ្យ/គ្លីនិកឯកជន Private clinic | |
| 4- បន្ទប់ពិគ្រោះ/ថែទាំអ្នកជំងឺ Consultation / Care Room | |
| 5- ឱសថស្ថាន Pharmacy | |
| 6- វេជ្ជបណ្ឌិត Doctors | |
| 7- ពេទ្យមធ្យម Health assistants | |
| 8- គិលានុបដ្ឋាយិកា ឬឆ្មប Nurses/Midwives | |
| 9- ឆ្មបបុរាណ Traditional midwives | |

**សំណួរទី៤.២ ៖ ជំងឺចម្បងទូទៅ** Prevalence of major diseases

| ការពិពណ៌នា<br>Descriptions | ចំនួនករណី<br>No. of Cases | | |
|---|---|---|---|
| | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| *1- គ្រុនចាញ់ Malaria* | | | |
| 1.1- ចំនួនករណីកើតជំងឺគ្រុនចាញ់ No. of Malaria cases | | | |
| 1.2- ចំនួនស្លាប់ដោយជំងឺគ្រុនចាញ់ No. of Malaria deaths | | | |
| *2- របេង TB* | | | |
| 2.1- ចំនួនករណីកើតជំងឺរបេង No. of TB cases | | | |
| 2.2- ចំនួនស្លាប់ដោយជំងឺរបេង No. of TB deaths | | | |

**សំណួរទី៤.៣ ៖ ចំនួនអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ តាមក្រុមអាយុ** Number of HIV / AIDS by Age Group

| ក្រុមអាយុ<br>Age group | ចំនួនអ្នកកើតជំងឺអេដស៍<br>Number of AIDS | | | ចំនួនអ្នកស្លាប់ដោយជំងឺអេដស៍<br>Number of Death from AIDS | | |
|---|---|---|---|---|---|---|
| | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female | សរុប<br>Total | ប្រុស<br>Male | ស្រី<br>Female |
| 1- ( ០-១៧ ឆ្នាំ ) 0-17 years | | | | | | |
| 2- ( ១៨-២៥ ឆ្នាំ ) 18-25 years | | | | | | |
| 3- ( ២៦-៥៩ ឆ្នាំ ) 26-59 years | | | | | | |
| 4- ( ៦០ ឆ្នាំឡើង ) 60 over years | | | | | | |
| *សរុប*<br>*Total* | | | | | | |

**សំណួរទី៤.៤ ៖ បុគ្គលរងផលប៉ះពាល់ពីអ្នកមានជំងឺអេដស៍ ឬផ្ទុកមេរោគអេដស៍ និងកុមារកំព្រា** Individuals affected by people living with HIV / AIDS and Orphans

| ការពិពណ៌នា<br>Descriptions | ចំនួនមនុស្ស<br>No. of People |
|---|---|
| 1- បុគ្គលរងផលប៉ះពាល់ពីអ្នកមានជំងឺអេដស៍ ឬផ្ទុកមេរោគអេដស៍<br>Individuals affected by people living with HIV / AIDS | |
| 2- កុមារកំព្រា (អាយុក្រោម១៨ឆ្នាំ) ដែលឪពុកម្តាយបានស្លាប់ដោយជំងឺអេដស៍<br>Orphans ( less than 18 years old ) whose parents died with HIV / AIDS | |
| 3- កុមារកំព្រា (អាយុក្រោម១៨ឆ្នាំ) ដែលមានអ្នកមើលថៃត្រឹមត្រូវ<br>Orphans ( less than 18 years old ) who have legal protector | |
| 4- កុមារកំព្រា (អាយុក្រោម១៨ឆ្នាំ) ដែលគ្មានអ្នកមើលថៃត្រឹមត្រូវ<br>Orphans ( less than 18 years old ) who do not have legal protector | |

# ផ្នែកទី៥ ៖ កសិកម្ម Agriculture

**សំណួរទី៥.១ ៖ ការកាន់កាប់ដីកសិកម្ម** Landholding and Agricultural land

| ទំហំផ្ទៃដី<br>Size of landholding | ចំនួនគ្រួសារ<br>No. Households |
|---|---|
| 1- ( គ្មានដី ) Landless | |
| 2- ( តិចជាង១ហិកតា ) <1 ha | |
| 3- ( ១-១,៩៩ហិកតា ) 1-1.99 ha | |
| 4- ( ២-២,៩៩ហិកតា ) 2-2.99 ha | |
| 5- ( ៣-៣,៩៩ហិកតា ) 3-3.99 ha | |
| 6- ( ៤-៤,៩៩ហិកតា ) 4-4.99 ha | |
| 7- ( ៥ហិកតាឡើង ) More than or 5 ha | |
| *សរុប ( ត្រូវស្មើនឹងចំនួនគ្រួសារក្នុងភូមិ )*<br>*Total ( Must be equal to the households in the village )* | |

**សំណួរទី៥.២ ៖ ផ្ទៃដីកសិកម្មដែលមាន និងផ្ទៃដីដែលបានដាំដុះ** Agricultural and Cultivated land

| ផ្ទៃដីដែលមាន (ហិកតា)<br>Area in hectares | | | ផ្ទៃដីបានដាំដុះ (ហិកតា)<br>Production in hectare | | |
|---|---|---|---|---|---|
| រដូវប្រាំង<br>Dry season | រដូវវស្សា<br>Wet season | ទាំងពីររដូវ<br>Multi -season | រដូវប្រាំង<br>Dry season | រដូវវស្សា<br>Wet season | ទាំងពីររដូវ<br>Multi-season |
| | | | | | |

**សំណួរទី៥.៣ ៖ ស្ថានភាពប្រព័ន្ធស្រោចស្រព** Irrigation status

| ប្រព័ន្ធស្រោចស្រព<br>Irrigation status | ផ្ទៃដីបានដាំដំណាំ (ហិកតា)<br>Cropped area ( ha ) | | |
|---|---|---|---|
| | សរុប<br>Total | ដំណាំស្រូវ<br>Paddy | ដំណាំផ្សេង<br>Other crops |
| 1- មានប្រព័ន្ធស្រោចស្រព Irrigated | | | |
| 2- គ្មានប្រព័ន្ធស្រោចស្រព Non-Irrigated | | | |

**សំណួរទី៥.៤ ៖ ការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វចង្រៃក្នុងកសិកម្ម** Fertilizers and Insecticides using in Agricultural

| ប្រភេទជី និង ថ្នាំសម្លាប់សត្វចង្រៃ<br>Types fertilizers and Insecticides | ផ្ទៃដីបានដាំដំណាំ (ហិកតា)<br>Cropped area (ha) | | |
|---|---|---|---|
| | សរុប<br>Total | ដំណាំស្រូវ<br>Paddy | ដំណាំផ្សេង<br>Other crops |
| 1- ជីគីមី Inorganic fertilizers | | | |
| 2- ជីសរីរាង្គ Organic fertilizers | | | |
| 3- ថ្នាំសម្លាប់សត្វចង្រៃ Pesticides | | | |
| 4- ថ្នាំសម្លាប់ផ្សិត Fungicides | | | |
| 5- ថ្នាំសម្លាប់ស្មៅ Herbicides | | | |
| 6- ផ្សេងៗ (សូមបញ្ជាក់....) Other (Please specify...) | | | |

**សំណួរទី៥.៥ ៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី** Livestock and Poultry holdings

| ប្រភេទនៃបសុសត្វ និងបសុបក្សី<br>Type of Livestock and poultry | ចំនួនគ្រួសារ<br>No. Households | ចំនួនសត្វ<br>No. of animals | ចំនួនសត្វ/គ្រួសារ<br>No. of animals/ Households |
|---|---|---|---|
| 1- គោ Cattles | | | |
| 2- ក្របី Buffalo | | | |
| 3- សេះ Horses | | | |
| 4- ជ្រូក Pigs | | | |
| 5- ពពែ/ចៀម Goat / Sheep | | | |
| 6- មាន់ Chicken | | | |
| 7- ទា Ducks | | | |
| 8- ក្រួច Quail | | | |
| 9- ត្រចៀកកាំ Swallow | | | |
| 10- សត្វល្អិត Insects | | | |
| 11- ផ្សេងៗ (សូមបញ្ជាក់....)<br>Other (Please specify...) | | | |

**សំណួរទី៥.៦ ៖ ការធ្វើវារីវប្បកម្ម** Aquaculture

| វារីវប្បកម្ម<br>Aquaculture | ចំនួនគ្រួសារ<br>No. of Households | ចំនួនស្រះ<br>No. of ponds | បរិមាណផលមធ្យម (តោន/ស្រះ) Average Yield rate (t/pond) | ចំនួនប្រមូលផល/ឆ្នាំ<br>No. of harvests / year | បរិមាណផល (តោន/ឆ្នាំ) No. of Production (ton/Year) | បរិមាណផល/គ្រួសារ<br>Production / Households |
|---|---|---|---|---|---|---|
| 1- ត្រី Fish | | | | | | |
| 2- បង្គារ Shrimp | | | | | | |
| 3- បង្កង Lobster | | | | | | |
| 4- ក្រពើ Crocodile | | | | | | |
| 5- កង្កែប Frog | | | | | | |
| 6- អន្ទង់ Eel | | | | | | |
| 7- ផ្សេងៗ (សូមបញ្ជាក់....)<br>Other (Please specify…) | | | | | | |

** សំណួរទី៥.៧៖ ចំនួនបរិមាណផល ប្រសិនបើមិនទាន់ប្រមូលផល សូមចុះសូន្យ "0" Please fill "0" At the amount of yield, If not yet harvested.*

**សំណួរទី៥.៧ ៖ ផ្ទៃដី និងផលិតកម្មនៃដំណាំសំខាន់ៗ** Area and Production of Major crops

| ដំណាំ<br>Crops | ផ្ទៃដី (ហិកតា) Area (ha) | ទិន្នផលមធ្យម (តោន/ហិកតា) Average Yield rate (t/ha) | ចំនួនប្រមូលផល/ឆ្នាំ<br>No. of harvests / year | បរិមាណផលិតកម្ម (តោន) Estimated production (ton) | គោលបំណង<br>Purposes | | |
|---|---|---|---|---|---|---|---|
| | | | | | ហូប/ប្រើប្រាស់<br>For home Consumption (%) | លក់<br>For sale (%) | ផ្សេងៗ<br>For other (%) |
| 1- ស្រូវ Paddy | | | | | | | |
| 2- ពោត Corn | | | | | | | |
| 3- សណ្តែកសៀង Soybean | | | | | | | |
| 4- សណ្តែកបាយ Green gram | | | | | | | |
| 5- សណ្តែកដី Peanuts | | | | | | | |
| 6- ដំឡូងមី Cassava | | | | | | | |
| 7- ដំឡូងជ្វា Sweet Potato | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 8- ល្ង Sesame | | | | | | | |
| 9- ម្រេច Black Pepper | | | | | | | |
| 10- ស្វាយចន្ទី Cashew nuts | | | | | | | |
| 11- កៅស៊ូ Rubber | | | | | | | |
| 12- ចេក Banana | | | | | | | |
| 13- ក្រូច Orange | | | | | | | |
| 14- មៀន Longan | | | | | | | |
| 15- សាវម៉ៅ Rambutan | | | | | | | |
| 16- ស្វាយ Mango | | | | | | | |
| 17- ល្ហុង Papaya | | | | | | | |
| 18- ទុរេន Durian | | | | | | | |
| 19- ប៊ឺរ Avocado | | | | | | | |
| 20- អំពៅ Sugar Cane | | | | | | | |
| 21- ខ្នុរ Jackfruit | | | | | | | |
| 22- ផ្សេងៗ Other crops | | | | | | | |

# ឧបសម្ព័ន្ធ២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ**: ១៤៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦៤ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេរគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដឹកនាំស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច
## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការនិងមានគោលដៅកំណត់អំពីបេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ ដូចខាងក្រោម៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ក្រសួងផែនការ
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានាក្រោមឱវាទក្រសួងផែនការ
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារក្នុងវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងផែនការ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ដោយគ្របដណ្ដប់លើវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូក ២
## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ៣.-**

ក្រសួងផែនការបំពេញមុខងារជាសេនាធិការជូនរាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ សម្របសម្រួល និងគ្រប់គ្រងលើវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ដោយធានាគុណភាព និងប្រសិទ្ធភាព ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ។

បេសកកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវស្របតាមគោលនយោបាយក្របខ័ណ្ឌច្បាប់និងបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

ក្រសួងផែនការមានមុខងារ និងភារកិច្ចដូចតទៅ ៖

- ធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ រៀបចំ កំណត់ចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ និងអាទិភាពនានាសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ ដោយឈរលើមូលដ្ឋាននៃការបង្កើតឱ្យមាននិរន្តរភាព និងតុល្យភាព រវាងការអភិវឌ្ឍ និងសមភាពនិងសមធម៌ និងយុត្តិធម៌ក្នុងសង្គម ដោយគិតគូរអំពីទំនាក់ទំនងរវាងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន
- ដឹកនាំ និងរៀបចំផែនការ ស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានាពាក់ព័ន្ធនឹងវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ តាមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស

២/៣៤

- ដឹកនាំការវាស់វែង និងវិភាគអំពីភាពក្រីក្រនៅកម្ពុជា និងការវិភាគផ្សេងៗដែលពាក់ព័ន្ធនឹងឌីណាមិកប្រជាសាស្ត្រ
- ដឹកនាំធ្វើជំរឿនប្រជាជន ជំរឿនសេដ្ឋកិច្ច ជំរឿនកសិកម្ម និងជំរឿនផ្សេងៗទៀតតាមតម្រូវការចាំបាច់របស់ប្រទេស និងអនុលោមតាមច្បាប់ស្តីពីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា
- ដឹកនាំធ្វើអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា អង្កេតប្រជាសាស្ត្រនិងសុខភាព អង្កេតកសិកម្ម អង្កេតកម្លាំងពលកម្ម អង្កេតមនុស្សចាស់ និងអង្កេតផ្សេងៗទៀតតាមតម្រូវការចាំបាច់របស់ប្រទេស និងអនុលោមតាមច្បាប់ស្តីពីស្ថិតិនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងព័ត៌មានស្ថិតិសេដ្ឋកិច្ចសង្គមកិច្ច និងប្រជាសាស្ត្រក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- គ្រប់គ្រងប្រព័ន្ធមូលដ្ឋានទិន្នន័យជាតិ
- រៀបចំផែនការ និងកម្មវិធីជាតិសម្រាប់កិច្ចអភិវឌ្ឍរយៈពេលខ្លី មធ្យម និងវែង ដោយសម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាថាផែនការ និងកម្មវិធីជាតិទាំងនោះមានសង្គតិភាពជាមួយគ្នា រវាងបណ្តាវិស័យសេដ្ឋកិច្ច សង្គមកិច្ច ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- ផ្តួចផ្តើមនិងលើកសំណើជូនរាជរដ្ឋាភិបាល ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំនិងកែសម្រួលគោលនយោបាយ ផែនការអភិវឌ្ឍន៍ យុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីគាំទ្រដល់កម្មវិធីសកម្មភាពនិងគោលនយោបាយនានាឆ្លើយតបទៅនឹងសេចក្តីសម្រេច និងអនុសញ្ញានានារបស់អង្គការសហប្រជាជាតិ
- តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការ កម្មវិធីជាតិ និងបណ្តាគម្រោងពីគ្រប់ផ្នែកទាំងអស់ ហើយវាយតម្លៃលទ្ធផលនៃការអនុវត្ត និងលើកឡើងពីវិធានការកែតម្រូវផែនការ កម្មវិធីជាតិក្នុងករណីចាំបាច់
- សិក្សាស្រាវជ្រាវអំពីស្ថានភាពសង្គម-សេដ្ឋកិច្ច សង្គម-ប្រជាសាស្ត្រ សង្គម-វប្បធម៌ និងសង្គម-បរិស្ថាន ដើម្បីបម្រើឱ្យវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ សម្រាប់ផលប្រយោជន៍សាធារណៈ និងសង្គមជាតិ
- ផ្តល់ជំនួយខាងផ្នែកបច្ចេកទេស និងវិធីសាស្ត្រ ឬអនុវត្តការធ្វើជំរឿន និងអង្កេតតាមវិស័យ និងប្រធានបទនានាតាមសំណូមពររបស់អ្នកប្រើប្រាស់ទិន្នន័យស្ថិតិ
- ចងក្រងស្ថិតិគណនេយ្យជាតិ ស្ថិតិថ្លៃ គណនីរណប សេដ្ឋកិច្ចជាតិ និងសៀវភៅកម្រង ស្ថិតិរបស់កម្ពុជាប្រចាំ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីកំណត់អាទិភាពក្នុងការវិនិយោគទាំងសាធារណៈ ទាំងឯកជនដោយប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាពនូវសក្តានុពលនៃធនធានទាំងក្នុង ទាំងក្រៅប្រទេស
- សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកំណត់បរិមាណធនធានសរុបនិងភោជនីយវិនិយោគសាធារណៈប្រចាំឆ្នាំ

៣/៣៤

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងកំណត់អាទិភាពក្នុងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាមួយដៃគូអភិវឌ្ឍន៍ឱ្យមានសង្គតិភាពជាមួយនឹងទិសដៅ និងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍជាតិ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំគោលនយោបាយប្រជាសាស្ត្រ ការផ្លាស់ប្តូរទីលំនៅ និងផែនការសកម្មភាពស្តីពីការបែងចែកកម្លាំងពលកម្មសង្គមឱ្យមានតុល្យភាព ធានាដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការការពារជាតិ
- សហការដោះដូរព័ត៌មានស្ថិតិជាមួយអង្គភាពស្ថិតិជាតិនៃប្រទេសក្នុងតំបន់ ក្នុងពិភពលោក និងបណ្ដាអង្គការជាតិ អង្គការអន្តរជាតិ
- បំពេញមុខងារ និងភារកិច្ចចាំបាច់ផ្សេងទៀតតាមការប្រគល់ជូនពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា ៥.-**

ក្រសួងផែនការមានរចនាសម្ព័ន្ធដូចតទៅ ៖

ក. អង្គភាពថ្នាក់ជាតិ

១. ខុទ្ទកាល័យ

២. អគ្គនាយកដ្ឋានកិច្ចការទូទៅ

៣. អគ្គនាយកដ្ឋានផែនការ

៤. វិទ្យាស្ថានជាតិស្ថិតិ

៥. អគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍន៍

៦. អគ្គាធិការដ្ឋាន

៧. នាយកដ្ឋានសវនកម្មផ្ទៃក្នុង

៨. អង្គភាពលទ្ធកម្ម

៩. សាលាជាតិផែនការ និងស្ថិតិ

ខ. អង្គភាពថ្នាក់ក្រោមជាតិ

- មន្ទីរផែនការរាជធានី ខេត្ត

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន វិទ្យាស្ថាន ដឹកនាំដោយអគ្គលេខាធិការ/អគ្គនាយកមួយរូប និងអមដោយអគ្គលេខាធិការរង/អគ្គនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សាលាជាតិផែនការ និងស្ថិតិ ដឹកនាំដោយនាយកមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយនាយករងមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មហាវិទ្យាល័យដឹកនាំដោយព្រឹទ្ធបុរសមួយរូបមានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយព្រឹទ្ធបុរសរងមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មជ្ឈមណ្ឌលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនមានឋានៈស្មើអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

មន្ទីរផែនការរាជធានី ខេត្ត ដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់ក្រសួងផែនការជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

**មាត្រា ៧.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ និងអង្គភាពនានាក្រោមឱវាទនាយកដ្ឋាន សាលាជាតិផែនការ និងស្ថិតិ និងមន្ទីរផែនការរាជធានី ខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

## ជំពូក ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៨.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលមានកំណត់ក្នុងអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន និង អនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាននិងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូក ៤
## អគ្គនាយកដ្ឋានកិច្ចការទូទៅ

**មាត្រា ៩.-**

អគ្គនាយកដ្ឋានកិច្ចការទូទៅមានតួនាទី និងភារកិច្ចដូចតទៅ៖

- ដឹកនាំ គ្រប់គ្រងការងាររដ្ឋបាល និងសម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់ជាតិ និងរវាងអង្គភាពថ្នាក់ជាតិនិងអង្គភាពថ្នាក់ក្រោមជាតិ
- គ្រប់គ្រង កិច្ចការរដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ បដិសណ្ឋារកិច្ច ការងារសន្តិសុខផ្ទៃក្នុង និងសម្របសម្រួលការងារទូទៅជាមួយបណ្ដាក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា
- គ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សរបស់ក្រសួង
- គ្រប់គ្រង និងសម្របសម្រួលរាល់ការចំណាយរបស់ក្រសួងទៅតាមខ្ទង់ជំពូកថវិកា និងគ្រប់គ្រងការងារគណនេយ្យ និងហិរញ្ញវត្ថុ

- គ្រប់គ្រង និងសម្របសម្រួលការងារលទ្ធកម្មសាធារណៈ
- គ្រប់គ្រងសន្និធិសម្ភារៈបរិក្ខា ទ្រព្យសម្បត្តិ ចលនទ្រព្យ អចលនទ្រព្យ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងបណ្ណសាររបស់ក្រសួង
- គ្រប់គ្រង និងចាត់ចែងការងារសង្គមកិច្ចសម្រាប់មន្ត្រីរាជការ
- គ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពទូទៅក្នុងទីស្តីការក្រសួង
- អភិវឌ្ឍន៍ រៀបចំ និងគ្រប់គ្រងបណ្តាញបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន និងគេហទំព័រនៅថ្នាក់កណ្តាល និង អង្គភាពថ្នាក់ក្រោមជាតិ
- សហការ សម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចប្រតិបត្តិការទាំងថ្នាក់ជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍ
- រៀបចំលិខិតរដ្ឋបាល និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធ
- ទទួលខុសត្រូវ និងសម្របសម្រួលរៀបចំផែនការថវិការយៈពេលខ្លី មធ្យម និងវែងរបស់ក្រសួង
- ស្រាវជ្រាវ ដកស្រង់ ចងក្រង និងផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត សន្ធិសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ និងគ្រប់គ្រងរក្សាលិខិតបទដ្ឋានគតិយុត្តនានាដូចជា សេចក្តីសម្រេច ប្រកាស សារាចរ អនុក្រឹត្យ ព្រះរាជក្រឹត្យ ច្បាប់ និងកិច្ចព្រមព្រាងផ្សេងៗ
- សម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង
- សម្របសម្រួលជាមួយអង្គភាពនានាជាប្រចាំដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រសួង
- ណែនាំ និងតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ
- ទទួលបន្ទុកសម្របសម្រួលជាមួយមន្ទីរផែនការ រាជធានី ខេត្ត ដែលតំណាងឱ្យក្រសួងផែនការនៅថ្នាក់ក្រោមជាតិ
- សម្របសម្រួលដោះស្រាយវិវាទក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- រៀបចំរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំក្រសួង និងរាជរដ្ឋាភិបាល
- ទទួលអនុវត្តន៍ភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។
- អគ្គនាយកដ្ឋានកិច្ចការទូទៅ មាននាយកដ្ឋានចំនួន៥ ចំណុះ ដូចខាងក្រោម៖

**មាត្រា ១០.-**

នាយកដ្ឋានរដ្ឋបាលទូទៅ មានភារកិច្ច ដូចតទៅ៖

- គ្រប់គ្រង និងចរាចរណ៍ឯកសាររដ្ឋបាល និងឯកសារផ្សេងៗ របស់ក្រសួងតាមច្រកចេញចូលតែមួយ
- ទទួលបន្ទុកសម្របសម្រួលការងាររដ្ឋបាលនៅថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិស្ថិតក្រោមឱវាទក្រសួងផែនការ និងស្ថាប័នពាក់ព័ន្ធ
- ជានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល
- ស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានពាក់ព័ន្ធការងាររដ្ឋបាល

- សម្របសម្រួលរៀបចំកិច្ចប្រជុំ និងការងារបដិសណ្ឋារកិច្ច
- រៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនក្រសួង និងរាជរដ្ឋាភិបាល
- រៀបចំតម្កល់ឯកសារ និងគ្រប់គ្រងបណ្ណាល័យ
- គ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពទូទៅក្នុងទីស្តីការក្រសួង
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ១១.-**

នាយកដ្ឋានបុគ្គលិក មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងមន្ត្រីរាជការរបស់ក្រសួងផែនការ ដោយទំនាក់ទំនងជាមួយនឹងក្រសួងមុខងារសាធារណៈ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រងមន្ត្រីរាជការតាមរយៈទិន្នន័យរដ្ឋបាល និងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំសំណុំឯកសារសម្រាប់គ្រប់គ្រងអាជីពមន្ត្រីរាជការ មានជាអាទិ៍ ការតែងតាំង ការតាំងស៊ប់ ការផ្ទេរ ផ្លាស់ប្តូរកន្លែងធ្វើការ ការតំឡើងឋានៈ ឋានន្តរស័ក្តិ ការលើកសរសើរ ជូនគ្រឿងឥស្សរិយយស ការដាក់វិន័យ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការរៀបចំសំណុំឯកសារចូលនិវត្តន៍ និងការបាត់បង់សម្បទាវិជ្ជាជីវៈ
- ធ្វើកម្មវិធីតំណែង ឯកទេស និងធនធានមនុស្សរបស់ក្រសួង
- រៀបចំគោលនយោបាយ និងផែនការបណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្សក្រោមឱវាទក្រសួងផែនការ
- រៀបចំជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មីដោយផ្អែកតាមតម្រូវការ និងជំនាញជាក់ស្តែង ផ្លាស់ប្តូរប្រភេទក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យា
- រៀបចំធ្វើវិក្រឹតការ និងសុក្រឹតការចំពោះមន្ត្រីរាជការរបស់ក្រសួង
- ទទួលបន្ទុកសម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដឹកនាំ គ្រប់គ្រង សម្របសម្រួល និងគាំទ្រដល់ការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការរបស់ក្រសួង
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ១២.-**

នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ៖

- រៀបចំ និងសម្របសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំ ទាំងរដ្ឋបាលថ្នាក់ជាតិ ទាំងអង្គភាពថ្នាក់ក្រោមជាតិ ក្រោមឱវាទក្រសួង
- ធ្វើអាណាប័កផ្ទេរសិទ្ធ ការងារនិយ័តភាពថវិកា គម្រោងស្នើសុំថវិកាបន្ថែម សម្រាប់ទាំងរដ្ឋបាលថ្នាក់ជាតិ ទាំងអង្គភាពថ្នាក់ក្រោមជាតិ ក្រោមឱវាទក្រសួង

- ចូលរួមអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រោម ឱវាទក្រសួងផែនការ
- សម្របសម្រួលរៀបចំផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអនុវត្តក្រោមឱវាទក្រសួងផែនការ
- តាមដាននិងសម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំ និងអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសំរាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើកិច្ចការវិភាជន៍ថវិកា អនុវត្តការស្នើសុំ និងទូទាត់ចំណាយថវិកា
- ប្រមូលផ្តុំ និង សម្របសម្រួលរាល់ការចំណាយថវិការបស់អង្គភាពក្រោមឱវាទក្រសួង តាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់
- តាមដាននិងត្រួតពិនិត្យការអនុវត្តចំណាយតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់ អង្គភាពថវិកានិមួយៗ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- សម្របសម្រួលរាល់សកម្មភាពទាំងឡាយពាក់ព័ន្ធនឹងចំណាយថវិកាជាតិរបស់ក្រសួងផែនការ
- គាំទ្រការអនុវត្តការងាររបស់អង្គភាពថវិកា ដើម្បីធានាបាននូវនិរន្តរភាពការងារ ចំណូលចំណាយ រដ្ឋទេយ្យបុរេប្រទាន ចំណាយបេសកកម្មក្នុង និងក្រៅប្រទេស និងចំណាយទូទៅផ្សេងៗរបស់ក្រសួង
- រៀបចំរបាយការណ៍សកម្មភាពការងារ ចំណាយសាច់ប្រាក់ សមិទ្ធិកម្មប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំកម្មវិធីចំណូល-ចំណាយប្រចាំខែ ត្រីមាស និងឆ្នាំ
- ត្រួតពិនិត្យ និងគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ និងសន្និធិសម្ភារៈ ថែទាំជួសជុលទ្រព្យសម្បត្តិរដ្ឋ និងបែងចែកសម្ភារបរិក្ខាជូនគ្រប់អង្គភាពក្រោមឱវាទក្រសួងផែនការ
- ប្រមូលផ្តុំតម្រូវការ និងធ្វើកម្មវិធីចំណាយគ្រប់គ្រងការជួសជុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងយានយន្ត និងយានជំនិះ របស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងរៀបចំប្រើប្រាស់ប្រេងឥន្ធនៈ
- ពិនិត្យ ផ្ទៀងផ្ទាត់ អង្កេត និងតាមដានកិច្ចបញ្ជីការស្តុកឃ្លាំងជាប្រចាំ
- បណ្តុះបណ្តាលដល់មន្ត្រីរាជការរបស់អង្គភាពថវិកា ទាំងរដ្ឋបាលថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិក្រោមឱវាទក្រសួងផែនការ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ១៣.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ៖

- សហការ សម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចប្រតិបត្តិការផ្ទៃក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍ
- សិក្សា វិភាគ និងវាយតម្លៃលើទិដ្ឋភាពនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងបណ្តាប្រទេសជាមិត្ត និងអន្តរជាតិ ព្រមទាំងលើកទិសដៅសហប្រតិបត្តិការទ្វេភាគី

និង ពហុភាគី ក្នុងវិស័យផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍ សំដៅជំរុញការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ក្នុងការផ្លាស់ប្តូរព័ត៌មានក្នុងក្របខ័ណ្ឌការងារផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍
- សម្របសម្រួលកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌការងារអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគី នៅក្នុងតំបន់ និងពិភពលោក រួមទាំង កម្ពុជា-ឡាវ-វៀតណាម និង កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម ក្នុងវិស័យការងារផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាព គេហទំព័រ នៃកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី រួមទាំងគេហទំព័រ កម្ពុជា-ឡាវ-វៀតណាម របស់គណៈកម្មការចម្រុះតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម
- ទទួលបន្ទុកជាអង្គភាពបង្គោលស្តីពីការងារការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា វៀតណាម លើក្របខណ្ឌកិច្ចព្រមព្រៀងរួមរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ ដែលកំពុងដំណើការជូនថ្នាក់ដឹកនាំក្រសួងផែនការ
- សម្របសម្រួល និងសហការជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មាន និងជាតុចូលអំពីទំនាក់ទំនងទ្វេភាគី នៃរដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជាជាមួយនឹងខេត្តសម្ព័ន្ធមេត្រីភាពនៃបណ្តាលប្រទេសជាមិត្ត
- សម្របសម្រួលការងារសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិតាមការចាំបាច់ និងតាមការប្រគល់ភារកិច្ចពីថ្នាក់ដឹកនាំក្រសួង និងពីរាជរដ្ឋាភិបាល នៅក្នុងវិស័យផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- សហការ ជាមួយអង្គភាពភាពពាក់ព័ន្ធក្រោមឱវាទក្រសួងផែនការ និងក្រសួង ស្ថាប័ន ក្នុងការចូលរួមកិច្ចប្រជុំជាអន្តរជាតិនានា ជាទ្វេភាគី ពហុភាគី សហគមន៍អាស៊ាន នៅក្នុងតំបន់ និងពិភពលោក
- សហការសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងផែនការ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការប្រមូល និងទទួលបានព័ត៌មានពីកិច្ចសហប្រតិបត្តិការអន្តរជាតិ លើវិស័យផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍ សម្រាប់ធ្វើការបូកសរុប វាយតម្លៃ រាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងផែនការ
- រៀបចំរបាយការណ៍ លើការងារកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងអង្គភាពក្រោមឱវាទក្រសួងផែនការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ជូនថ្នាក់ដឹកនាំក្រសួងផែនការ
- សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋានជំនាញ និងស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញ រៀបចំលើកគម្រោង សហប្រតិបត្តិការទ្វេភាគី ពហុភាគី និងអន្តរជាតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាផ្ទាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

៩/៣៤

**មាត្រា ១៤.-**

នាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងនិងអភិវឌ្ឍប្រព័ន្ធរដ្ឋាភិបាលឌីជីថលរបស់ក្រសួងផែនការដោយសហការណ៍ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រងប្រព័ន្ធមូលដ្ឋានទិន្នន័យ សូចនាករ និងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍ឱ្យមានសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព
- គ្រប់គ្រងនិងអភិវឌ្ឍប្រព័ន្ធបណ្ណាល័យអេឡិកត្រូនិក
- អភិវឌ្ឍ រៀបចំ និងគ្រប់គ្រងប្រព័ន្ធបណ្តាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងបង្កើតមាតិកាព័ត៌មានជាភាសាខ្មែរលើគេហទំព័ររបស់ក្រសួង រួមទាំងអង្គភាពក្រោមឱវាទទាំងថ្នាក់ជាតិ ទាំងអង្គភាពថ្នាក់ក្រោមជាតិ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពកុំព្យូទ័រសម្រាប់ការប្រើប្រាស់ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ ក្នុងការអភិវឌ្ឍវិស័យផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍ ព្រមទាំងវិស័យពាក់ព័ន្ធផ្សេងទៀត
- អភិវឌ្ឍ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- រៀបចំការងារបច្ចេកទេសលើការតភ្ជាប់បណ្តាញ ការប្រើប្រាស់សេវាអ៊ីនធឺណែត និងការប្រើប្រាស់ប្រព័ន្ធវីដេអូនៃសន្និសីទរបស់ក្រសួង
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងប្រព័ន្ធកុំព្យូទ័រ
- បង្កើតប្រព័ន្ធជូនដំណឹងជាមុនពីសន្តិសុខបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ស្រាវជ្រាវនិងសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធឬដៃគូអភិវឌ្ឍ ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន របស់ក្រសួង និងរួមទាំងអង្គភាពក្រោមឱវាទ
- ស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- ប្រមូលនិងរៀបចំចងក្រងទិន្នន័យទាំងឡាយទាក់ទងនឹងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
- សហការជាមួយនាយកដ្ឋានបុគ្គលិក និងអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំផែនការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងឌីជីថល
- សហការ និងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងផែនការទាំងនៅរដ្ឋបាលថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ ដើម្បីប្រមូល និងចងក្រងសំណុំទិន្នន័យដើម ព័ត៌មាននានា និងរបាយការណ៍លទ្ធផលចុងក្រោយដែលបានផលិតនិងដាក់ឲ្យប្រើប្រាស់ជាស្ថាពរទាំងអស់ពីអង្គភាពពាក់ព័ន្ធនានា
- រៀបចំ និងគ្រប់គ្រងមូលដ្ឋានទិន្នន័យធំ ដើម្បីតំកល់និងថែរក្សាទុកក្នុងម៉ាស៊ីនមេ ក្នុងគោលបំណងធានាឲ្យបាននូវគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ សម្រាប់ការប្រើប្រាស់ក្នុងវិស័យផែនការ ស្ថិតិ ប្រជាជននិងអភិវឌ្ឍន៍ និងសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍ

- បណ្តុះបណ្តាលដល់មន្ត្រីក្នុងនាយកដ្ឋាន និងអង្គភាពទាំងអស់ក្រោមឱវាទក្រសួងផែនការ រួមទាំងមន្ត្រីមន្ទីរផែនការរាជធានី ខេត្ត អំពីការគ្រប់គ្រងការងារតាមប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងឌីជីថល
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាក់ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

## ជំពូក ៥
## អគ្គនាយកដ្ឋានផែនការ

**មាត្រា ១៥.-**

អគ្គនាយកដ្ឋានផែនការមានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងវែង និង កម្មវិធីជាតិ សម្រាប់អភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា
- ផ្តល់ការសហការ និងណែនាំដល់ក្រសួង ស្ថាប័ននានា ក្នុងការរៀបចំផែនការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ
- ពិនិត្យរាល់អនុសញ្ញា និងកម្មវិធីអន្តរជាតិនានា ដែលកម្ពុជាមានភារកិច្ចចូលរួមអនុវត្ត ក្នុងនាមសមាជិករបស់អង្គការសហប្រជាជាតិ ដើម្បីធ្វើមូលដ្ឋានីយកម្ម និងបញ្ជ្រាបទៅក្នុងផែនការជាតិ
- កំណត់អាទិភាពក្នុងការវិនិយោគ ទាំងសាធារណៈ ទាំងឯកជន ដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាព និងមានប្រសិទ្ធភាព នូវសក្តានុពលនៃធនធានទាំងក្នុង ទាំងក្រៅប្រទេស តាមរយៈកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល
- សហការជាមួយនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ដើម្បីរៀបចំវិធីសាស្ត្រ និងបែបបទ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិឱ្យមានសង្គតិភាពរវាងផែនការអភិវឌ្ឍន៍ជាតិជាមួយផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ
- រៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ សម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ជាតិ កម្មវិធីជាតិ និងផែនការតាមវិស័យ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការនិងកម្មវិធីជាតិ និងរៀបចំរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្ត ជូនថ្នាក់ដឹកនាំក្រសួងផែនការ និងរាជរដ្ឋាភិបាលកម្ពុជា
- សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍក្នុងការកំណត់វិធីសាស្ត្រនិងគណនាភាពក្រីក្រនៅកម្ពុជា
- ដឹកនាំ និងរៀបចំវិធីសាស្ត្រ និងអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយ និងផែនការ នៅគ្រប់កម្រិត
- រៀបចំ និងដឹកនាំការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ លើកកម្ពស់អាហារូបត្ថម្ភ

១១/៣៤

- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រយេនឌ័ររបស់ក្រសួងផែនការ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានផែនការ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី ក្រសួងផែនការ។
- អគ្គនាយកដ្ឋានផែនការ មាននាយកដ្ឋានចំណុះចំនួន ៧ ដូចខាងក្រោម៖

**មាត្រា ១៦.-**

នាយកដ្ឋានផែនការទូទៅ មានភារកិច្ចដូចតទៅ៖

- រៀបចំទស្សនាទាន យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ រយៈពេលខ្លី មធ្យម និង វែង ដោយសម្របសម្រួល និង សហការជាមួយគ្រប់អង្គភាពចំណុះក្រសួងផែនការ និង ក្រសួង ស្ថាប័ន និង អ្នកមានចំណែកពាក់ព័ន្ធទាំងអស់
- វិភាគ និងព្យាករណ៍ពីស្ថានភាពរួមនៃការវិវត្តខាងផ្នែកម៉ាក្រូសេដ្ឋកិច្ចនៅក្នុង និងក្រៅប្រទេសព្រមទាំង លើកឡើងនូវយោបល់ និងវិធានការចាំបាច់ ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេស
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច
- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងផែនការ ដោយសហការជាមួយ នាយកដ្ឋាននិងអង្គភាពនានាចំណុះក្រសួងផែនការ
- តាមដានត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំ ឆ្នាំរបស់ក្រសួងផែនការ
- រៀបចំរបាយការណ៍បូកសរុបរបស់អគ្គនាយកដ្ឋានផែនការ តាមកាលកំណត់ និងតាមតម្រូវការ
- សហការជាមួយនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានផែនការក្នុងការបណ្តុះបណ្តាលលើជំនាញផែន ការដល់មន្ត្រីក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- សម្របសម្រួលការងាររដ្ឋបាលរបស់អគ្គនាយកដ្ឋានផែនការ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

**មាត្រា ១៧.-**

នាយកដ្ឋានផែនការសេដ្ឋកិច្ច មានភារកិច្ចដូចតទៅ៖

- វិភាគ និងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវឌ្ឍខាងផ្នែកសេដ្ឋកិច្ចនៅក្នុងប្រទេសព្រមទាំងលើកឡើងនូវ យោបល់ និងវិធានការចាំបាច់ដើម្បីតម្រង់ទិសនៃការអភិវឌ្ឍប្រទេស
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងវិស័យសេដ្ឋកិច្ចរួមមាន កសិកម្ម ឧស្សាហកម្ម រ៉ែ និងថាមពល គមនាគមន៍ដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ សំណង់ អភិវឌ្ឍន៍ជនបទ និងបរិស្ថាន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងវិស័យសេដ្ឋកិច្ច និងការវិភាគសេដ្ឋកិច្ចតាមវិស័យ ដើម្បីឱ្យវិស័យនីមួយៗមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ

១២/៣៤

- សហការជាមួយនឹងក្រសួងពាក់ព័ន្ធសម្រាប់កិច្ចសហការអភិវឌ្ឍសេដ្ឋកិច្ចទាំងក្នុងក្របខ័ណ្ឌតំបន់ ទាំងពិភពលោក
- បណ្តុះបណ្តាលជំនាញដែលពាក់ព័ន្ធនឹងការងារផែនការសេដ្ឋកិច្ចដល់មន្ត្រីអគ្គនាយកដ្ឋានផែនការ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

**មាត្រា ១៨**.-

នាយកដ្ឋានផែនការសង្គមកិច្ច មានភារកិច្ចដូចតទៅះ:

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ ក្នុងវិស័យសង្គមកិច្ច
- សហការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ ជាមួយក្រសួង ស្ថាប័ននានាក្នុងវិស័យសង្គមកិច្ចដូចជាះ រៀបចំការងារអប់រំបណ្តុះបណ្តាលធនធានមនុស្ស ការងារយេនឌ័រ ការងារសុខាភិបាល ការងារប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍និងជំងឺរាតត្បាតផ្សេងៗ ការងារវប្បធម៌និងវិចិត្រសិល្បៈ ធម្មការនិងសាសនា និង ព័ត៌មាន និងវិស័យសង្គមកិច្ចផ្សេងៗទៀត
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ ក្នុងវិស័យសង្គមកិច្ច និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន និងថ្នាក់ដឹកនាំក្រសួងផែនការ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

**មាត្រា ១៩**.-

នាយកដ្ឋានផែនការវិនិយោគមានភារកិច្ចដូចតទៅះ

- វិភាគ និងព្យាករណ៍អំពីស្ថានភាពរួមនៃការវិវឌ្ឍខាងផ្នែកវិនិយោគនៅក្នុងប្រទេស ទាំងវិនិយោគសាធារណៈ និងឯកជន ព្រមទាំងលើកឡើងនូវយោបល់ និងវិធានការចាំបាច់នានា ដើម្បីតម្រង់ទិសឱ្យសមស្របតាមទិសដៅអាទិភាព នៃការអភិវឌ្ឍប្រទេស
- រៀបចំផែនការយុទ្ធសាស្ត្រវិនិយោគរយៈពេលខ្លី មធ្យម និង វែង
- កំណត់អាទិភាពនៃការវិភាជទុនតាមវិស័យ
- ពិនិត្យសេចក្តីព្រាងគម្រោងវិនិយោគសាធារណៈរបស់បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ
- រៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិលប្រចាំឆ្នាំ
- ចូលរួមក្នុងគណៈកម្មការដេញថ្លៃ លើគ្រប់គម្រោងការងារវិនិយោគសាធារណៈ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល
- បណ្តុះបណ្តាលដល់មន្ត្រីជំនាញនៅតាមក្រសួងស្ថាប័នស្តីពីការរៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងក្នុងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

**មាត្រា ២០.-**

នាយកដ្ឋានលើកកម្ពស់អាហារូបត្ថម្ភ មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រស្តីពីអាហារូបត្ថម្ភផ្អែកលើនវានុវត្តន៍
- សហការជាមួយក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ពាក់ព័ន្ធ និងការផលិត ការប្រើប្រាស់អាហារបញ្ចូលមីក្រូសារជាតិ ឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់សុខភាពសាធារណៈ ជាពិសេសស្ត្រីនិងកុមារ
- សម្របសម្រួលជាមួយនឹងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍនានា អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ វិស័យឯកជននិងអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗ ដើម្បីចូលរួមលើកកម្ពស់អាហារូបត្ថម្ភ
- សម្របសម្រួល និងសហការ ជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន សមាគមន៍អ្នកផលិត អ្នកប្រើប្រាស់ ឬអង្គការសង្គមស៊ីវិល ដើម្បីកៀរគរធនធានសម្រាប់ការងារអាហារូបត្ថម្ភ
- សហការជាមួយដៃគូអភិវឌ្ឍ អង្គការជាតិ អន្តរជាតិ សិក្សាស្រាវជ្រាវអាហារមូលដ្ឋាននៅក្នុងប្រទេសដើម្បីបញ្ចូលមីក្រូសារជាតិ
- សិក្សាស្រាវជ្រាវអំពីបញ្ហាអាហារូបត្ថម្ភ និងសុខុមាលភាពផ្អែកលើនវានុវត្តន៍ និងរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងរាជរដ្ឋាភិបាល
- បង្កើនការផ្សព្វផ្សាយចំណេះដឹង ស្តីពីអាហារូបត្ថម្ភ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ឱ្យបានទូលំទូលាយ
- ធ្វើជាសេនាធិការជូនក្រសួង ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ និងគណៈកម្មការបច្ចេកទេសអន្តរក្រសួង ដើម្បីផ្តល់គោលការណ៍ណែនាំ ការបញ្ជ្រាបនិងវិភាគបញ្ហាអាហារូបត្ថម្ភ និងសុខុមាលភាព ក្នុងផែនការអភិវឌ្ឍន៍ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃស្ថានភាពអាហារូបត្ថម្ភនៅកម្ពុជា
- បណ្តុះបណ្តាលជំនាញអាហារូបត្ថម្ភ ដោយផ្តោតលើការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ ដល់មន្ត្រីរាជការក្នុងនាយកដ្ឋាន
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាផ្ទាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

**មាត្រា ២១.-**

នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រមានភារកិច្ចដូចតទៅ៖

- រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់កិច្ចដំណើរការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះ
- រៀបចំនីតិវិធី និងលក្ខណៈវិនិច្ឆ័យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះដោយពិគ្រោះយោបល់ជាមួយ ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ
- កៀរគរធនធានពីដៃគូពាក់ព័ន្ធ សម្រាប់កិច្ចដំណើរការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និងពង្រឹងសមត្ថភាពអ្នកពាក់ព័ន្ធអំពីដំណើរការអត្តសញ្ញាណកម្មគ្រួសារក្រីក្រនិងជនងាយរងគ្រោះ

១៤/៣៤

- សម្របសម្រួលជាមួយស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីពង្រឹងការអនុវត្តការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះ
- ពង្រឹងយន្តការតាមដាន ត្រួតពិនិត្យការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ
- ផ្តល់ទិន្នន័យចាំបាច់សម្រាប់ក្របខ័ណ្ឌតាមដានត្រួតពិនិត្យអំពីការអនុវត្តគោលនយោបាយគាំពារសង្គមនៅព្រះរាជាណាចក្រកម្ពុជា
- ណែនាំ និងបណ្តុះបណ្តាលសមត្ថភាពជំនាញដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពីការគ្រប់គ្រងនិងដំណើការការអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះ
- ប្រមូល ចងក្រងព័ត៌មានអំពីគ្រួសារក្រីក្រ និងជនងាយរងគ្រោះសម្រាប់កំណត់កម្រិតភាពក្រីក្រ
- រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយការយល់ដឹងដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយព័ត៌មានអំពីលទ្ធផលអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងជនងាយរងគ្រោះដល់ស្ថាប័នពាក់ព័ន្ធ និង ដៃគូផ្តល់សេវានានា
- ធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ និងជនងាយរងគ្រោះជាប្រចាំសម្រាប់តម្រូវការនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម មូលនិធិសមធម៌ និង តម្រូវការផ្សេងៗទៀតតាមការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះផ្សេងៗ
- ធ្វើបច្ចុប្បន្នភាព និងគ្រប់គ្រងប្រព័ន្ធមូលដ្ឋានទិន្នន័យគ្រួសារក្រីក្រថ្នាក់ជាតិ និងអភិវឌ្ឍន៍មុខងារបន្ថែមដើម្បីសម្រួលដល់ការចែករំលែកទិន្នន័យនៅលើគេហទំព័រ និងតាម API (Application Programming Interface)
- រៀបចំធ្វើសុខដុមនីកម្មប្រព័ន្ធទិន្នន័យគ្រួសារក្រីក្រជាមួយនឹងថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា CamDX (Cambodia Data eXchange)
- ផ្តល់បណ្ណសមធម៌ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដែលត្រូវបានកំណត់អត្តសញ្ញាណ
- រៀបចំនិងគ្រប់គ្រងយន្តការទទួលមតិយោបល់ និងបណ្តឹងតវ៉ា ពីអ្នកពាក់ព័ន្ធ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

**មាត្រា ២២.-**

នាយកដ្ឋានផែនការថ្នាក់ក្រោមជាតិមានភារកិច្ចដូចតទៅ៖

- រៀបចំ និងបង្កើតនូវឧបករណ៍ សម្រាប់គាំទ្របច្ចេកទេសក្នុងការបណ្តុះបណ្តាលស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ
- សិក្សា និងកំណត់នូវទស្សនទានគោលនយោបាយដើម្បីជានាដល់ការធ្វើសុខដុមនីយកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) និងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល

- រៀបចំឯកសារគោលដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយ ទស្សនវិស័យ កម្មវិធី នៃក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នីតិវិធីនិងសេចក្តីណែនាំនានាទាក់ទងនឹងការងារផែនការដល់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- សហការ និងសម្របសម្រួលជាមួយ គណៈកម្មាធិការសម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍនានា លើការរៀបចំឯកសារ ទាក់ទងនឹងក្របខ័ណ្ឌច្បាប់ គតិយុត្តិនានា សេចក្តីណែនាំ សម្រាប់គាំទ្រដល់ដំណើរការរៀបចំ និងកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល នៅថ្នាក់ក្រោមជាតិ
- រៀបចំ និងគ្រប់គ្រងប្រព័ន្ធព័ត៌មាន កម្រងស្ថានភាពមូលដ្ឋានទិន្នន័យ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ប្រើប្រាស់គាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ
- រៀបចំមូលដ្ឋានទិន្នន័យឃុំ សង្កាត់ (CDB) សម្រាប់បម្រើឱ្យការងាររៀបចំផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគ៣ឆ្នាំ រំកិលនៅថ្នាក់ក្រោមជាតិ
- រៀបចំសេចក្តីណែនាំ និងបង្កើតក្របខ័ណ្ឌប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ
- ផ្តល់ការបណ្តុះបណ្តាល និងគាំទ្រផ្នែកបច្ចេកទេស ស្តីពីក្របខ័ណ្ឌប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិដល់ក្រុមការងាររៀបចំផែនការ និងភាគីពាក់ព័ន្ធនានា
- វិភាគ និងរាយការណ៍ ពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលនៅថ្នាក់ក្រោមជាតិ ជូនថ្នាក់ដឹកនាំក្រសួងផែនការ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក ។

## ជំពូក ៦
## វិទ្យាស្ថានជាតិស្ថិតិ

**មាត្រា ២៣.-**

វិទ្យាស្ថានជាតិស្ថិតិ មានតួនាទី និងភារកិច្ចដូចតទៅ៖

- ប្រមូល កែច្នៃ ចងក្រង វិភាគ បោះពុម្ព និងផ្សព្វផ្សាយទិន្នន័យស្ថិតិគ្រឹះនិងស្ថិតិផ្លូវការ តាមរយៈការធ្វើជំរឿន ការធ្វើអង្កេត ការសិក្សាស្រាវជ្រាវនានា និងការប្រើប្រាស់ប្រភពទិន្នន័យរដ្ឋបាល ព្រមទាំងទិន្នន័យប្រភពផ្សេងៗទៀត ក្នុងគោលបំណង ដើម្បីប្រើប្រាស់ជាធាតុចូលក្នុងការបម្រើឱ្យការរៀបចំគោលនយោបាយ ការធ្វើផែនការអភិវឌ្ឍន៍ និងការស្រាវជ្រាវទាំងក្នុងក្របខ័ណ្ឌជាតិ ទាំងអន្តរជាតិ
- ស្រាវជ្រាវ សម្របសម្រួល ចងក្រងវិធីសាស្ត្រ បង្កើតនិងអភិវឌ្ឍន៍ម៉ូដែល និងបច្ចេកទេសស្ថិតិនានា ដើម្បីបង្កើនគុណភាពស្ថិតិផ្លូវការ តាមបទដ្ឋានជាតិ និងអន្តរជាតិ

១៦/៣៤

- ចងក្រងស្ថិតិគណនេយ្យជាតិនិងស្ថិតិថ្លៃ ក៏ដូចជាសូចនាករសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ប្រជាសាស្ត្រ ព្រមទាំងសន្ទស្សន៍ស្ថិតិ និងសូចនាករស្ថិតិផ្សេងៗទៀត
- អភិវឌ្ឍកម្មវិធី និងបច្ចេកវិទ្យានៅក្នុងសកម្មភាពស្ថិតិដោយផ្អែកការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានវិទ្យា និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការផលិតទិន្នន័យ ការផ្ទេរនិងបញ្ជូនទិន្នន័យ ព្រមទាំងការផ្សព្វផ្សាយទិន្នន័យស្ថិតិ និងសូចនាករអភិវឌ្ឍន៍
- កសាងគោលនយោបាយស្ថិតិផ្លូវការក្នុងការបង្កើតប្រព័ន្ធស្ថិតិជាតិរួមបញ្ចូលគ្នាមួយ ដែលគ្របដណ្តប់ស្ថិតិផ្លូវការដែលបានចាត់តាំងទាំងអស់ និងអង្គភាពស្ថិតិនៃក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើកិច្ចសហប្រតិបត្តិការស្ថិតិជាមួយការិយាល័យស្ថិតិជាតិនៃបណ្តាប្រទេស អង្គការអន្តរជាតិ និងវិស័យឯកជននានា ទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- ផ្តល់ការណែនាំ និងជួយគាំទ្រដល់អង្គភាពស្ថិតិដែលបានចាត់តាំងទាក់ទងនឹងស្ថិតិផ្លូវការ ដើម្បីលើកកម្ពស់ជានាការប្រតិបត្តិបទដ្ឋានស្ថិតិ ក្នុងការអនុវត្តគោលនយោបាយស្ថិតិ និងអភិវឌ្ឍន៍ប្រព័ន្ធស្ថិតិជាតិ
- រៀបចំយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិ ផែនការថវិកានិងធនធានមនុស្ស សម្រាប់អង្គភាពស្ថិតិដែលបានចាត់តាំង រួមទាំងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីដឹកនាំការធ្វើជំរឿន និងធ្វើអង្កេត ផលិត និងផ្សព្វផ្សាយស្ថិតិផ្លូវការ សម្រាប់គោលដៅសាធារណៈ
- សម្របសម្រួលក្នុងសកម្មភាពនៃដំណើរការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យស្ថិតិ ដោយរួមទាំងការផ្តល់ប្រឹក្សា និងជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល
- ជានាសម្របសម្រួលប្រតិបត្តិការរបស់អង្គភាពស្ថិតិដែលបានចាត់តាំងក្នុងការប្រមូល កែច្នៃ ចងក្រងវិភាគ បោះពុម្ពផ្សព្វផ្សាយ ស្ថិតិផ្លូវការ និងព័ត៌មានដែលទាក់ទងនឹងការងារស្ថិតិ
- ចូលរួមផ្តល់ទិន្នន័យ និងវិភាគស៊ីជម្រៅអំពីភាពក្រីក្រនៅកម្ពុជា
- សហការបណ្តុះបណ្តាល និងរៀបចំផែនការយុទ្ធសាស្ត្របញ្ញាបយេនឌ័រ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំ និងចងក្រងចំណាត់ថ្នាក់ជាតិ ផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់វិទ្យាស្ថានជាតិស្ថិតិ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី ក្រសួងផែនការ។
- វិទ្យាស្ថានជាតិស្ថិតិ មាននាយកដ្ឋានចំណុះចំនួន ១០ ដូចខាងក្រោម៖

**មាត្រា ២៤.-**

នាយកដ្ឋានគោលនយោបាយ និងសហប្រតិបត្តិការស្ថិតិមានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយក្នុងការពង្រឹងប្រព័ន្ធស្ថិតិជាតិ និងស្ថិតិផ្លូវការដែលបានចាត់តាំង
- រៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីពង្រឹងប្រព័ន្ធស្ថិតិជាតិ និងកិច្ចសហប្រតិបត្តិការស្ថិតិ
- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដល់ក្រសួងស្ថាប័នរាជរដ្ឋាភិបាល អង្គភាពឯកជន និងសាធារណជនឲ្យបានយល់ដឹងអំពីសារៈសំខាន់នៃស្ថិតិ
- រកដំណោះស្រាយក្នុងករណីមានបទល្មើសស្ថិតិ

- សហប្រតិបត្តិការស្ថិតិទ្វេភាគី ពហុភាគីក្នុងតំបន់ លើពិភពលោក និងសម្របសម្រួលការងារសម្រាប់អ្នកស្រាវជ្រាវស្ថិតិអន្តរជាតិ
- សហការជាមួយស្ថាប័នជាតិ តំបន់ និងអន្តរជាតិ ដើម្បីផ្តល់ទិន្នន័យស្ថិតិ និងសេវាកម្មស្ថិតិ
- គ្រប់គ្រងធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញស្ថិតិដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក្នុងក្របខណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បូកសរុបសកម្មភាពការងារ និងធ្វើរបាយការណ៍តាមកាលកំណត់ស្តីពីការអនុវត្តការងារស្ថិតិជូនអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងថ្នាក់ដឹកនាំក្រសួងផែនការ
- រៀបចំ គ្រប់គ្រងលិខិតបទដ្ឋានគតិយុត្ត និងតម្កល់ឯកសារ
- រៀបចំផែនការយុទ្ធសាស្ត្រ សកម្មភាពការងារស្ថិតិរយៈពេលខ្លី មធ្យម និងវែង
- រៀបចំគម្រោងថវិកាសម្រាប់ដំណើរការការងារស្ថិតិប្រចាំថ្ងៃ រយៈពេលខ្លី មធ្យម និងវែង របស់វិទ្យាស្ថានជាតិស្ថិតិ
- ជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ និងក្រុមប្រឹក្សាស្ថិតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ២៥.-**

នាយកដ្ឋានស្ថិតិសេដ្ឋកិច្ច មានភារកិច្ចដូចតទៅ៖

- រៀបចំ និងធ្វើជំរឿនកសិកម្ម អង្កេតចន្លោះជំរឿនកសិកម្ម ជំរឿនសេដ្ឋកិច្ច និងអង្កេតចន្លោះជំរឿនសេដ្ឋកិច្ចដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- រៀបចំ និងធ្វើអង្កេតកសិកម្ម អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា អង្កេតឧស្សាហកម្ម ពាណិជ្ជកម្ម ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- អង្កេត ប្រមូល ចងក្រងព័ត៌មានបឋម និងវិភាគព័ត៌មានស្ថិតិកសិកម្ម រុក្ខកម្ម នេសាទ ស្ថិតិចំណូល ចំណាយ និងបំណុលរបស់គ្រួសារ ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម និងវិនិយោគ ស្ថិតិសំណង់ ស្ថិតិទូរគមនាគមន៍ ដឹកជញ្ជូន ស្ថិតិទេសចរណ៍ ស្ថិតិបរិស្ថាន និងបញ្ជីគ្រឹះស្ថានសហគ្រាស ពាណិជ្ជកម្ម
- អង្កេត ប្រមូល ចងក្រង វិភាគ ផ្សព្វផ្សាយ ទិន្នន័យស្ថិតិសេដ្ឋកិច្ច បរិស្ថាន នៃកម្ពុជាប្រចាំឆ្នាំ
- អង្កេត ប្រមូល ចងក្រង វិភាគ ផ្សព្វផ្សាយទិន្នន័យស្ថិតិទំនិញពាណិជ្ជកម្មអន្តរជាតិប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ
- រៀបចំចងក្រងវិធីសាស្ត្រអនុវត្តស្ថិតិសេដ្ឋកិច្ច-បរិស្ថាន (ស្ថិតិកសិកម្ម ស្ថិតិឧស្សាហកម្ម ពាណិជ្ជកម្ម វិនិយោគ ស្ថិតិសំណង់ គមនាគមន៍ ដឹកជញ្ជូន) និងស្ថិតិចំណូលចំណាយ និងបំណុលគ្រួសារដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ រៀបចំ ប្រមូល ចងក្រង វាស់វែង និងវិភាគទិន្នន័យស្ថិតិសេដ្ឋកិច្ចតាមជំនាន់ ដោយអនុលោមតាមបទដ្ឋានជាតិ និងអន្តរជាតិ ដោយសហការជាមួយក្រសួង ស្ថាប័ន ឬអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា

- បណ្តុះបណ្តាល ពង្រឹង និងបង្កើនសមត្ថភាពមន្ត្រីជំនាញស្ថិតិសេដ្ឋកិច្ច តាមរយៈការរៀបចំសហការ និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងវគ្គសិក្សាផ្សេងៗទាំងក្នុង ទាំងក្រៅប្រទេស
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាផ្ទាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ២៦.-**

នាយកដ្ឋានស្ថិតិសង្គមកិច្ច មានភារកិច្ចដូចតទៅ៖

- ប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយទិន្នន័យរដ្ឋបាលពីបណ្តាក្រសួង ស្ថាប័នពាក់ពន្ធ័ ដើម្បីគាំទ្រដល់ស្ថិតិសង្គមកិច្ច ស្ថិតិការងារ ស្ថិតិកំលាំងពលកម្ម ស្ថិតិពិការភាព ស្ថិតិអប់រំ យុវជន និងកីឡា ស្ថិតិសុខាភិបាល ស្ថិតិវប្បធម៌ ស្ថិតិព័ត៌មាន ស្ថិតិសាសនា ស្ថិតិយេនឌ័រ ស្ថិតិបទឧក្រិដ្ឋកម្ម និងទិន្នន័យរដ្ឋបាលដែលពាក់ព័ន្ធផ្នែកស្ថិតិសង្គមកិច្ចដទៃទៀត
- អង្កេត វិភាគ និងផ្សព្វផ្សាយទិន្ន័យ នៃអង្កេតគ្រួសារ អង្កេតសង្គមកិច្ចនិងសុខមលភាព អង្កេតពិការភាព និងមុខងារកុមារ អង្កេតអំពើហិង្សានិងភាពងាយរងគ្រោះ អង្កេតការប្រើប្រាស់ពេលវេលា អង្កេតគ្រោះថ្នាក់និងរបួស និងអង្កេតដែលពាក់ព័ន្ធផ្នែកស្ថិតិសង្គមកិច្ចដទៃទៀត
- គណនាសន្ទស្សន៍អភិវឌ្ឍន៍សង្គមកិច្ច និងវាស់វែងក្របខណ្ឌសូចនាករផ្នែកកសង្គមកិច្ចដែលមានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព
- រៀបចំ និងធ្វើអង្កេតកំលាំងពលកម្ម និងពលកម្មកុមារ
- ប្រមូល ចងក្រង វិភាគ សូចនាករស្ថិតិសង្គមកិច្ច តាមរាជធានី ខេត្ត នៅក្នុងប្រទេសកម្ពុជា
- សហការ សម្របសម្រួល ចងក្រងគណនីរណបសង្គមកិច្ច និងគណនីជាតិសុខាភិបាល
- សហការជាមួយអង្គភាពពាក់ព័ន្ធ រៀបចំធ្វើជំរឿន អង្កេត និងកិច្ចការស្រាវជ្រាវ ស្ថិតិផ្សេងៗទៀត ដើម្បីចងក្រង និងវិភាគតាមប្រធានបទ ដែលពាក់ព័ន្ធ ព័ត៌មាន ស្ថិតិការងារ ស្ថិតិកំលាំងពលកម្ម ស្ថិតិពិការភាព ស្ថិតិអប់រំ យុវជន និងកីឡា ស្ថិតិសុខាភិបាល ស្ថិតិវប្បធម៌ ស្ថិតិព័ត៌មាន ស្ថិតិសាសនា ស្ថិតិយេនឌ័រ អំពើហិង្សានិងភាពងាយរងគ្រោះ និងស្ថិតិបទល្មើសព្រហ្មទណ្ឌ
- សហការជាមួយដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ ដែលកំពុងប្រតិបត្តិការការងារពាក់ព័ន្ធស្ថិតិសង្គមកិច្ចក្នុងក្របខណ្ឌអភិវឌ្ឍន៍វិធីសាស្ត្រថ្មីៗ ក្នុងការគណនា និងវាស់វែងសូចនាករ សង្គមកិច្ច និងសូចនាករនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចេរភាព
- សហការរៀបចំ ចងក្រងសៀវភៅ កម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ
- អភិវឌ្ឍសមត្ថភាពជំនាញ ប្រមូល ចងក្រង និងវិភាគស្ថិតិសង្គមកិច្ច ដល់មន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបំពេញការងារពាក់ព័ន្ធស្ថិតិសង្គមកិច្ច ឲ្យស្របតាមការវិវឌ្ឍន៍នៃបរិបទសង្គម និងអន្តរជាតិ
- អភិវឌ្ឍសមត្ថភាពមន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលធ្វើការងារពាក់ព័ន្ធការងារប្រមូលចងក្រង និងវិភាគស្ថិតិសង្គមកិច្ច
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាផ្ទាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

១៩/៣៤

**មាត្រា ២៧.-**

នាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេតមានភារកិច្ចដូចតទៅ៖

- ធ្វើជំរឿន អង្កេត ប្រមូល ចងក្រង និងគ្រប់គ្រងស្ថិតិប្រជាសាស្ត្រ និងសុខភាព
- ជំរឿនប្រជាជន និងអង្កេតចន្លោះជំរឿនប្រជាជន
- អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា
- អង្កេតមនុស្សចាស់ នៅកម្ពុជា
- អង្កេតវាយតម្លៃការចុះបញ្ជីអត្រានុកូលដ្ឋាន
- អង្កេតតាមប្រធានបទនានាតាមសំណូមពររបស់បណ្តាអង្គភាពនិងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិ
- គណនាចំណោលប្រជាជន (Population Projection)
- រៀបចំធ្វើបច្ចុប្បន្នភាព ចំនួនភូមិនៅទូទាំងប្រទេសសម្រាប់រៀបចំធ្វើសំណាកគំរូនិងជំរឿន
- ពង្រឹងសមត្ថភាពមន្ត្រីជំនាញស្ថិតិប្រជាសាស្ត្រជំរឿន និងអង្កេត នៅថ្នាក់ជាតិ និងក្រោមជាតិ ព្រមទាំងវិធីសាស្ត្រពាក់ព័ន្ធនានា ផ្អែកតាមបទដ្ឋានជាតិ និងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថិតិអត្រានុកូលដ្ឋាន
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ២៨.-**

នាយកដ្ឋានស្តង់ដារស្ថិតិនិងវិភាគស្ថិតិ មានភារកិច្ចដូចតទៅ៖

- រៀបចំ និងចងក្រងចំណាត់ថ្នាក់ស្តង់ដារស្ថិតិជាតិ ដើម្បីឲ្យការផលិតទិន្នន័យជំរឿន អង្កេតនិងការវិភាគ
- រៀបចំ និងចងក្រងទស្សនាទាន និយមន័យស្ថិតិជាតិ
- រៀបចំ និងចងក្រងវិធីសាស្ត្រស្ថិតិរបស់ស្ថិតិផ្លូវការតាមវិស័យ ដើម្បីជានាដំណើរការផលិតទិន្នន័យស្ថិតិផ្លូវការឲ្យបានត្រឹមត្រូវ មានគុណភាព និងគួរទុកចិត្តបាន
- ធ្វើអង្កេតពលកម្មទីផ្សារការងារកម្ពុជា ក្នុងគោលបំណងវិភាគស៊ីជម្រៅស្តីពីស្ថានភាពទីផ្សារការងារនៅកម្ពុជា និងជាមូលដ្ឋានសម្រាប់ធ្វើចំណាត់ថ្នាក់មុខរបរកម្ពុជា ចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចកម្ពុជា ព្រមទាំងបម្រើតម្រូវការទិន្នន័យស្ថិតិរបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ និងអន្តរជាតិដ៏ទូលំទូលាយ
- សម្របសម្រួលក្នុងការអនុវត្តន៍ចំណាត់ថ្នាក់ស្តង់ដារស្ថិតិ និយមន័យស្ថិតិ និងវិធីសាស្ត្រស្ថិតិ ដើម្បីឲ្យអង្គភាពស្ថិតិដែលបានចាត់តាំងអនុវត្តមានការឯកភាពគ្នា
- បណ្តុះបណ្តាលដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធនានា លើស្តង់ដារស្ថិតិនិងវិភាគស្ថិតិ
- វិភាគស្ថិតិស៊ីជម្រៅតាមប្រធានបទដែលបានពីការអង្កេត និងជំរឿន ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ការប្រើប្រាស់ពេលវេលា អាហាររូបត្ថម្ភ កម្លាំងពលកម្ម ពលកម្មកុមារ និងប្រធានបទចាំបាច់ផ្សេងទៀត

- ស្រាវជ្រាវ និងចងក្រងព័ត៌មានស្ថិតិសំខាន់ៗ តាមសំណូមពរ និងតាមតម្រូវការរបស់អ្នកប្រើប្រាស់ អ្នកធ្វើគោលនយោបាយ និងអ្នកស្រាវជ្រាវក្នុងសហគមន៍ជាតិ តំបន់ និងអន្តរជាតិ
- ផ្សព្វផ្សាយវិធីសាស្ត្រនៃការវិភាគស៊ីជម្រៅដល់មន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិនៃក្រសួងស្ថាប័នរាជរដ្ឋាភិបាល
- ផ្តល់សេវាកម្មស្រាវជ្រាវ និងវិភាគស្ថិតិតាមសំណូមពរ និងសេចក្តីត្រូវការរបស់ស្ថាប័នជាតិ តំបន់ និងអន្តរជាតិ
- សម្របសម្រួល សហការ និងត្រួតពិនិត្យដើម្បីពង្រឹងស្តង់ដារស្ថិតិ ឱ្យសមស្របទៅតាមសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក្នុងការវិភាគទៅតាមប្រធានបទនីមួយៗ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ២៩.-**

នាយកដ្ឋាន គ្រប់គ្រងទិន្នន័យ អភិវឌ្ឍន៍កម្មវិធី និងបច្ចេកវិទ្យា មានភារកិច្ច ដូចតទៅ ៖

- រៀបចំ តម្លើង និងកែលម្អប្រព័ន្ធបណ្តាញកុំព្យូទ័រផ្ទៃក្នុង និងម៉ាស៊ីនមេក្លោដ សម្រាប់ទំនាក់ទំនងបញ្ជូនព្រមទាំងទទួលព័ត៌មាន និងទិន្នន័យស្ថិតិ ដើម្បីធានាផ្តល់នូវសុវត្ថិភាពទិន្នន័យក្នុងប្រព័ន្ធស្ថិតិ ដោយមធ្យោបាយផ្សេងៗ ដូចជា ប្រព័ន្ធឌីជីថល ម៉ាស៊ីនមេក្លោដ អ៊ិនធឺណែត អ៊ីម៉ែល ។ល។ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ
- រៀបចំ តម្លើង និងថែរក្សាកម្មវិធីសុវត្ថិភាពកុំព្យូទ័រ សម្រាប់ដំណើរការប្រព្រឹត្តិកម្មទិន្នន័យ ពីជំរឿន និងអង្កេតផ្សេងៗ
- វិភាគកែតម្រូវ អភិវឌ្ឍន៍កម្មវិធី ឬប្រព័ន្ធកម្មវិធី និងតម្លើងកម្មវិធីផ្សេងៗ ពិសេសកម្មវិធីប្រមូលទិន្នន័យអេឡិកត្រូនិក ដោយប្រើប្រាស់ឧបករណ៍ ថាប្លេត ភីឌីអេ ស្មាតហ្វូន ។ល។ ការប្រើប្រាស់ម៉ាស៊ីនមេក្លោដ ដោយរួមបញ្ចូលទាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ កែតម្រូវបញ្ហាសម្អាតទិន្នន័យបម្លែងជាមូលដ្ឋានទិន្នន័យ ព្រមទាំងត្រួតពិនិត្យផ្នែកទន់សម្រាប់ការងារអង្កេត និងជំរឿន
- រៀបចំទិន្នន័យស្ថិតិ និងកែលម្អប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ កំណត់លេខកូដ និងអភិវឌ្ឍផ្នែកទន់ដើម្បីអនុវត្តឱ្យមានការឯកភាព គុណភាព និងប្រសិទ្ធិភាពខ្ពស់
- ទទួលខុសត្រូវ រៀបចំ គ្រប់គ្រង និងរក្សាទុកទិន្នន័យនៃអង្កេត និងជំរឿន គ្រប់ប្រភេទ សម្រាប់វិទ្យាស្ថានជាតិស្ថិតិ
- ថែរក្សា កែលម្អ វេបសាយ និង អភិវឌ្ឍផែនទីស្ថិតិ កំណត់ទីតាំងប្រព័ន្ធព័ត៌មានភូមិសាស្ត្រតំបន់ស្ថិតិ ។ល។ ដើម្បីផ្សព្វផ្សាយអំពីរបាយការណ៍ និងទិន្នន័យស្ថិតិ
- ទទួលបន្ទុករៀបចំ និងអនុវត្តគោលការណ៍បែបបទប្រើប្រាស់ និងស្តង់ដារប្រព័ន្ធកុំព្យូទ័រដើម្បីធានាឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងទិន្នន័យ ក្នុងវិទ្យាស្ថានជាតិស្ថិតិ
- ត្រួតពិនិត្យការវាយបញ្ចូលទិន្នន័យ ការកែតម្រូវទិន្នន័យ សម្អាតកំហុសទិន្នន័យនិង រៀបចំឯកសារណែនាំការវាយបញ្ចូលទិន្នន័យដោយកុំព្យូទ័រ សម្រាប់អង្កេត និងជំរឿន

- បង្កើត រៀបចំកម្មវិធី និងផលិតតារាងទិន្នន័យស្ថិតិ សម្រាប់អង្កេត និងជំរឿន ដោយប្រើប្រាស់កុំព្យូទ័រ
- ស្រាវជ្រាវ និងដាក់ឱ្យប្រើប្រាស់បច្ចេកទេសកុំព្យូទ័រថ្មីៗ ក្នុងវិទ្យាស្ថានជាតិស្ថិតិ ដែលទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធបណ្ដាញកុំព្យូទ័រ ការអភិវឌ្ឍន៍កម្មវិធី ការអភិវឌ្ឍប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ការវិភាគនឹងគ្រោងវាយបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យ អ៊ិនធឺណេត អ៊ីម៉ែល និងវេបសាយ
- បណ្ដុះបណ្ដាលដល់មន្ត្រីនាយកដ្ឋាន ដើម្បីពង្រឹងសមត្ថភាព ដែលទាក់ទងនឹងជំនាញ ឬឯកទេស ជាពិសេសកម្មវិធីសម្រាប់បញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យផ្អែកលើឯកសារណែនាំ ។ល។ និងផ្សព្វផ្សាយមូលដ្ឋានទិន្នន័យ ការប្រើប្រាស់ប្រព័ន្ធ មូលដ្ឋានទិន្នន័យ និងព័ត៌មានស្ថិតិដល់អ្នកប្រើប្រាស់ស្ថិតិ នៃក្រសួង ស្ថាប័ន និងសាធារណជន តាមរយៈការផ្សព្វផ្សាយវេបសាយរបស់វិទ្យាស្ថានជាតិស្ថិតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាណ្ឆ្នាំ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ៣០.-**

នាយកដ្ឋានគណនេយ្យជាតិមានភារកិច្ចដូចតទៅ៖

- ប៉ាន់ស្មាន និងវិភាគស្ថិតិម៉ាក្រូសេដ្ឋកិច្ច
- វិភាគនិងធ្វើរបាយការណ៍ស្ថានភាពសេដ្ឋកិច្ចជាតិ តាមវិស័យ និងតាមគណនីរណបក្នុងសេដ្ឋកិច្ចជាតិ អតិផរណាអ្នកប្រើប្រាស់ អតិផរណាអ្នកផលិត និងការប្រែប្រួលនៃសន្ទស្សន៍ថ្លៃផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជូនក្រសួងផែនការ និងរាជរដ្ឋាភិបាល
- ចងក្រងស្ថិតិគណនេយ្យជាតិថ្នាក់ជាតិ និងស្ថិតិថ្លៃ អតិផរណាប្រើប្រាស់ អ្នកផលិត និងសន្ទស្សន៍ថ្លៃផ្សេងទៀត តាមបទដ្ឋាន និងប្រព័ន្ធគណនេយ្យជាតិអង្គការសហប្រជាជាតិ
- ចងក្រងតារាងផ្គត់ផ្គង់ និងប្រើប្រាស់ តារាងធាតុចូល និងតារាងធាតុចេញ តារាងគណនីមាទ្រីសសង្គមកិច្ច សម្រាប់ប្រើប្រាស់ជាធាតុចូលក្នុងវិភាគសេដ្ឋកិច្ច និងរៀបចំគោលនយោបាយ
- ចងក្រងគណនីរណបក្នុងសេដ្ឋកិច្ចជាតិ៖ គណនីរណបសេដ្ឋកិច្ចឌីជីថល គណនីរណបទេសចរណ៍ គណនីរណបបរិស្ថាននិងសេដ្ឋកិច្ច គណនីរណបសមុទ្រ និងជលផល គណនីរណបសុខាភិបាលនិងសង្គមកិច្ច តាមបទដ្ឋាន និងប្រព័ន្ធគណនេយ្យជាតិអង្គការសហប្រជាជាតិ សម្រាប់ប្រើប្រាស់ជាធាតុចូលក្នុងការវិភាគសេដ្ឋកិច្ច និងរៀបចំគោលនយោបាយ
- ចងក្រងគណនីស្ថាប័ន គណនីវិស័យក្រៅប្រទេស គណនីរណបមូលធន និងហិរញ្ញវត្ថុ ឱ្យសង្គតិភាពក្នុងស្ថិតិម៉ាក្រូសេដ្ឋកិច្ចជាតិ
- សហការជាមួយធនាគារជាតិនៃកម្ពុជា ចងក្រងស្ថិតិពាណិជ្ជកម្មសេវាកម្មអន្តរជាតិ
- ប្រមូលនិងចងក្រងស្ថិតិតាមវិស័យពីអន្តរក្រសួង ស្ថាប័នជាតិនិងអន្តរជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រការប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមត្រីមាស និងប្រចាំឆ្នាំ
- អង្កេត និងចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ប្រចាំខែ សន្ទស្សន៍ថ្លៃអ្នកផលិតប្រចាំត្រីមាស និងសន្ទស្សន៍ថ្លៃនាំចេញ នាំចូល ប្រចាំត្រីមាស

- អង្កេត និងចងក្រងសូចនាករសេដ្ឋកិច្ចមួយចំនួនសម្រាប់ជានាគុណភាពការប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ
- ធ្វើបច្ចុប្បន្នភាព និងធ្វើអោយប្រសើរឡើងវិធីសាស្ត្រប៉ាន់ស្មានស្ថិតិគណនេយ្យជាតិ និងស្ថិតិថ្លៃ តាមបរិបទនៃសេដ្ឋកិច្ចឌីជីថល
- ធ្វើបច្ចុប្បន្នភាព និងធ្វើអោយប្រសើរសេចក្តីណែនាំស្ថិតិគណនេយ្យជាតិ និងស្ថិតិថ្លៃស្របតាមតាមបទដ្ឋាន និងប្រព័ន្ធគណនេយ្យជាតិអង្គការសហប្រជាជាតិ
- សហការជាមួយក្រសួងស្ថាប័នក្នុងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍដើម្បីពង្រឹងគុណភាពស្ថិតិម៉ាក្រូសេដ្ឋកិច្ចជាតិ
- បណ្តុះបណ្តាលជំនាញចងកងស្ថិតិគណនេយ្យជាតិ ស្ថិតិថ្លៃ គណនីរណប គណនីស្ថាប័ន ក្នុងសេដ្ឋកិច្ចជូនមន្ត្រីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្រសួងស្ថាប័ន តាមបទដ្ឋានប្រព័ន្ធគណនេយ្យជាតិ អង្គការសហប្រជាជាតិ ដើម្បីពង្រឹងគុណភាព និងសង្គតិភាព ស្ថិតិម៉ាក្រូសេដ្ឋកិច្ចជាតិ
- សហការជាមួយក្រសួងស្ថាប័នជាតិ និងអន្តរជាតិ តាមរយៈការបណ្តុះបណ្តាល ចែករំលែកបទពិសោធទាំងក្នុង ទាំងក្រៅប្រទេស ដើម្បីពង្រឹងគុណភាព និងសង្គតិភាព ស្ថិតិម៉ាក្រូសេដ្ឋកិច្ចជាតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាធ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ៣១.-**

នាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិមានភារកិច្ចដូចតទៅៈ

- ប្រមូលនិងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីប្រជាសាស្ត្រ អត្រានុកូលដ្ឋាន ផ្ទះសម្បែង ស្ថានភាពគ្រួសារនិងស្ថិតិប្រជាសាស្ត្រដទៃទៀតពីមន្ទីរផែនការរាជធានី ខេត្ត
- ប្រមូល និងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីសេដ្ឋកិច្ច ដូចជា កសិកម្ម រុក្ខាប្រមាញ់ នេសាទ ឧស្សាហកម្ម ពាណិជ្ជកម្ម សំណង់ ទេសចរណ៍ បរិស្ថាន គមនាគមន៍ និងស្ថិតិសេដ្ឋកិច្ចដទៃទៀត ពីការិយាល័យស្ថិតិនៃមន្ទីរផែនការរាជធានី ខេត្ត
- សហការប្រមូល និងចងក្រងស្ថិតិម៉ាក្រូសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ
- ប្រមូល និងចងក្រងស្ថិតិថ្នាក់ក្រោមជាតិស្តីពីសង្គមកិច្ច ដូចជា អប់រំ ការងារ សុខាភិបាល វប្បធម៌ព័ត៌មាន សាសនា និងស្ថិតិសង្គមកិច្ចដទៃទៀតពីមន្ទីរផែនការរាជធានី ខេត្ត
- កំណត់ និងធ្វើបច្ចុប្បន្នភាពផែនទីភូមិសាស្ត្រតំបន់តូចៗ
- ប្រមូល និងចងក្រងស្ថិតិថ្នាក់ក្រោមជាតិនៅមូលដ្ឋានដែលទាក់ទងនឹងព័ត៌មាន ស្តីពីប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គមកិច្ច និងកសិកម្ម
- រៀបចំនិងគ្រប់គ្រងប្រពន្ធ័មូលដ្ឋានទិន្នន័យ ស្ថិតិថ្នាក់ក្រោមជាតិសម្រាប់គោលដៅស្ថិតិ
- វិភាគ និងផ្សព្វផ្សាយទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិស្តីពីប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច ស្ថិតិភូមិសាស្ត្រថ្នាក់ក្រោមជាតិ
- បណ្តុះបណ្តាលជំនាញស្តីពី វិធីសាស្ត្រនៃការប្រមូល ការចងក្រង និងការវិភាគទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិដល់មន្ត្រីក្នុងនាយកដ្ឋាន និងបណ្តុះបណ្តាលបន្តនៅថ្នាក់ក្រោមជាតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាធ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

២៣/៣៤

**មាត្រា ៣២.-**

នាយកដ្ឋានស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មានភារកិច្ចដូចតទៅ៖

- សិក្សាកសាងវិធីសាស្ត្រឯកសារណែនាំនិងផែនការសកម្មភាពដែលពាក់ព័ន្ធនឹងស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ប្រមូលទិន្នន័យ ចងក្រង និងផ្សព្វផ្សាយព័ត៌មានអំពីបច្ចេកវិទ្យានិងនវានុវត្តន៍រួមទាំងការស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីជានាការអភិវឌ្ឍប្រកបដោយចីរភាពនិងលើកកម្ពស់គុណភាពជីវិតប្រជាជន
- កសាងនិងពង្រឹងសមត្ថភាពផ្នែកស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- រៀបចំនិងធ្វើអង្កេតស្ដីពីការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងអង្កេតបច្ចេកវិទ្យា នវានុវត្តន៍
- ប្រមូល ចងក្រងសូចនាករ និងផ្តល់ព័ត៌មានផ្នែកស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បី
- ជួយដល់ក្រសួង ស្ថាប័នក្នុងការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការសកម្មភាព ដើម្បីអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមវិស័យរៀងៗខ្លួន
- សម្របសម្រួល និងសហការជាមួយអន្តរក្រសួងលើការងារបច្ចេកទេសអង្កេតស្ដីពីបច្ចេកវិទ្យា និងនវានុវត្តន៍
- ចូលរួមជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំនិងអនុវត្តកម្មវិធីជាមួយដៃគូអភិវឌ្ឍដើម្បីគាំទ្រ ដល់ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍
- ចូលរួមកសាងនិងអនុវត្តកម្មវិធីជាតិ និងកម្មវិធីសហគមន៍ សម្រាប់អភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- សហការជាមួយដៃគូអភិវឌ្ឍដើម្បីអភិវឌ្ឍកិច្ចការស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បណ្តុះបណ្តាល ពង្រឹង និងបង្កើនសមត្ថភាពមន្ត្រីជំនាញស្ថិតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការរៀបចំ សហការ និងចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំ ផ្សព្វផ្សាយ និងវគ្គសិក្សាស្រាវជ្រាវផ្សេងៗទាំងក្នុង ទាំងក្រៅប្រទេស ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

**មាត្រា ៣៣.-**

នាយកដ្ឋានសេវាព័ត៌មានស្ថិតិមានភារកិច្ចដូចតទៅ៖

- ផលិតសៀវភៅស្ថិតិប្រចាំឆ្នាំនិងការបោះពុម្ពផ្សាយសៀវភៅផ្សេងៗទៀត
- លើកកម្ពស់ការអភិវឌ្ឍផលិតផលផ្សព្វផ្សាយថ្មីៗដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការអ្នកប្រើប្រាស់
- ផ្តល់សេវាកម្មបណ្ណាល័យសម្រាប់បម្រើជូនមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ មន្ត្រីអង្គភាពស្ថិតិក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលនិងអ្នកប្រើប្រាស់ទិន្នន័យទូទៅ
- ផ្តល់ជូននូវសេវាកម្មបោះពុម្ពនិងលក់ទិន្នន័យតាមរយៈមជ្ឈមណ្ឌលសេវាកម្មអ្នកប្រើប្រាស់ទិន្នន័យ
- ផ្តល់សេវាកម្មជាប្រចាំឬសមាជិកភាពសម្រាប់ការទទួលបានឯកសារបោះពុម្ពស្តង់ដានិងផលិតផល
- អេឡិចត្រូនិកដល់អ្នកប្រើប្រាស់ស្ថិតិផ្លូវការ

២៤/៣៤

- សម្របសម្រួលការចងក្រង ការផលិត និងការផ្សព្វផ្សាយទិន្នន័យ ដើម្បីឆ្លើយតបតម្រូវការទិន្នន័យស្ថិតិសម្រាប់ការអភិវឌ្ឍព្រមទាំងតម្រូវការរបស់អ្នកប្រើប្រាស់ទូទៅ
- សម្របសម្រួលនិងផ្តល់ព័ត៌មាន និងផ្តល់សេវាកម្មប្រឹក្សាស្ថិតិព្រមទាំងផ្តល់ការយល់ដឹងជាសាធារណៈអំពីសារៈសំខាន់និងតួនាទីរបស់ស្ថិតិក្នុងការអភិវឌ្ឍ
- អភិវឌ្ឍប្រព័ន្ធកម្មវិធីផ្សព្វផ្សាយទិន្នន័យ ដោយរួមបញ្ចូលការប្រើប្រាស់គំរូដំណើរការស្ថិតិទូទៅ ការអនុវត្តបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់ថ្នាលទិន្នន័យសម្រាប់ផ្ទេរបញ្ជូននិងរាយការណ៍ទិន្នន័យ
- ធ្វើអង្កេតស្តីពីតម្រូវការទិន្នន័យ ការប្រើប្រាស់ និងភាពពេញចិត្តរបស់អ្នកប្រើប្រាស់ទិន្នន័យ
- ផ្តល់ការផ្សព្វផ្សាយទិន្នន័យស្ថិតិស្របតាមគោលការណ៍វិទ្យាសាស្ត្រ ក្រមសីលធម៌វិជ្ជាជីវៈ និងស្តង់ដារអន្តរជាតិ
- លើកកម្ពស់វប្បធម៌នៃការប្រើប្រាស់ទិន្នន័យផ្អែកតាមតម្រូវការអ្នកប្រើប្រាស់ និងដំណោះស្រាយបញ្ហាផ្សព្វផ្សាយទិន្នន័យ ដោយធានាថាអ្នកប្រើប្រាស់អាចទទួលបានសេវាកម្មព័ត៌មានស្ថិតិទាន់ពេលវេលា និងមានភាពងាយស្រួល
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិនានានៅក្នុងក្របខ័ណ្ឌការងារ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្ថិតិ ការរាយការណ៍ និងការផ្លាស់ប្តូរទិន្នន័យស្ថិតិផ្លូវការ
- អភិវឌ្ឍសមត្ថភាពជំនាញរៀបចំ ចងក្រង រចនា ស្ថិតិផ្លូវការ តាមរយៈសៀវភៅ បណ្ណផ្សព្វផ្សាយ ប្រព័ន្ធឌីជីថល និងប្រព័ន្ធក្លោដ (cloud) ដល់មន្ត្រីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំអំពីសកម្មភាពនិងលទ្ធផលការងាររបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយក។

## ជំពូក ៧
## អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍

**មាត្រា ៣៤.-**

អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍មានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានាពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- ផ្តួចផ្តើមនិងលើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការរៀបចំនិងកែសម្រួលគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព ដើម្បីគាំទ្រដល់កម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍
- តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន និងផែនការសកម្មភាព
- ផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការសកម្មភាព កម្មវិធី និងសេចក្តីប្រកាសអន្តរជាតិនានា រួមទាំងរៀបចំទិវាប្រជាជនពិភពលោក និងវេទិកាពិភាក្សាផ្សេងៗទាក់ទងនឹងប្រជាជននិងអភិវឌ្ឍន៍

២៥/៣៤

- រៀបចំនិងបណ្តុះបណ្តាលដល់មន្ត្រីរាជការនិងអ្នកដែលពាក់ព័ន្ធលើប្រធានបទនានាពាក់ព័ន្ធនឹងគោលនយោបាយជាតិប្រជាជននិងប្រជាសាស្ត្រ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ និងប្រធានបទផ្សេងៗ
- សម្របសម្រួលនិងសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីជំរុញការអភិវឌ្ឍសហគមន៍ឱ្យកាន់តែ ល្អប្រសើរឡើង តាមរយៈការចងក្រង ការកែលម្អ ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាពសហគមន៍
- សិក្សាស្រាវជ្រាវអំពីទំនាក់ទំនងរវាងបម្រែបម្រួលប្រជាសាស្ត្រ និងការអភិវឌ្ឍ សង្គម សេដ្ឋកិច្ច និងបរិស្ថាន និងប្រធានបទនានាពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- សម្របសម្រួលនិងសហការជាមួយស្ថាប័ននីតិប្បញ្ញត្តិ ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិ សង្គមស៊ីវិល និងវិស័យឯកជន ក្នុងក្របខ័ណ្ឌការងារនិងសកម្មភាពនានាពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន អាស៊ីប៉ាស៊ីហ្វិក និងពិភពលោក និងស្ថាប័នសហប្រជាជាតិ លើការងារនិងសកម្មភាពនានាពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាល សិក្ខាសាលា វគ្គសិក្សាផ្សេងៗ និងសន្និសីទអន្តរជាតិ នៅក្នុងនិងក្រៅប្រទេស ដើម្បីបង្កើនសមត្ថភាពជំនាញ និងភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ សំដៅលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពការងារ
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពហុឆ្នាំនិងប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី ក្រសួងផែនការ
- អគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ មាននាយកដ្ឋានចំនួន៤ ចំណុះ ដូចខាងក្រោម៖

**មាត្រា ៣៥.-**

នាយកដ្ឋានគោលនយោបាយប្រជាជន មានភារកិច្ចដូចតទៅ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងគោលនយោបាយជាតិប្រជាជន
- រៀបចំរបាយការណ៍វឌ្ឍនភាពពាក់កណ្តាលអណត្តិនៃការអនុវត្តគោលនយោបាយជាតិប្រជាជន និងផែនការសកម្មភាពនៃគោលនយោបាយជាតិប្រជាជន
- បង្កើតនិងចងក្រងសូចនាករសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន
- បង្កើត និងពង្រឹងយន្តការសម្របសម្រួលអន្តរក្រសួងសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយជាតិប្រជាជន
- សម្របសម្រួលនិងសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តកម្មវិធីសកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជននិងអភិវឌ្ឍន៍
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពហុឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ៣៦.-**

នាយកដ្ឋានផ្សព្វផ្សាយនិងព័ត៌មាន មានភារកិច្ចដូចតទៅ៖

- ផ្សព្វផ្សាយឯកសារគោលនយោបាយ ផែនការសកម្មភាព កម្មវិធី និងសេចក្ដីប្រកាសអន្តរជាតិនានា ដែលទាក់ទងនឹងប្រជាជននិងអភិវឌ្ឍន៍ ឆ្លើយតបទៅនឹងសេចក្ដីប្រកាសសន្និសីទអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍ ដល់អ្នកដែលមានចំណែកពាក់ព័ន្ធទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- ប្រមូលនិងចងក្រង អត្ថបទ ទស្សនាវដ្ដី សៀវភៅព្រឹត្តិបត្រ ផ្ទាំងរូបភាព និងខ្សែវីដេអូផ្សេងៗ ដែលទាក់ទងនឹងប្រជាជននិងអភិវឌ្ឍន៍ ដើម្បីបោះពុម្ពផ្សាយ រួមទាំងការផ្សព្វផ្សាយតាមប្រព័ន្ធ អ៊ីនធឺណិត
- រៀបចំទិវាប្រជាជនពិភពលោក និងវេទិកាពិភាក្សាផ្សេងៗពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- សម្របសម្រួលនិងសហការជាមួយនឹង អង្គភាពពាក់ព័ន្ធក្នុងការផ្ដល់ព័ត៌មានអំពីគំនិតនៃគោលនយោបាយជាតិប្រជាជន ដល់អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើផែនការ អ្នកធ្វើការសម្រេចចិត្តថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីឱ្យមានការគាំទ្រ និងអនុវត្តគោលនយោបាយជាតិប្រជាជនប្រកបដោយប្រសិទ្ធិភាព
- សម្របសម្រួលនិងសហការជាមួយស្ថាប័ននីតិប្បញ្ញត្តិ ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងក្របខ័ណ្ឌការងារនិងសកម្មភាពនានាពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍ ដើម្បីសម្រេចគោលដៅគោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល
- ចូលរួមក្នុងសន្និសីទ និងកិច្ចប្រជុំជាតិនិងអន្តរជាតិស្ដីពីប្រជាជននិងអភិវឌ្ឍន៍
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គលេខាធិការដ្ឋានប្រជាជនិងអភិវឌ្ឍន៍
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ៣៧.-**

នាយកដ្ឋានបណ្ដុះបណ្ដាលនិងអភិវឌ្ឍន៍ មានភារកិច្ចដូចតទៅ៖

- កសាងផែនការនិងដំណើរការបណ្ដុះបណ្ដាលធនធានមនុស្សនៅតាមបណ្ដាអង្គភាពនានាក្នុងនិងក្រៅអគ្គលេខាធិការដ្ឋានពាក់ព័ន្ធនឹងប្រជាជននិងអភិវឌ្ឍន៍
- សិក្សាស្រាវជ្រាវ ចងក្រងឯកសារ និងរៀបចំការបណ្ដុះបណ្ដាលដល់មន្ត្រីក្នុងក្របខ័ណ្ឌអគ្គលេខាធិការដ្ឋានប្រជាជននិងអភិវឌ្ឍន៍ មន្ទីរផែនការរាជធានី ខេត្ត និងក្រសួងផែនការ និងអ្នកពាក់ព័ន្ធ លើប្រធានបទនានាទាក់ទងនឹងគោលនយោបាយជាតិប្រជាជននិងប្រជាសាស្ត្រ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងប្រធានបទផ្សេងៗ ដូចជា ភាពជាអ្នកដឹកនាំនិងនវានុវត្តន៍ និងសេដ្ឋកិច្ចនិងសង្គមឌីជីថល
- ផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេសដល់មន្ត្រីការិយាល័យប្រជាជននិងអភិវឌ្ឍន៍ និងមន្ត្រីពាក់ព័ន្ធ ក្នុងការរៀបចំរបាយការណ៍អំពីស្ថានភាពប្រជាសាស្ត្ររាជធានី ខេត្ត
- ចូលរួមក្នុងកម្មវិធីផ្លាស់ប្ដូរបទពិសោធន៍ វគ្គបណ្ដុះបណ្ដាល សិក្ខាសាលា នៅក្នុងនិងក្រៅប្រទេស អំពីទំនាក់ទំនងពហុវិស័យរវាងប្រជាជននិងអភិវឌ្ឍន៍ ដើម្បីបង្កើនសមត្ថភាព
- សម្របសម្រួលនិងសហការជាមួយនឹងស្ថាប័នបណ្ដុះបណ្ដាលក្នុងនិងក្រៅប្រទេស
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

**មាត្រា ៣៨.-**

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍មានភារកិច្ចដូចតទៅៈ

- សិក្សាស្រាវជ្រាវ អង្កេត និងកំណត់សូចនាករអំពីសហគមន៍នៅកម្ពុជា
- ប្រមូល ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍នៅកម្ពុជា
- សម្របសម្រួលនិងសហការជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិនិងអន្តរជាតិ សង្គមស៊ីវិល និងវិស័យឯកជន លើការងារនិងសកម្មភាពដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍ ដើម្បីកែលម្អនិងពង្រឹងសមត្ថភាព និងស្វែងរកដៃគូដែលមានសក្ដានុពលក្នុងការជួយអភិវឌ្ឍនិងផ្ដល់ឥណទានដល់សហគមន៍ រួមទាំងការបណ្ដុះបណ្ដាលពីរបៀបកែច្នៃផលិតផលរបស់សហគមន៍នីមួយៗឱ្យមានលទ្ធភាពប្រកួតប្រជែង
- រៀបចំនិងកែលម្អឱ្យមានការផ្លាស់ប្តូរ និងដកស្រង់យកបទពិសោធន៍ល្អៗពីសហគមន៍មួយទៅសហគមន៍មួយទៀត តាមរយៈទស្សនកិច្ចសិក្សា ឬសិក្ខាសាលាថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ ដើម្បីឱ្យការអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាពនិងនវានុវត្តន៍
- ចងក្រងឯកសារគោលនយោបាយ ឯកសារគតិយុត្តិ និងឯកសារស្តីពីសហគមន៍ ដើម្បីជាឯកសារជំនួយស្មារតីបន្ថែមទៀតសម្រាប់សហគមន៍ ស្ថាប័នពាក់ព័ន្ធ និងអ្នកសិក្សាស្រាវជ្រាវប្រើប្រាស់
- ផ្សព្វផ្សាយអំពីលទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវ និងអង្កេតផ្សេងៗពាក់ព័ន្ធនឹងសហគមន៍
- បណ្ដុះបណ្ដាលស្តីពីការអភិវឌ្ឍសហគមន៍ ដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអ្នកមានចំណែកពាក់ព័ន្ធ
- ចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនានាអំពីការអភិវឌ្ឍសហគមន៍ទាំងក្នុងទាំងក្រៅប្រទេស ដើម្បីបង្កើនសមត្ថភាពជំនាញ
- តាមដានត្រួតពិនិត្យនិងវាយតម្លៃសហគមន៍ដែលបានរៀបចំការអភិវឌ្ឍកន្លងមក
- រៀបចំផែនការសកម្មភាព និងផែនការថវិកាពាផ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គលេខាធិការ។

## ជំពូក ៨
## អគ្គាធិការដ្ឋាន

**មាត្រា ៣៩.-**

អគ្គាធិការដ្ឋានមានតួនាទីនិងភារកិច្ចដូចតទៅៈ

- ទទួលបន្ទុកអនុវត្តមុខងារដូចមានចែងក្នុងអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- ធ្វើអធិការកិច្ចជាប្រចាំទៅលើការគ្រប់គ្រងអង្គភាពក្រោមឱវាទរបស់ក្រសួងផែនការ

២៨/៣៤

- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីអំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចរួចហើយ និងអំពីមធ្យោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់អគ្គាធិការដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី ក្រសួងផែនការ។

## ជំពូក ៩
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអង្គភាពលទ្ធកម្ម

**មាត្រា ៤០.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានភារកិច្ចដូចតទៅ៖

- អនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងតាមបណ្តា ស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ និងអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ ២០២០ ស្តីពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំនិងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រី ក្រសួងផែនការ។

**មាត្រា ៤១.-**

អង្គភាពលទ្ធកម្ម មានភារកិច្ចដូចតទៅ៖

- អង្គភាពលទ្ធកម្ម ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធី នៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម
- រៀបចំ និងអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំសេចក្តីសម្រេចបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកាថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់អង្គភាពថវិកា នៃស្ថាប័នអនុវត្តលទ្ធកម្ម ក្នុងក្របខណ្ឌក្រសួងផែនការ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងផែនការ។

## ជំពូក ១០
## សាលាជាតិផែនការ និងស្ថិតិ

**មាត្រា ៤២.-**

សាលាជាតិផែនការ និងស្ថិតិ មានតួនាទីនិងភារកិច្ចដូចតទៅ៖

- ដឹកនាំ គ្រប់គ្រងនិងសម្របសម្រួលលើការងារអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យផែនការ ស្ថិតិ និងប្រជាសាស្ត្រ
- រៀបចំផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់សាលាជាតិផែនការ និងស្ថិតិ
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសម្រាប់មហាវិទ្យាល័យ ដេប៉ាតេម៉ង់ និងមជ្ឈមណ្ឌល

- រៀបចំបទបញ្ញត្តិនានាស្តីពីការគ្រប់គ្រងការសិក្សា និងការងាររដ្ឋបាល
- គ្រប់គ្រងការងារបណ្តុះបណ្តាល ការងារស្រាវជ្រាវ ការប្រលងនិងការប្រគល់សញ្ញាបត្រ
- រៀបចំកម្មវិធីសិក្សាឱ្យសមស្របតាមលក្ខខណ្ឌ និងបទបញ្ញត្តិនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- អនុវត្តតាមបទដ្ឋាន និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំផ្ទៃក្នុងនៅគ្រឹះស្ថានឧត្តមសិក្សា
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងបណ្តាប្រទេសនានា ដើម្បីអភិវឌ្ឍលើការងារបណ្តុះបណ្តាលក្នុងវិស័យផែនការ ស្ថិតិ និងប្រជាសាស្ត្រ
- សហការធ្វើការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ ធ្វើទំនើបកម្មកម្មវិធីសិក្សាលើជំនាញក្នុងវិស័យផែនការ ស្ថិតិ ប្រជាសាស្ត្រ និងវិធីសាស្ត្រស្រាវជ្រាវ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សាឱ្យមានលក្ខណៈទំនើបតាមតម្រូវការសង្គម
- រៀបចំផែនការ និងអភិវឌ្ឍន៍កម្មវិធីសិក្សា អប់រំ បណ្តុះបណ្តាលលើវិស័យផែនការ ស្ថិតិ ប្រជាសាស្ត្រនិងវិធីសាស្ត្រស្រាវជ្រាវ ព្រមទាំងជ្រើសរើសគ្រូបង្រៀនតាមមុខវិជ្ជាជំនាញ ដើម្បីធានាបានគុណភាព និងប្រសិទ្ធភាពខ្ពស់
- ជំរុញបង្កើនសមត្ថភាពស្រាវជ្រាវ អភិវឌ្ឍន៍ស្តង់ដានានាក្នុងវិស័យផែនការ ស្ថិតិ ប្រជាសាស្ត្រ និងវិធីសាស្ត្រស្រាវជ្រាវ
- សហការរៀបចំការបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យម ដល់សិក្ខាកាមជាមន្ត្រីរាជការមកពីក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងវិស័យឯកជន លើជំនាញផែនការ ស្ថិតិ ប្រជាសាស្ត្រ និងវិធីសាស្ត្រស្រាវជ្រាវ
- រៀបចំការអប់រំនិងបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញផែនការអភិវឌ្ឍន៍ ស្ថិតិ ប្រជាសាស្ត្រ និងជំនាញផ្សេងៗទៀតតាមការចាំបាច់
- ធ្វើការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន ស្របតាមគោលការណ៍កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល
- រៀបចំគម្រោងចំណូល ចំណាយថវិកា ផែនការប្រតិបត្តិ ធនធានមនុស្ស សម្ភារៈ ភស្តុភាប្រចាំឆ្នាំរបស់សាលាជាតិផែនការ និងស្ថិតិ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំ ៥ឆ្នាំ និងប្រចាំឆ្នាំរបស់សាលាជាតិផែនការ និងស្ថិតិ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនរដ្ឋមន្ត្រីក្រសួងផែនការ និងស្ថាប័នពាក់ព័ន្ធ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន

សាលាជាតិផែនការ និងស្ថិតិ មានក្រុមប្រឹក្សាភិបាលមួយ សម្រាប់ពិនិត្យនិងសម្រេចលើគោលនយោបាយផែនការអភិវឌ្ឍន៍ អនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

សាលាជាតិផែនការ និងស្ថិតិ មានមហាវិទ្យាល័យចំនួន ២ (ពីរ) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលស្រាវជ្រាវនិងអភិវឌ្ឍន៍ ចំនួន១(មួយ)។

៣០/៣៤

**មាត្រា ៤៣.-**

មហាវិទ្យាល័យផែនការអភិវឌ្ឍន៍ មានភារកិច្ចដូចតទៅ៖

- សហការរៀបចំផែនការ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់សាលាជាតិផែនការ និងស្ថិតិ
- រៀបចំផែនការ និងអភិវឌ្ឍន៍ កម្មវិធីសិក្សា អប់រំ ការបណ្តុះបណ្តាលលើវិស័យផែនការអភិវឌ្ឍន៍
- រៀបចំបច្ចុប្បន្នភាពកម្មវិធីសិក្សា អប់រំ បណ្តុះបណ្តាល និងជ្រើសរើសគ្រូបង្រៀន តាមមុខវិជ្ជាជំនាញ
- សហការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ លើជំនាញក្នុងវិស័យផែនការ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សា
- ផ្តល់ការអប់រំនិងបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញផែនការអភិវឌ្ឍន៍
- គ្រប់គ្រងចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗរបស់មហាវិទ្យាល័យនៃសាលាជាតិផែនការ និងស្ថិតិ ឱ្យមាននិរន្តភាពប្រកបដោយគុណភាព ប្រសិទ្ធភាព សុវត្ថិភាព
- រៀបចំវគ្គសិក្សាអាហារូបករណ៍ និងបង់ថ្លៃដល់និស្សិត និងសាធារណជនមកពីគ្រប់មជ្ឈដ្ឋាននានា
- រៀបចំផែនការសកម្មភាពនិងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មហាវិទ្យាល័យ ព្រមទាំងសហការរៀបចំគម្រោងចំណូល ចំណាយថវិកា ផែនការប្រតិបត្តិ ធនធានមនុស្ស សម្ភារៈភស្តុភាប្រចាំឆ្នាំរបស់សាលាជាតិផែនការ និងស្ថិតិ
- គ្រប់គ្រង និងចាត់ចែងលើការងាររដ្ឋបាលក្នុងមហាវិទ្យាល័យ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំ និងប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ក្រសួង និងសាលាជាតិផែនការ និងស្ថិតិ។

**មាត្រា ៤៤.-**

មហាវិទ្យាល័យស្ថិតិ មានភារកិច្ចដូចតទៅ៖

- សហការរៀបចំផែនការ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់សាលាជាតិផែនការ និងស្ថិតិ
- រៀបចំផែនការ និងអភិវឌ្ឍន៍កម្មវិធីសិក្សា អប់រំ បណ្តុះបណ្តាលលើវិស័យស្ថិតិ និងវិធីសាស្ត្រស្រាវជ្រាវ
- រៀបចំកម្មវិធីសិក្សា អប់រំ បណ្តុះបណ្តាល និងជ្រើសរើសគ្រូបង្រៀនតាមមុខវិជ្ជាជំនាញ ដើម្បីធានាបានគុណភាព និងប្រសិទ្ធភាពខ្ពស់
- សហការធ្វើការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ លើជំនាញក្នុងវិស័យស្ថិតិ និងវិធីសាស្ត្រស្រាវជ្រាវ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សាឱ្យមានលក្ខណៈទំនើបតាមតម្រូវការ
- ផ្តល់ការអប់រំនិងបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញស្ថិតិ ប្រជាសាស្ត្រ ឱ្យបានសមស្របតាមតម្រូវការ
- គ្រប់គ្រងចរាចរឯកសារ និងលិខិតរដ្ឋបាលផ្សេងៗរបស់មហាវិទ្យាល័យ
- រៀបចំវគ្គសិក្សាអាហារូបករណ៍ និងបង់ថ្លៃដល់និស្សិត និងសាធារណជនមកពីគ្រប់មជ្ឈដ្ឋាន

- សហការរៀបចំគម្រោងចំណូល ចំណាយថវិកា ផែនការប្រតិបត្តិ ធនធានមនុស្ស សម្ភារៈ ភស្តុភាប្រចាំឆ្នាំរបស់សាលាជាតិផែនការ និងស្ថិតិ
- គ្រប់គ្រង និងចាត់ចែងលើការងាររដ្ឋបាលក្នុងមហាវិទ្យាល័យ
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំ និងប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ក្រសួង និងសាលាជាតិផែនការ និងស្ថិតិ។

**មាត្រា ៤៥.-**

មជ្ឈមណ្ឌលបណ្តុះបណ្តាល ស្រាវជ្រាវ និងអភិវឌ្ឍន៍ មានភារកិច្ចដូចតទៅ៖

- សហការរៀបចំផែនការ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់សាលាជាតិផែនការ និងស្ថិតិ
- រៀបចំផែនការ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ មជ្ឈមណ្ឌលបណ្តុះបណ្តាល ស្រាវជ្រាវ និងអភិវឌ្ឍន៍
- ស្រាវជ្រាវ អភិវឌ្ឍន៍ ផ្ទេរបច្ចេកវិទ្យា និងចំណេះដឹង សម្រាប់អភិវឌ្ឍន៍លើវិស័យ ផែនការ ស្ថិតិ ប្រជាសាស្ត្រ និងវិធីសាស្ត្រស្រាវជ្រាវ
- សិក្សា និងស្រាវជ្រាវលើការកំណត់បទដ្ឋានគំរូ តាមស្តង់ដារជាតិ និងអន្តរជាតិ សម្រាប់អភិវឌ្ឍន៍ធនធានមនុស្សលើវិស័យផែនការ និងស្ថិតិ និងវិធីសាស្ត្រស្រាវជ្រាវ
- សម្របសម្រួលការងាររបស់គម្រោងស្រាវជ្រាវ អភិវឌ្ឍន៍ និងផ្ទេរចំណេះដឹងរបស់ស្ថាប័នជាតិ អន្តរជាតិ និងសាធារណៈជន ក្នុងវិស័យផែនការ និងស្ថិតិ និងវិធីសាស្ត្រស្រាវជ្រាវ
- ជំរុញបង្កើនសមត្ថភាពស្រាវជ្រាវ អភិវឌ្ឍន៍ក្នុងវិស័យផែនការ និងស្ថិតិ និងវិធីសាស្ត្រស្រាវជ្រាវ
- រៀបចំសិក្ខាសាលា ឬកម្មវិធីផ្សព្វផ្សាយស្តីពីគម្រោងស្រាវជ្រាវ អភិវឌ្ឍន៍ និងរបកគំហើញថ្មីៗ ពាក់ព័ន្ធនឹងវិស័យផែនការ និងស្ថិតិ និងវិធីសាស្ត្រស្រាវជ្រាវ ឬធ្វើការបោះពុម្ពផ្សព្វផ្សាយតាមរយៈព្រឹត្តបត្រ ទស្សនាវដ្តី គេហទំព័រ និងបណ្តាញសង្គមនានា
- ផ្តល់សេវាប្រឹក្សាយោបល់ សេវាស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងសេវាពិសោធន៍ផ្សេងៗ ដោយបង់ថ្លៃសម្រាប់ស្ថាប័នជាតិ ដៃគូរអភិវឌ្ឍន៍ និងស្ថាប័នឯកជន
- អនុវត្តន៍គម្រោងសាកល្បងលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងគាំទ្រលើកទឹកចិត្តឧបត្ថម្ភចំពោះកិច្ចការស្រាវជ្រាវ និងអភិវឌ្ឍន៍នានា
- ផ្តល់ការបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យម ដល់សិក្ខាកាមជាមន្ត្រីរាជការមកពីក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងវិស័យឯកជន លើជំនាញផែនការ ស្ថិតិ ប្រជាសាស្ត្រ និងវិធីសាស្ត្រស្រាវជ្រាវ
- គ្រប់គ្រង និងចាត់ចែងលើការងាររដ្ឋបាលក្នុងមជ្ឈមណ្ឌល
- រៀបចំផែនការសកម្មភាព និងផែនការថវិកា៣ឆ្នាំ និងប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- សហការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់សាលាជាតិផែនការ និងស្ថិតិ
- សហការរៀបចំគម្រោងចំណូល ចំណាយ ផែនការប្រតិបត្តិការ ធនធានមនុស្ស សម្ភារៈ ភស្តុភាប្រចាំឆ្នាំរបស់សាលាជាតិផែនការ និងស្ថិតិ
- ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ខ្លួនប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ក្រសួង និងសាលាជាតិផែនការ និងស្ថិតិ។

## ជំពូក ១១
## អង្គភាពថ្នាក់ក្រោមជាតិ

**មាត្រា ៤៦.-**

មន្ទីរផែនការរាជធានី ខេត្ត មានតួនាទី និងភារកិច្ចដឹកនាំ គ្រប់គ្រង អនុវត្តនិងសម្របសម្រួលសកម្មភាពការងារវិស័យផែនការ ស្ថិតិ និងប្រជាជននិងអភិវឌ្ឍន៍ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងផែនការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូក ១២
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៤៧.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូក ១៣
## អន្តរប្បញ្ញត្តិ

**មាត្រា ៤៨.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការ ការបង្កើតឬការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពនានាចំណុះក្រសួងផែនការ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូក ១៤
## អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ និងអនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យដូចតទៅ៖

- អនុក្រឹត្យលេខ ៧០ អនក្រ .បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- អនុក្រឹត្យលេខ ៥៥ អនក្រ .បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- អនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងផែនការ
- អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតនាយកដ្ឋានមួយចំនួនចំណុះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
- អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រជាជននិងការអភិវឌ្ឍ។

៣៣/៣៤

**មាត្រា ៥០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១ រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**

សូមឡាយហត្ថលេខា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

កិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន**

**ចម្លងជូន ៖**

- ក្រសួងបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ